## ជំពូកទី១ : ការគណនាក្នុងគីមី

## មេរៀនទី១ : រូបមន្ត និង សមីការគីមី

### I-និមិត្តសញ្ញា និងរូបមន្តគីមី

**១-និមិត្តសញ្ញានៃធាតុគីមី** (Element Symbol)

អាតូមនៃធាតុគីមីទាំងឡាយត្រូវបានតាងដោយនិមិត្តសញ្ញារបស់វា។ ជាទូទៅគេកំណត់និមិត្តសញ្ញានៃធាតុគីមីដោយយកតួអក្សរធំដែលជាតួអក្សរទីមួយខាងដើម ឬសរសេរជាមួយអក្សរតូចនៃតួទីពីរ ឬ ទីបីនៃឈ្មោះធាតុគីមីជាអក្សរឡាតាំង ឬ ភាសាអន្តរជាតិដទៃទៀត ។



ឧទាហរណ៍ : C = Carbon , B = Boron , P = Phosphorus , U = Uranium , ….
Ca = Calcium , Co = Cobalt , Ni = Nickel , Ba = Barium , ….
Cl = Chlorine , Mg = Magnesium , Mn = Manganese , Cr = Chromium, ….
Cu = Cuprum , Au = Aurum , Fe = Ferrum , K = Kalium,….

**២-រូបមន្តគីមី** (Chemical Formulas)

សមាសធាតុគីមីទាំងឡាយតាងដោយរូបមន្តគីមី ។ រូបមន្តគីមីនៃសារធាតុមួយប្រាប់ឱ្យយើងដឹងពីចំនួនធាតុដែលចូលផ្សំ និងចំនួនអាតូមរបស់ធាតុនីមួយៗដែលមាននៅក្នុងម៉ូលេគុលនៃសារធាតុនោះ ។

**-អ៊ីយ៉ុងសាមញ្ញមួយចំនួន**

| វ៉ាឡង់ | អ៊ីយ៉ុងបន្ទុកវិជ្ជមាន | អ៊ីយ៉ុងបន្ទុកអវិជ្ជមាន |
|---|---|---|
| ១ | អ៊ីយ៉ុង សូដ្យូម $Na^+$<br>អ៊ីយ៉ុង ប៉ូតាស្យូម $K^+$<br>អ៊ីយ៉ុង អ៊ីដ្រូសែន $H^+$<br>អ៊ីយ៉ុង អាម៉ូញ៉ូម $NH_4^+$ | អ៊ីយ៉ុង ក្លរ $Cl^-$<br>អ៊ីយ៉ុង ប្រូម $Br^-$<br>អ៊ីយ៉ុង អ៊ីដ្រុកស៊ីត $OH^-$<br>អ៊ីយ៉ុង អ៊ីដ្រូសែនស៊ុលផាត $HSO_4^-$ |
| ២ | អ៊ីយ៉ុង សំណ (II) $Pb^{2+}$<br>អ៊ីយ៉ុង កាល់ស្យូម $Ca^{2+}$<br>អ៊ីយ៉ុង សង្កសី $Zn^{2+}$<br>អ៊ីយ៉ុង ដែក (II) $Fe^{2+}$ | អ៊ីយ៉ុង ស៊ុលផាត $SO_4^{2-}$<br>អ៊ីយ៉ុង កាបូណាត $CO_3^{2-}$<br>អ៊ីយ៉ុង ស៊ុលផួ $S^{2-}$ |
| ៣ | អ៊ីយ៉ុង ដែក (III) $Fe^{3+}$ | អ៊ីយ៉ុង ផូស្វាត $PO_4^{3-}$ |

ឧទាហរណ៍ : NaCl , $Na_2CO_3$ , $Zn(OH)_2$…… ។

**ចំណាំ** : ដើម្បីសរសេររូបមន្តគីមីនៃសមាសធាតុអ៊ីយ៉ុង យើងត្រូវសរសេរឈ្មោះរបស់ធាតុសរសេរអ៊ីយ៉ុងដែលចូលផ្សំលៃយ៉ាងណាឱ្យ ចំនួនបន្ទុកវិជ្ជមាន (+) ស្មើនឹងចំនួនបន្ទុកអវិជ្ជមាន (-) ។

***រូបមន្តគីមីរបស់សមាសធាតុកូវ៉ាឡង់មួយចំនួនដែលមិនបំបែកជាអ៊ីយ៉ុង**

| ម៉ូលេគុលកូវ៉ាឡង់ | រូបមន្ត | ម៉ូលេគុលកូវ៉ាឡង់ | រូបមន្ត |
|---|---|---|---|
| អ៊ីដ្រូសែន | $H_2$ | កាបូនម៉ូណូអុកស៊ីត | $CO$ |
| អុកស៊ីសែន | $O_2$ | កាបូនឌីអុកស៊ីត | $CO_2$ |
| ក្លរ | $Cl_2$ | ស្ពាន់ធ័រឌីអុកស៊ីត | $SO_2$ |
| អាសូត | $N_2$ | ស្ពាន់ធ័រទ្រីអុកស៊ីត | $SO_3$ |
| ទឹក | $H_2O$ | អាសូតឌីអុកស៊ីត | $NO_2$ |
| អាម៉ូញ៉ាក់ | $NH_3$ | អ៊ីដ្រូសែនក្លរួ | $HCl$ |

## II- វ៉ាឡង់ និងរូបមន្តគីមី

### ១-វ៉ាឡង់ (Valence)

វ៉ាឡង់ជាលទ្ធភាពចូលផ្សំនៃអាតូមឬរ៉ាឌីកាល់ជាមួយធាតុដទៃទៀត។ ចំពោះសមាសធាតុអ៊ីយ៉ុង វ៉ាឡង់ស្មើនឹងបន្ទុកនៅលើអ៊ីយ៉ុង។ ជានិច្ចកាលវ៉ាឡង់ជាចំនួនគត់តូច ឬសូន្យតាងដោយលេខរ៉ូម៉ាំង។

### ២-រ៉ាឌីកាល់

រ៉ាឌីកាល់គឺជាក្រុមអាតូមដែលចូលរួមក្នុងរូបមន្តម៉ូលេគុលនៃអង្គធាតុសមាសមួយចំនួន។

### *វ៉ាឡង់នៃធាតុ និងរ៉ាឌីកាល់មួយចំនួន

| ឈ្មោះធាតុ | និមិត្តសញ្ញា | វ៉ាឡង់ | ឈ្មោះរ៉ាឌីកាល់ | និមិត្តសញ្ញា | វ៉ាឡង់ |
|---|---|---|---|---|---|
| អេល្យូម | He | ០ | អ៊ីដ្រុកស៊ីត | $OH$ | ១ |
| នេអុង | Ne | ០ | នីត្រាត | $NO_3$ | ១ |
| អ៊ីដ្រូសែន | H | ១ | អាម៉ូញ៉ូម | $NH_4$ | ១ |
| លីចូម | Li | ១ | កាបូណាតអាស៊ីត | $HCO_3$ | ១ |
| សូដ្យូម | Na | ១ | កាបូណាត | $CO_3$ | ២ |
| ម៉ាញេស្យូម | Mg | ២ | ស៊ុលផាត | $SO_4$ | ២ |
| ស័ង្កសី | Zn | ២ | ផូស្វាត | $PO_4$ | ៣ |
| ដែក | Fe | ២ ឬ ៣ | | | |
| ស្ពាន់ធ័រ | S | ២ ឬ ៣ | | | |

### ៣-ការសរសេររូបមន្តគីមី (Writing chemical formulas)




-បើ $x = y$ គេសរសេរ AB

-បើ $x \neq y$ គេសរសេរ $A_yB_x$

ឧទាហរណ៍ : $Al_2O_3$ , $CO_2$……… ។

## III-ម៉ាសធៀប

## ១-ម៉ាសអាតូមធៀប $A_r$ ( Atomic mass ratio )

ម៉ាសអាតូមធៀបនៃអាតូមមួយ គឺជាផលធៀបម៉ាសមធ្យមរបស់អាតូមនៃធាតុនោះជាមួយនឹង 1/12 ម៉ាសអាតូមកាបូន 12 ( $^{12}C$) ។

$$A_r = \frac{\text{ម៉ាសមធ្យមរបស់អាតូមនៃធាតុមួយ}}{\text{ម៉ាសនៃ 1/12 របស់អាតូមកាបូន 12}}$$

ម៉ាសអាតូមធៀបគឺជាចំនួនគ្មានខ្នាត ។

ឧទាហរណ៍ : H = 1, O = 16 , Fe = 56 , Cl = 35.5 , ……… ។

## ២-ម៉ាសម៉ូលេគុលធៀប $M_r$ ( Molecular mass ratio )

ម៉ាសម៉ូលេគុលធៀបនៃសារធាតុមួយ គឺជាផលធៀបម៉ាសម៉ូលេគុលមធ្យមរបស់សារធាតុនោះជាមួយនឹង 1/12 ម៉ាសអាតូមកាបូន 12 ( $^{12}C$) ។

$$M_r = \frac{\text{ម៉ាសមធ្យមរបស់ម៉ូលេគុលនៃសមាសធាតុមួយ}}{\text{ម៉ាសនៃ 1/12 របស់អាតូមកាបូន 12}}$$

ម៉ាសម៉ូលេគុលធៀបគឺជាចំនួនគ្មានខ្នាត ។

ក្នុងការអនុវត្តម៉ាសម៉ូលេគុលធៀបរបស់ម៉ូលេគុលមួយ គេអាចគណនាតាមផលបូកនៃម៉ាសអាតូមធៀបនៃធាតុបង្កក្នុងម៉ូលេគុលនោះ ។

ឧទាហរណ៍ : គេឱ្យម៉ាសអាតូមធៀប $A_r(H) = 1$ , $A_r(S) = 32$ , $A_r(O) = 16$ ។ ចូរគណនា $M_r(H_2SO_4)$ ?

, ចម្លើយ :

## IV-សមាសភាពសតភាគ (%) (Percent Composition of Compounds)

## ១-សមាសភាពសតភាគនៃធាតុបង្កក្នុងម៉ូលេគុល (Percent Composition of an element)

$$\text{ភាគរយនៃធាតុ} = \frac{A_r \text{ របស់ធាតុ x ចំនួនអាតូមរបស់ធាតុ}}{M_r \text{ របស់សមាសធាតុ}} \times 100\ \%$$

ឧទាហរណ៍ : គេមានរូបមន្ត NaCl ចូរគណនា %Na និង %Cl ? គេឱ្យ $A_r(Na) = 23$ , $A_r(Cl) = 35.5$ ។

ចម្លើយ :

## ២-គណនាម៉ាសនៃធាតុបង្កក្នុងសមាសធាតុមួយ

$$\text{ម៉ាសធាតុបង្ក} = \frac{A_r \text{ របស់ធាតុ} \times \text{ចំនួនអាតូមធាតុបង្កក្នុងរូបមន្ត}}{M_r \text{ របស់សមាសធាតុ}} \times \text{ម៉ាសភាគសំណាក}$$

ឧទាហរណ៍ : គណនាម៉ាស Cu នៅក្នុង 32g នៃក្រាម $CuSO_4$? គេឱ្យ $A_r(O) = 16$ , $A_r(Cu) = 64$ , $A_r(S) = 32$ ។

ចម្លើយ :

## V- គណនាម៉ាសទឹកក្នុងសមាសធាតុ

សមាសធាតុក្រាមទាំងឡាយណាដែលមានទឹកក្នុងម៉ូលេគុលរបស់វាហៅថា *សមាសធាតុអ៊ីដ្រាតេ*។

ឧទាហរណ៍ : $CuSO_4 . 5H_2O$ ក្រាមទង់ដែង (II) ស៊ុលផាតប៉ង់តាអ៊ីដ្រាតេ ។

$$\text{ម៉ាស } H_2O \text{ ក្នុងសមាសធាតុ} = \frac{M_r \text{ នៃ } H_2O \times \text{ចំនួនម៉ូល } H_2O \text{ ក្នុងរូបមន្ត}}{M_r \text{ នៃសមាសធាតុ}} \times \text{ម៉ាសភាគសំណាក}$$

ឧទាហរណ៍ : ចូរគណនាម៉ាស $H_2O$ ក្នុង 10g នៃក្រាម $Na_2CO_3 . 10H_2O$? គេឱ្យ $A_r(O) = 16$ , $A_r(Na) = 23$ , $A_r(C) = 12$ ។

ចម្លើយ :

## VI-រូបមន្តងាយ (Empirical Formulas)

រូបមន្តងាយរបស់សមាសធាតុគីមីគឺជារូបមន្តបង្ហាញពីចំនួនអាតូមធៀបនៃធាតុខុសៗគ្នា។ គេអាចកំណត់រូបមន្តងាយបានកាលណាគេស្គាល់ភាគរយ (%) ឬម៉ាសរបស់ធាតុនីមួយៗ។

ឧទាហរណ៍ : ចូររករូបមន្តងាយនៃសមាសធាតុមួយដោយដឹងថាវាមានបង្កដោយអុកស៊ីសែន 88.89% និង អ៊ីដ្រូសែន 11.11%?

| | H | O |
|---|---|---|
| -ចែក % ដោយ $A_r$ របស់ធាតុនីមួយៗ | $\frac{11.11}{1} = 11.11$ | $\frac{88.89}{16} = 5.55$ |
| -ចែកជាមួយលទ្ធផលដែលតូចជាងគេ | $\frac{11.11}{5.55} = 2$ | $\frac{5.55}{5.55} = 1$ |
| -រូបមន្តងាយ | $H_2$ | O |

**VII-សមីការគីមី** (Chemical Equations)

ក្នុងសមីការគីមីធាតុ ឬ សមាសធាតុនៃផ្នែកខាងឆ្វេងសញ្ញាព្រួញហៅថា *អង្គធាតុប្រតិករ* ហើយសារធាតុថ្មីដែលកកើតនៅផ្នែកខាងស្តាំសញ្ញាព្រួញហៅថា *អង្គធាតុកកើត* ឬ *ផលិតផល* ។

សមីការដែលគេសរសេរជាអក្សរហៅថា*សមីការពាក្យ*រីឯសមីការដែលគេសរសេរដោយប្រើនិមិត្តសញ្ញាហៅថា*សមីការគីមី* ។

**ចំណាំ :** សមាសធាតុទាំងអស់ត្រូវមានភាពរូបរបស់វាផ្ទាល់ ។ ភាពរូបអង្គធាតុរឹង (Solid) តាងដោយ (S) អង្គធាតុរាវ (Liquid) តាងដោយ (l) ឧស្ម័ន (gas) តាងដោយ (g) និងសារធាតុដែលរលាយក្នុងទឹក (aqueous) តាងដោយ (aq) ។

ឧទាហរណ៍ : ចូរសរសេរសមីការតាងប្រតិកម្មនៅពេលម៉ាញេស្យូមឆេះក្នុងអុកស៊ីសែនបង្កើតជាម៉ាញេស្យូមអុកស៊ីត?

| | | |
|---|---|---|
| សមីការពាក្យ | : | ម៉ាញេស្យូម + អុកស៊ីសែន → ម៉ាញេស្យូមអុកស៊ីត |
| សមីការគីមី | : | $Mg + O_2 \rightarrow MgO$ |
| ថ្លឹងសមីការ | : | $2Mg + O_2 \rightarrow 2MgO$ |
| ដាក់និមិត្តសញ្ញាភាពរូប | : | $2Mg(s) + O_2(g) \rightarrow 2MgO(s)$ |

**VIII-សមីការអ៊ីយ៉ុង**

សមីការអ៊ីយ៉ុងជាសមីការបានមកពីអ៊ីយ៉ុងចូលផ្សំគ្នានៅក្នុងសូលុយស្យុង។ អង្គធាតុដែលរលាយក្នុងប្រតិកម្មគីមីអាចសរសេរជាអ៊ីយ៉ុងបាន ចំណែកឯអង្គធាតុរឹងមិនអាចសរសេរជាអ៊ីយ៉ុងបានទេ ។

ឧទាហរណ៍ : សមីការពាក្យ : សូដ្យូមអ៊ីដ្រុកស៊ីត + ទង់ដែង(II) ស៊ុលផាត → សូដ្យូមស៊ុលផាត + ទង់ដែង(II) អ៊ីដ្រុកស៊ីត

សមីការគីមី : $2NaOH(aq) + CuSO_4(aq) \rightarrow Na_2SO_4(aq) + Cu(OH)_2(s)$

សមីការអ៊ីយ៉ុង : $2Na^+(aq) + 2OH^-(aq) + Cu^{2+}(aq) + SO_4^{2-}(aq) \rightarrow 2Na^+(aq) + SO_4^{2-}(aq) + Cu(OH)_2(s)$

**ចំណាំ:** អ៊ីយ៉ុងទាំងឡាយដែលមិនចូលរួមប្រតិកម្មហៅថា *អ៊ីយ៉ុងទស្សនិក* ដែលគេអាចសម្រួលចោលបាន។ ដូចនេះសមីការអ៊ីយ៉ុងខាងលើគេអាចសរសេរ : $Cu^{2+}(aq) + 2OH^-(aq) \rightarrow Cu(OH)_2(s)$

## មេរៀនទី២ : ចំនួនម៉ូល

### I-ម៉ូល

អ្នកគីមីបានកំណត់យកឯកតាមួយសម្រាប់កំណត់បរិមាណនៃភាគល្អិតដូចជា អាតូម អ៊ីយ៉ុង និង ម៉ូលេគុល ហៅថា *ម៉ូល* តាងដោយនិមិត្តសញ្ញា mol ។



ឧទាហរណ៍ : 1mol អាតូមមានចំនួន $6.02.10^{23}$ អាតូម

1mol ម៉ូលេគុលមានចំនួន $6.02.10^{23}$ ម៉ូលេគុល

1mol អេឡិចត្រុងមានចំនួន $6.02.10^{23}$ អេឡិចត្រុង

ជាទូទៅ 1mol ភាគល្អិតមានចំនួន $6.02.10^{23}$ ភាគល្អិត ។

ដូចនេះចំនួន $6.02.10^{23}$ ហៅថា *ចំនួនអាវ៉ូកាដ្រូ* ដែលតាងដោយ $N=6.02.10^{23}$ ។

ម៉ូលគឺជាបរិមាណកំណត់នៃសារធាតុមួយដែលបង្កដោយភាគល្អិតចំនួន $N=6.02.10^{23}$ ។

### II-ម៉ូលនៃអាតូម ម៉ូលេគុល និងឧស្ម័ន

#### ១-ម៉ូលនៃអាតូម និងម៉ូលនៃម៉ូលេគុល

1mol អាតូមរបស់ធាតុគីមីមានម៉ាសស្មើនឹងម៉ាសអាតូមធៀបគិតជាក្រាម ។ ម៉ាស1mol អាតូមនេះហៅថា *ម៉ាសម៉ូល*។

$$\text{ចំនួនម៉ូល} = \frac{\text{ម៉ាសធាតុជាក្រាម}}{\text{ម៉ាសម៉ូលរបស់ធាតុ}}$$

ឬ

$$n = \frac{m}{M}$$

- n គិតជា mol
- m គិតជា g
- M គិតជា $g.mol^{-1}$

ឧទាហរណ៍ : ១-តើនៅក្នុង 8g មានប៉ុន្មានម៉ូលអាតូមស្ពាន់ធ័រ? $A_r(S) = 32$ ។

២-គណនាចំនួនម៉ូលេគុលទឹក 4.5g ។ គេឱ្យ $A_r(O) = 16$ , $A_r(H) = 1$ ។

ចម្លើយ :

#### ២-ម៉ូលនៃឧស្ម័ន

**ច្បាប់អាវ៉ូកាដ្រូ** "ក្នុងលក្ខខណ្ឌនៃសីតុណ្ហភាព និងសម្ពាធដូចគ្នា មាឌប៉ុនគ្នានៃគ្រប់ឧស្ម័នតែងមានចំនួនម៉ូលេគុលស្មើគ្នា" ។

**ចំណាំ** : មាឌប៉ុនគ្នានៃឧស្ម័នផ្សេងគ្នា (ក្នុងលក្ខខណ្ឌដូចគ្នា) មានចំនួនម៉ូល ឬចំនួនម៉ូលេគុលស្មើគ្នា ។ មាឌឧស្ម័នតែងប្រែប្រួលទៅតាមសីតុណ្ហភាព និងសម្ពាធ ។

ឧទាហរណ៍ : នៅក្រោមសម្ពាធ ១ អាត់ម៉ូស្វែ (1atm) ឧស្ម័នមានមាឌ

$22.4\ L.\ mol^{-1}$ នៅសីតុណ្ហភាព 0 °C

$24.0\ L.\ mol^{-1}$ នៅសីតុណ្ហភាព 25 °C ( សីតុណ្ហភាពបន្ទប់)

$36.6\ L.\ mol^{-1}$ នៅសីតុណ្ហភាព 100 °C

ប៉ុន្តែគេជ្រើសរើសយកលក្ខខណ្ឌពិសេសមួយឈ្មោះថា *លក្ខខណ្ឌស្តង់ដា* (0 °C និង 1atm) ដើម្បីកំណត់តម្លៃមាឌម៉ូល ឈ្មោះថា *មាឌម៉ូលស្តង់ដា* ឬ *មាឌម៉ូលធម្មតា*។ $V_m = 22.4\ L.\ mol^{-1}$

**មាឌម៉ូល**

$$\text{មាឌម៉ូល} = \frac{\text{ម៉ាសម៉ូល}}{\text{ម៉ាសមាឌ}}$$

ឬ

$$Vm = \frac{M}{d}$$

M គិតជា $g.mol^{-1}$

d គិតជា $g.dm^{-3}$

$V_m$ គិតជា $dm^3.mol^{-1}$ ឬ $L.mol^{-1}$



## ៣-គណនាកម្រិតសុទ្ធ និងទិន្នផលជាភាគរយ

ទិន្នផលជាភាគរយប្រែប្រួល ឬផ្លាស់ប្តូរដោយកត្តាផ្សេងៗដូចជា : សីតុណ្ហភាព សម្ពាធ កាតាលីករ កម្រិតសុទ្ធនៃសារធាតុ...។

$$\text{ភាគរយកម្រិតសុទ្ធនៃសារធាតុ} = \frac{\text{ម៉ាសសារធាតុសុទ្ធដែលមាន}}{\text{ម៉ាសភាគសំណាក}} \times 100\%$$

$$\text{ទិន្នផល} = \frac{\text{ម៉ាសផលិតផលតាមពិសោធ}}{\text{ម៉ាសផលិតផលតាមទ្រឹស្តី}} \times 100\%$$

ឬ

$$Rd = \frac{m_{\text{តាមពិសោធ}}}{m_{\text{តាមទ្រឹស្តី}}} \times 100\%$$

ឧទាហរណ៍ : គេដុតថ្មកំបោរ $CaCO_3$ ចំនួន 50g នៅទីពិសោធន៍គេទទួលបាន CaO ចំនួន 21g ។ ចូរគណនាទិន្នផលនៃប្រតិកម្ម (Rd) ?

ចម្លើយ :

## ៤-កំហាប់នៃសូលុយស្យុង

សូលុយស្យុង = ធាតុរលាយ + ធាតុរំលាយ

**-កំហាប់ជាម៉ាស** $C_m$

$C_m$ នៃធាតុរលាយដែលគេបានរំលាយដើម្បីបានសូលុយស្យុង 1L ឬ $1dm^{-3}$ ។

$$C_m = \frac{m\ \text{ធាតុរលាយ}}{V_s\ \text{សូលុយស្យុង}}$$

- m គិតជា g
- $V_s$ គិតជា L ឬ $dm^3$
- $C_m$ គិតជា $g.dm^{-3}$ ឬ $g.L^{-1}$

**-កំហាប់ជាម៉ូល** $C_M$

$C_M$ ជាបរិមាណ (ចំនួនម៉ូល) នៃសារធាតុដែលរលាយក្នុង $1dm^3$ ឬ 1L សូលុយស្យុង ។

$$C_M = \frac{\text{ចំនួនម៉ូល}}{\text{មាឌសូលុយស្យុង}} \quad \text{ឬ} \quad C_M = \frac{n}{V_s}$$

- n គិតជា mol
- $V_s$ គិតជា $dm^3$ ឬ L
- $C_M$ គិតជា $mol.L^{-1}$ ឬ $mol.dm^{-3}$ ឬ M (ម៉ូល)

ចំណាំ : គេអាចប្តូរ $C_m$ ទៅជា $C_M$ ដោយប្រើរូបមន្តខាងក្រោម :

$$C_M = \frac{C_m}{M}$$

- M ម៉ាសម៉ូលេគុល គិតជា $g.mol^{-1}$
- $C_m$ កំហាប់ម៉ាស គិតជា $g.L^{-1}$ ឬ $g.dm^{-3}$
- $C_M$ កំហាប់ម៉ូល គិតជា $mol.dm^{-3}$ ឬ $mol.L^{-1}$ ឬ M

## ជំពូកទី២ : លោហៈ

## មេរៀនទី១ : លក្ខណៈរបស់លោហៈ (Properties of Metal)

### I. លក្ខណៈរូបនៃលោហៈ (The physical property of metals)

### ១-លក្ខណៈរូបរួម



-មានផ្លេកលោហៈ

-លោហៈអាចផែ ឬហូតជាលួសបាន

-លោហៈចម្លងចរន្តអគ្គិសនី និងកម្ដៅបានល្អ

-លោហៈមានចំណុចរលាយ និងរំពុះខ្ពស់

-មានដង់ស៊ីតេធំ

លក្ខណៈទាំងនេះហើយដែលអាចឱ្យគេញែកសម្គាល់ពីភាពខុសគ្នារវាងលោហៈនិងអលោហៈបាន ។

តារាងសង្ខេបពីលក្ខណៈរូបរបស់លោហៈនិងអលោហ

| លោហៈ | អលោហៈ |
|---|---|
| -ផ្លេកលោហៈ | -ស្រអាប់ |
| -ចម្លងកម្ដៅនិងអគ្គិសនីបានល្អ | -ចម្លងកម្ដៅនិងអគ្គិសនីអន់ |
| -ដង់ស៊ីតេធំ | -ដង់ស៊ីតេតូច |
| -ផែឬហូតជាលួសបាន | -ស្រួយនិងងាយបាក់បែក |
| -សីតុណ្ហភាពរលាយ និងរំពុះខ្ពស់ ។ | -សីតុណ្ហភាពរលាយនិងរំពុះទាប ។ |

### ២-សំលោហៈ (Alloy)

សំលោហៈគឺជាល្បាយនៃលោហៈពីរឬច្រើនផ្សំចូលគ្នា ។ តែក៏មានសំលោហៈខ្លះមានអលោហៈផងដែរ ។

សំលោហៈមានលក្ខណៈខុសពីអង្គធាតុបង្ករបស់វាទាំងសីតុណ្ហភាពរលាយ ទាំងរបឹង ។

ឧទាហរណ៍ : សំលោហៈ (Cu + Au) រឹងជាងមាសសុទ្ធ គេប្រើវាសម្រាប់ធ្វើជាគ្រឿងអលង្ការ ។

បើគេបន្ថែមបេរីល្យូម Be 1% ទៅលើ Cu គេបានសំលោហៈមួយប្រភេទដែលស្វិតជាងទង់ដែង 7ដង ។

**សម្គាល់ :** លោហៈសុទ្ធមានលក្ខណៈទន់ ព្រោះស្រទាប់អាតូមរបស់វាអាចរអិលលើគ្នាបានយ៉ាងងាយ ចំណែកឯសំលោហៈវិញ មានអាតូមនៃលោហៈផ្សេងគ្នាដែលមានទំហំខុសគ្នាធ្វើឱ្យស្រទាប់របស់វាតម្រៀបគ្នាគ្មានសណ្ដាប់ធ្នាប់ជាហេតុធ្វើឱ្យវារឹងខ្លាំង ហើយ មិនអាចរអិលលើគ្នាបានយ៉ាងងាយទេ ។

ស្រទាប់អាតូមលោហៈសុទ្ធ



ស្រទាប់អាតូមសំលោហៈ

### II-លក្ខណៈគីមីនៃលោហៈ (Chemical Property of metals)

### ១-អំពើនៅលើទឹក

លោហៈខ្លះគ្មានប្រតិកម្មជាមួយទឹក $H_2O$ ទេ ខ្លះទៀតមានប្រតិកម្មខ្សោយ ឯខ្លះទៀតមានប្រតិកម្មយ៉ាងខ្លាំងក្លា ។

ឧទាហរណ៍ :

$2K_{(s)} + 2H_2O_{(l)} \rightarrow 2KOH_{(aq)} + H_{2(g)}$

$Ca_{(s)} + 2H_2O_{(l)} \rightarrow Ca(OH)_{2(aq)} + H_{2(g)}$

$Mg_{(s)} + H_2O_{(l)} \rightarrow MgO_{(s)} + H_{2(g)}$

$Zn_{(s)} + H_2O_{(l)} \rightarrow ZnO_{(s)} + H_{2(g)}$

$Pb_{(s)} + H_2O_{(l)} \rightarrow$ គ្មានប្រតិកម្ម

$Cu_{(s)} + H_2O_{(l)} \rightarrow$ គ្មានប្រតិកម្ម

$Au_{(s)} + H_2O_{(l)} \rightarrow$ គ្មានប្រតិកម្ម

## ២-ប្រតិកម្មជាមួយអាស៊ីតក្លរីឌ្រិច (HCl)

លោហៈជាច្រើនមានប្រតិកម្មជាមួយ HCl រាវឱ្យផលជាលោហៈក្លរួ និងបំភាយឧស្ម័នអ៊ីដ្រូសែន $H_2$ ។

ឧទាហរណ៍ :

$2K_{(s)} + 2HCl_{(aq)} \rightarrow 2KCl_{(aq)} + H_{2(g)}$

$Ca_{(s)} + 2HCl_{(aq)} \rightarrow CaCl_{2(aq)} + H_{2(g)}$

$Fe_{(s)} + 2HCl_{(aq)} \rightarrow FeCl_{2(s)} + H_{2(g)}$

$Pb_{(s)} + 2HCl_{(aq)} \rightarrow PbCl_{2(s)} + H_{2(g)}$ (យឺតណាស់)

$Cu_{(s)} + 2HCl_{(aq)} \rightarrow$ គ្មានប្រតិកម្ម

$Au_{(s)} + 2HCl_{(aq)} \rightarrow$ គ្មានប្រតិកម្ម

## III-សេរីសកម្មភាព ឬប្រតិកម្មភាពគីមីនៃលោហៈ

សេរីសកម្មភាព ឬប្រតិកម្មភាពគីមីនៃលោហៈជាការរៀបចំលោហៈតាមលំដាប់សកម្មភាពគីមីរបស់លោហៈ ។

**K Na Ca Mg Al Mn Zn Fe Ni Sn Pb [H] Cu Hg Ag Pt Au**

**សកម្មខ្លាំង** ← **សេរីសកម្មភាព ឬប្រតិកម្មភាពគីមីនៃលោហៈ** — **សកម្មភាពខ្សោយ**

-K, Na, Ca មានប្រតិកម្មយ៉ាងខ្លាំងក្លាជាមួយទឹកត្រជាក់ ។ ដូចនេះគេត្រូវរក្សាពួកវានៅក្នុងប្រេងកាត ។

ឧទាហរណ៍ : $2Na_{(s)} + 2H_2O_{(l)} \rightarrow 2NaOH_{(aq)} + H_{2(g)}$

-ធាតុទាំងឡាយដែលនៅខាងមុខ H មានប្រតិកម្មជាមួយអាស៊ីតរាវរំដោះបានឧស្ម័ន $H_2$ ។

ឧទាហរណ៍ : $2Al_{(s)} + 3H_2SO_{4(aq)} \rightarrow Al_2(SO_4)_{3(aq)} + 3H_{2(g)}$

-លោហៈដែលឈរនៅពីក្រោយ H គ្មានប្រតិកម្មជាមួយអាស៊ីតទេ ប៉ុន្តែវាមានប្រតិកម្មជាមួយអាស៊ីតខាប់ដូចជា$HNO_{3(ខាប់)}$ ឬ $H_2SO_{4(ខាប់)}$ ។

ឧទាហរណ៍ : $Cu_{(s)} + 4HNO_{3(ខាប់)} \rightarrow Cu(NO_3)_{2(aq)} + 2NO_{2(g)} + 2H_2O_{(l)}$

## IV-ប្រតិកម្មជំនួសនៃលោហៈ

### ១-ប្រតិកម្មជំនួសលោហៈក្នុងសូលុយស្យុង

លោហៈដែលនៅខាងមុខអាចជំនួសអ៊ីយ៉ុងលោហៈដែលស្ថិតនៅខាងក្រោយវាក្នុងសេរីសកម្មភាពនៃលោហៈ ពីសូលុយស្យុងអំបិលបាន ។

ឧទាហរណ៍ :

$Zn_{(s)} + CuSO_{4(aq)} \rightarrow ZnSO_{4(aq)} + Cu_{(s)}$

$Zn_{(s)} + Cu^{2+}_{(aq)} + SO_4^{2-}{}_{(aq)} \rightarrow Zn^{2+}_{(aq)} + SO_4^{2-}{}_{(aq)} + Cu_{(s)}$

$Zn_{(s)} + Cu^{2+}_{(aq)} \rightarrow Zn^{2+}_{(aq)} + Cu_{(s)}$

### ២-ប្រតិកម្មជំនួសលោហៈពីអុកស៊ីតលោហៈ

លោហៈមួយចំនួនអាចទាញយកអុកស៊ីសែនពីអុកស៊ីតលោហៈដែលស្ថិតនៅពីក្រោយវាក្នុងស៊េរីសកម្មភាពនៃលោហៈ ។

ឧទាហរណ៍ : $Mg_{(s)} + CuO_{(s)} \rightarrow MgO_{(s)} + Cu_{(s)}$

$2Al_{(s)} + Fe_2O_{3(s)} \rightarrow Al_2O_{3(s)} + 2Fe_{(s)}$

### ៣-ប្រតិកម្មនៃអុកស៊ីតលោហៈជាមួយអ៊ីដ្រូសែន $H_2$

$H_2$ អាចចាប់អុកស៊ីសែនចេញពីអុកស៊ីតលោហៈឱ្យផលជាលោហៈនិងទឹក ។ ប៉ុន្តែវាគ្មានប្រតិកម្មជាមួយអុកស៊ីតលោហៈសកម្មខ្លាំង ដូចជាអុកស៊ីតនៃលោហៈ Na និង Ca ទេ ។

ឧទាហរណ៍ : $PbO_{(s)} + H_{2(g)} \rightarrow Pb_{(s)} + H_2O_{(l)}$

$Na_2O_{(s)} + H_{2(g)} \rightarrow$ គ្មានប្រតិកម្ម

### ៤-ប្រតិកម្មនៃអុកស៊ីតលោហៈជាមួយកាបូន

កាបូនអាចទាញយកអុកស៊ីសែនពីអុកស៊ីតលោហៈដែលមិនសូវសកម្មក្នុងស៊េរីបាន ប៉ុន្តែកាបូនពិបាកទាញយកអុកស៊ីសែនពីអុកស៊ីតនៃលោហៈដែលសកម្មខ្លាំង ។

ឧទាហរណ៍ : $2CuO_{(s)} + C_{(s)} \rightarrow 2Cu_{(s)} + CO_{2(g)}$

### V-កាបូណាត

សមាសធាតុកាបូណាតភាគច្រើនបានបំបែកទៅជាអុកស៊ីតលោហៈនិងឧស្ម័នកាបូនិចកាលណាដុតកម្តៅខ្លាំង ។ប៉ុន្តែកាបូណាតរបស់លោហៈសកម្មខ្លាំងពិបាកបំបែក ។

ឧទាហរណ៍ : $CuCO_{3(s)} \xrightarrow{\text{កម្តៅ}} 2Cu_{(s)} + CO_{2(g)}$

### VI-ការឡើងច្រែះ

កំណច្រែះត្រូវការចាំបាច់នូវទឹក និង អុកស៊ីសែន ។ ដូចនេះដើម្បីការពារនឹងការឡើងច្រែះគេមានវិធី ២ យ៉ាងគឺ :

#### ក-ការស្រោបដោយសារធាតុ

វិធីទូទៅមួយដើម្បីការពារកំណច្រែះ គឺការស្រោបលោហៈដោយស្រទាប់សារធាតុមួយដែលអាចការពារលោហៈមិនឱ្យប៉ះផ្ទាល់ជាមួយខ្យល់ និងទឹក ។ សារធាតុនេះមាន ថ្នាំលាប ប្រេង ខ្លាញ់ ឬលោហៈដទៃទៀត ។

#### ១-វិធីកាល់វ៉ានិច

កាល់វ៉ានិចជាវិធីស្រោបលោហៈដែក និងដែកថែបដោយស្រទាប់លោហៈសង្កសី ។ សង្កសីសកម្មជាងដែកហើយងាយរងកំណូតជាងដែក គេប្រើសង្កសីនៅក្នុងលំនាំនេះព្រោះ :

-សង្កសីថោកជាង

-រងកំណូតយឺតជាង

-មានចំណុចរលាយទាបជាងដែលងាយរំលាយ ដើម្បីស្រោបលើវត្ថុដែលធ្វើអំពីដែក និងដែកថែប ។

# មេរៀនទី២ យោបកលោហៈ (Extraction of Metal)

## I. យោបកលោហៈ

### ១_ការទទួលលោហៈពីរ៉ែ

លោហៈភាគច្រើនមាននៅក្នុងដីលាយជាមួយអលោហៈដូចជា $O_2$ , S , ឬ C ។ សមាសធាតុនេះហៅថា **រ៉ែ** ។ ឈ្មោះរ៉ែសំខាន់ៗមានដូចជា :

- កាណាលីត **$KMgCl_3$**
- អំបិលសម្ល **NaCl**
- ថ្មកំបោរ **$CaCO_3$**
- ដូឡូមីត **$CaMg(CO_3)_2$**
- បុកស៊ីត **$Al_2O_3$**
- ស្វាលេរីត **ZnS**
- អេម៉ាទីត **$Fe_2O_3$**
- ទីនស្តូន **$SnO_2$**
- កាលេណា **PbS**
- ទង់ដែងពីរីត **$CuFeS_2$**
- ស៊ីនណាបា **HgS**

យោបកលោហៈពីរ៉ែជាលំនាំរេដុកម្ម ដែលអ៊ីយ៉ុងលោហៈទទួលអេឡិចត្រុង ។ ដំណើរការនេះងាយ ឬពិបាកអាស្រ័យនឹងទីតាំង និងកម្រិតសកម្មរបស់លោហៈនៅក្នុងស៊េរីសកម្មភាព ។

ឧទាហរណ៍ : យោបកលោហៈ **Zn**

$$2ZnS_{(s)} + 3O_{2(g)} \rightarrow 2ZnO_{(s)} + 2SO_{2(g)}$$
$$ZnS_{(s)} + C_{(s)} \rightarrow Zn_{(s)} + CO_{(g)}$$

ឧទាហរណ៍ : យោបកលោហៈ **Al**

$$2Al_2O_3 \xrightarrow{\text{អគ្គិសនីភាគ}} 4Al + 3O_2$$

### ២_យោបកលោហៈដែក

**Fe** ស្ថិតនៅក្នុងដីជាសណ្ឋានជារ៉ែដែក ។ រ៉ែដែកមានច្រើនប្រភេទខុសគ្នាដូចជា : អេម៉ាទីត **($Fe_2O_3$)** ម៉ាញេទីត **($Fe_3O_4$)** ដែកពីរីត **($FeS_2$)** និង ស៊ីដេរូស **($FeCO_3$)** ។ គេទាញយក **Fe** ចេញពីរ៉ែរបស់វាដោយប្រើឡស្ទូដែក ។

#### ក_ប្រតិកម្មនៅក្នុងឡស្ទូដែក

-ដំណាក់ទី១ : ធ្យូងកូកឆេះដោយសារចរន្តខ្យល់ក្តៅ

$$C_{(s)} + O_{2(g)} \rightarrow CO_{(g)} + \text{កម្តៅ}$$

-ដំណាក់ទី២ : ការកកើតឡើងនៃ **CO**

$$CO_{2(g)} + C_{(s)} \rightarrow 2CO_{(g)}$$

-ដំណាក់ទី៣ : ដែក (III) អុកស៊ីតរងរេដុកម្ម

$$Fe_2O_{3(s)} + 3CO_{(g)} \rightarrow 2Fe_{(l)} + 3CO_{2(g)}$$

-**$CaCO_3$** ត្រូវបំបែកដោយកម្តៅឱ្យផលជា **CaO** និង **$CO_2$** ។

$$CaCO_{3(s)} + CaO_{(s)} \rightarrow CO_{2(g)}$$

-រ៉ែដែកមានផ្ទុកធាតុមិនសុទ្ធជាច្រើន : **Si, S, P….** ។

$$CaO_{(s)} + SiO_{2(s)} \rightarrow CaSiO_{3(l)}$$



*Figure 22-8* A schematic drawing of a blast furnace for reduction of iron ore.

### ១_នាទីដែកថែប

ដែកថែបជាសំលោហៈដែក និង កាបូន លាយជាមួយបរិមាណលោហៈដទៃទៀត ដើម្បីឱ្យមានលក្ខណៈប្រសើរជាង។ ដែកថែបមានលក្ខណៈរឹង ហើយអាចពត់ និងទាញឱ្យយឺតបាន។

### គ_ប្រភេទនៃដែកថែប

លក្ខណៈរបស់ដែកថែបអាស្រ័យទៅលើបរិមាណកាបូនដែលមាន។ ដែកថែបមានពីរប្រភេទគឺ ដែកថែបកាបូន និង ដែកថែបពិសេស។

-ដែកថែបកាបូន : មានបរិមាណ (**P, S, Si**) តិចបំផុត។ ដែកកាន់តែរឹងកាលណាវាមានកាបូនកាន់តែច្រើន។

-ដែកថែបពិសេស : ជាដែកថែបដែលមានលាយធាតុដទៃទៀតដូចជា **Mn Cr Ni Si C V W**...... ។

## II-បម្រើបម្រាស់លោហៈ

គេយកលោហៈទៅប្រើដើម្បីផលិតវត្ថុប្រើប្រាស់ផ្សេងៗ ដោយអាស្រ័យទៅនឹងលក្ខណៈរបស់វា។ ការជ្រើសរើសនេះផ្អែកលើកត្តាសំខាន់បីយ៉ាងគឺ

-លក្ខណៈរូបដូចជា ចំណុចរលាយ ចំណុចរំពុះ រឹង.....

-លក្ខណៈគីមីដូចជា ការធន់នឹងកំណូត

-តម្លៃ

## III-ការកែច្នៃឡើងវិញ

ការកែច្នៃឡើងវិញជាដំណើរការដែលសន្សំសំចៃថវិកាបានច្រើនជាងយោបកលោហៈពីរ៉ែ។

-គុណសម្បត្តិ : សន្សំសំចៃរ៉ែលោហៈ ថវិកា កាត់បន្ថយការបំពុលបរិស្ថាន។

-គុណវិបត្តិ : ជាមូលហេតុនៃការបំពុលបរិស្ថាន។

## ជំពូកទី៣ : អុកស៊ីតកម្ម រេដុកម្ម និងអេឡិចត្រូគីមី

## មេរៀនទី១ : ប្រតិកម្មអុកស៊ីតកម្ម-រេដុកម្មក្នុងសូលុយស្យុងទឹក

### I-ប្រតិកម្មអុកស៊ីដូរេដុកម្មក្នុងសូលុយស្យុងទឹក

**☞ ជាទូទៅ**

-អុកស៊ីតកម្មគឺជាលំនាំបោះបង់អេឡិចត្រុង ឬខាតអេឡិចត្រុង។

-រេដុកម្មគឺជាលំនាំចាប់យកអេឡិចត្រុង ឬចំណេញអេឡិចត្រុង។

-អុកស៊ីតករគឺជាប្រភេទគីមី (អាតូម ម៉ូលេគុល អ៊ីយ៉ុង) ដែលចាប់យកអេឡិចត្រុង។

-រេដុករគឺជាប្រភេទគីមី (អាតូម ម៉ូលេគុល អ៊ីយ៉ុង) ដែលបោះបង់អេឡិចត្រុង។

-ប្រតិកម្មដែលមានបញ្ជូន និងចាប់យកអេឡិចត្រុងប្រព្រឹត្តទៅព្រមគ្នាហៅថា ***ប្រតិកម្មអុកស៊ីដូរេដុកម្ម ឬប្រតិកម្មរេដុក***។

ឧទាហរណ៍ : ប្រតិកម្មរវាងស័ង្កសី ជាមួយសូលុយស្យុងទង់ដែងស៊ុលផាត។

សូលុយស្យុងទង់ដែងស៊ុលផាត : $CuSO_4 \rightarrow Cu^{2+}_{(aq)} + SO_4^{2-}_{(aq)}$

$$Zn_{(s)} + CuSO_{4(aq)} \rightarrow ZnSO_{4(aq)} + Cu_{(s)}$$

$$Zn_{(s)} + Cu^{2+}_{(aq)} + SO_4^{2-}_{(aq)} \rightarrow Zn^{2+}_{(aq)} + SO_4^{2-}_{(aq)} + Cu_{(s)}$$

$$Zn_{(s)} + Cu^{2+}_{(aq)} \rightarrow Zn^{2+}_{(aq)} + Cu_{(s)}$$

អុកស៊ីតកម្ម

អុកស៊ីតករ

សង្ខេប : $\mathbf{Zn_{(s)}} + \mathbf{Cu^{2+}_{(aq)}} \rightarrow \mathbf{Zn^{2+}_{(aq)}} + \mathbf{Cu_{(s)}}$

រេដុករ　　　　　　　　រេដុកម្ម



**ចំណាំ** -លោហៈ M រងអុកស៊ីតកម្មក្លាយជាអ៊ីយ៉ុង $M^{n+}$

$$M \xrightarrow{\text{អុកស៊ីតកម្ម}} M^{n+} + ne^-$$

-អ៊ីយ៉ុង $M^{n+}$ រងរេដុកម្មក្លាយជាលោហៈ M

$$M^{n+} + ne^- \xrightarrow{\text{រេដុកម្ម}} M$$

-លទ្ធផលទាំងពីរខាងលើអាចតាងដោយកន្សោម ***សមីការអេឡិចត្រុង ឬកន្សោមសមីការអេឡិចត្រូនិច***

$$M^{n+} + ne^- \rightleftharpoons M$$

-ដែលត្រូវនឹងគូ អុកស៊ីតករ / រេដុករ : $\mathbf{M^{n+}/M}$

| គូ $M^{n+}/M$ | កន្សោមសមីការអេឡិចត្រុង |
|---|---|
| $Al^{3+}/Al$ | $Al^{3+}_{(aq)} + 3e^- \rightleftharpoons Al_{(s)}$ |
| $Fe^{2+}/Fe$ | $Fe^{2+}_{(aq)} + 2e^- \rightleftharpoons Fe_{(s)}$ |
| $Pb^{2+}/Pb$ | $Pb^{2+}_{(aq)} + 2e^- \rightleftharpoons Pb_{(s)}$ |
| $Mg^{2+}/Mg$ | $Mg^{2+}_{(aq)} + 2e^- \rightleftharpoons Mg_{(s)}$ |
| $Ag^{+}/Ag$ | $Ag^{+}_{(aq)} + 1e^- \rightleftharpoons Ag_{(s)}$ |

## II. អំពើនៃសូលុយស្យុងអាស៊ីតលើលោហៈ

-សូលុយស្យុងអាស៊ីតមានអ៊ីយ៉ុង $H^+$ ឬអ៊ីយ៉ុងអ៊ីដ្រូញ៉ូម $H_3O^+$ ។

-សមីការបំបែកសូលុយស្យុងអាស៊ីត HA

$$HA \rightarrow H^+(aq) + A^{n-}(aq)$$

$$H^+(aq) + H_2O(aq) \rightarrow H_3O^+(aq)$$

ឧទាហរណ៍ : $HCl\,(g) \rightarrow H^+(aq) + Cl^-(aq)$

$H_2SO_4(l) \rightarrow 2H^+(aq) + SO_4^{2-}(aq)$

-អ៊ីយ៉ុង $H^+$ មានគូរេដុក $H^+/H_2$

-កន្លះសមីការអេឡិចត្រុង : $2H^+(aq) + 2e^- \rightleftarrows H_2(g)$

## III. គូរេដុក

ប្រតិកម្មអុកស៊ីដូរេដុកមួយដែលកើតឯងបានដោយគោរពតាមទិសដៅនៃវិធានកាម៉ា (γ) ដែលពោលថា " **អុកស៊ីតករខ្លាំងមានប្រតិកម្មជាមួយរេដុករខ្លាំងឱ្យផលជាអុកស៊ីតករខ្សោយ និងរេដុករខ្សោយ** "។

| អុកស៊ីតករខ្លាំង + រេដុករខ្លាំង → អុកស៊ីតករខ្សោយ + រេដុករខ្សោយ |
|---|




**ជាទូទៅ**

$$Ox_1 + Red_2 \rightarrow Ox_2 + Red_1$$

### * ចំណែកថ្នាក់អេឡិចត្រូគីមីនៃអ៊ីយ៉ុងលោហៈ/លោហៈ

អំណាចអុកស៊ីតករកើនឡើងពីក្រោមទៅលើ រីឯអំណាចរេដុករកើនឡើងពីលើទៅក្រោម ។



## មេរៀនទី២ : ប៉ូតង់ស្យែលអុកស៊ីដូរេដុកម្ម

### I_ប្រតិកម្មអុកស៊ីដូរេដុកម្មក្នុងថ្មពិល

### ១_ថ្មពិលស័ង្កសី/ទង់ដែង (ថ្មពិលដាញ៉ែល)




#### ក_ពណ៌នាថ្មពិល

-ថ្មពិលដាញ៉ែលត្រូវបានបង្កើតពីពាក់កណ្តាលពិលពីរគឺពាក់កណ្តាលពិល $Zn^{2+}/Zn$ : $Zn^{2+}(aq) + 2e^- \rightleftarrows Zn(s)$ និងពាក់កណ្តាលពិល $Cu^{2+}/Cu$ : $Cu^{2+}(aq) + 2e^- \rightleftarrows Cu(s)$ ។

-ស្ពានអំបិល ឬស្ពានអ៊ីយ៉ុង ឬស្ពានអេឡិចត្រូលីតធ្វើពីក្រដាសដែលត្រាំដោយសូលុយស្យុង KCl ឬ NaCl ឬ $NH_4NO_3$ វាមាននាទីសម្រាប់បិទសៀគ្វី និងធានាមិនឱ្យសូលុយស្យុងនៃពាក់កណ្តាលពិលនៅលាយឡំគ្នា ។

#### ខ_ដំណើរការថ្មពិលដាញ៉ែល




- លោហៈ Zn បានបោះបង់ $2e^-$ ក្លាយជា $Zn^{2+}$

  $Zn(s) \rightarrow Zn^{2+}(aq) + 2e^-$

- $Cu^{2+}$ ចាប់យក $2e^-$ ក្លាយជា Cu

  $Cu^{2+}(aq) + 2e^- \rightarrow Cu$

- សមីការតុល្យការ

$$\begin{array}{l} Zn(s) \rightarrow Zn^{2+}(aq) + 2e^- \\ Cu^{2+}(aq) + 2e^- \rightarrow Cu(s) \end{array} \Bigg| +$$

$$Zn(s) + Cu^{2+}(aq) \rightarrow Zn^{2+}(aq) + Cu(s)$$

- តាមការសន្មតថ្មពិលដាញ៉ែលមានតំនួសបំព្រួញដូចខាងក្រោម

  (-) Zn | $Zn^{2+}$ ¦¦ $Cu^{2+}$ | Cu (+)

- កម្លាំងអគ្គិសនីចលករប្រហែល $E_{Zn/Cu} = V_{Cu} - V_{Zn} = 1.10V$

### ២_ថ្មពិលផ្សេងទៀត




#### ក_ ថ្មពិល Zn / Ag

(-) Zn | $Zn^{2+}$ ¦¦ $Ag^+$ | Ag (+)

$E_{Zn/Ag} = V_{Ag} - V_{Zn} = 1.56V$

#### ខ_ ថ្មពិល Cu / Ag

(-) Cu | $Cu^{2+}$ ¦¦ $Ag^+$ | Ag (+)

$E_{Cu/Ag} = V_{Ag} - V_{Cu} = 0.46V$

#### សន្និដ្ឋាន

- ប៉ូល (+) នៃពិលធ្វើពីលោហៈដែលជារេដុករខ្សោយ ។

- ប៉ូល (-) នៃពិលធ្វើពីលោហៈដែលជារេដុករខ្លាំង ។
- កម្លាំងអគ្គិសនីចលករនៃថ្មពិលអាស្រ័យនឹងគូអ៊ីយ៉ុងលោហៈ ⁄ លោហៈ ដែលប្រើនិងកំហាប់អ៊ីយ៉ុងក្នុងសូលុយស្យុង ។

## II- ប៉ូតង់ស្យែលអុកស៊ីដូរេដុកម្មស្តង់ដា

### ១-សញ្ញាណអេឡិចត្រូតគោល

#### ក- អេឡិចត្រូតស្តង់ដាអ៊ីដ្រូសែន (ESH)




ESH = Electrode Standard Hydrogene ឬ SHE = Standard Hydrogen Electrode វាផ្សំដោយបន្ទះ Pt ត្រាំក្នុងសូលុយស្យុង HCl ដែលមានកំហាប់ 1 mol. $L^{-1}$ និងឱ្យចរន្តឧស្ម័ន $H_2$ ឆ្លងកាត់ ដែលមានសម្ពាធ P = 1atm ។

#### ខ- គូរេដុកនៃអេឡិចត្រូត ESH

គេតាង ESH ដោយ **Pt , $H_2$| $H^+$** វាមានគូរេដុក $H^+/H_2$ ដែលត្រូវនឹងកន្លះសមីការអេឡិចត្រូនិច

$2H^+$ (aq) + $2e^-$ $\rightleftharpoons$ $H_2$(g) តាមការសន្មតប៉ូតង់ស្យែលស្តង់ដារបស់ ESH គឺ $V_{ESH} = E°_{H^+/H_2} = 0V$ ។ គេប្រើ ESH ដើម្បីវាស់ប៉ូតង់ស្យែលនៃគូរេដុកដទៃទៀតដែលធៀបនឹងវា ។

តម្លៃប៉ូតង់ស្យែលរេដុកជាទំហំវិជ្ជមាន ឬអវិជ្ជមានប្រែប្រួលទៅតាមកំហាប់ $M^{n+}$ និងសីតុណ្ហភាពនៃសូលុយស្យុង ។

### ២-ប៉ូតង់ស្យែលស្តង់ដា E° របស់គូរេដុក $M^{n+}/M$ វាស់នៅសីតុណ្ហភាព 25°C

| Couple | E°(V) |
|---|---|
| $Au^{3+}$ / Au | 1.50 |
| $Pt^{2+}$ / Pt | 1.20 |
| $Pd^{2+}$ / Pd | 0.99 |
| $Ag^{+}$ / Ag | 0.80 |
| $Hg^{2+}$ / Hg | 0.79 |
| $Cu^{2+}$ / Cu | 0.34 |
| **$H^{+}$ / $H_2$** | **0.00** |
| $Pb^{2+}$ / Pb | -0.13 |
| $Sn^{2+}$ / Sn | -0.14 |
| $Ni^{2+}$ / Ni | -0.23 |
| $Fe^{2+}$ / Fe | -0.44 |
| $Zn^{2+}$ / Zn | -0.76 |
| $Al^{3+}$ / Al | -1.67 |




### ៣-ការប្រើប្រាស់ប៉ូតង់ស្យែលស្តង់ដា

-ប៉ូល (+) របស់ថ្មពិលជាអេឡិចត្រូតដែលមាន E° ធំ ឯប៉ូល (-) ជាអេឡិចត្រូតដែលមាន E°តូច ។

-កម្លាំងអគ្គិសនីចលករ E របស់ថ្មពិលអនុវត្តតាមរូបមន្ត $E = E°_1 - E°_2$ ឬ $E = E°_{(ប៉ូលបូក)} - E°_{(ប៉ូលដក)} > 0$

-កម្លាំងអគ្គិសនីចលករ E មានតម្លៃវិជ្ជមានជានិច្ច

-ប្រតិកម្មអាចសម្រេចទាំងស្រុងកាលណាផលសងប៉ូតង់ស្យែលស្តង់ដាធំជាង ឬស្មើនិង 0.3V ឬ ( $\Delta E° \geq 0.3V$) ។

## មេរៀនទី៣ : ចំនួនអុកស៊ីតកម្ម

### I- ចំនួនអុកស៊ីតកម្ម

#### ១_សញ្ញាណអេឡិចត្រូអវិជ្ជមាន

**ក_ ការសង្កេត**

-ធាតុខ្លះមានទំនោរចាប់យក $e^-$ ដើម្បីក្លាយជាអ៊ីយ៉ុងអវិជ្ជមាន ឬ អាញ៉ុង ។

ឧទាហរណ៍ : $F^-$ , $O^{2-}$ , $Cl^-$ , $S^{2-}$,.................. ។

-ធាតុខ្លះទៀតមានទំនោរបោះបង់ $e^-$ ដើម្បីក្លាយជាអ៊ីយ៉ុងវិជ្ជមាន ឬ កាចុង ។

ឧទាហរណ៍ : $Li^+$ , $Na^+$ , $Zn^{2+}$ , $Al^{3+}$,............... ។

គេថាធាតុដែលងាយចាប់យក $e^-$ វាមានអេឡិចត្រូអវិជ្ជមានខ្លាំង រីឯធាតុដែលងាយបោះបង់ $e^-$ វាមានអេឡិចត្រូអវិជ្ជមានខ្សោយ ។

**ខ_ និយមន័យ**

អេឡិចត្រូអវិជ្ជមាននៃធាតុមួយគឺជាសម្បទារបស់ធាតុនោះក្នុងការរក្សាអេឡិចត្រុងវ៉ាឡង់ (អេឡិចត្រុងស្រទាប់ក្រៅ) របស់វា ឬ ក្នុងទំនាញយកអេឡិចត្រុងវ៉ាឡង់នៃធាតុមួយទៀត ។ អេឡិចត្រុងអវិជ្ជមាននៃធាតុនីមួយៗតាងដោយអក្សរក្រិចគី **គី** ($\chi$) ។ អេឡិចត្រូអវិជ្ជមានមានតម្លៃវិជ្ជមានជានិច្ច ។

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| H 2.2 | | | | | | | | | | | | | | | | | He |
| Li 1.0 | Be 1.6 | | | | | | | | | | | B 2.0 | C 2.5 | N 3.0 | O 3.5 | F 4.0 | Ne |
| Na 0.9 | Mg 1.3 | | | | | | | | | | | Al 1.6 | Si 1.9 | P 2.2 | S 2.6 | Cl 3.2 | Ar |
| K 0.8 | Ca 1.0 | Sc 1.4 | Ti 1.5 | V 1.6 | Cr 1.7 | Mn 1.6 | Fe 1.8 | Co 1.9 | Ni 1.9 | Cu 2.0 | Zn 1.7 | Ga 1.8 | Ge 2.0 | As 2.2 | Se 2.6 | Br 3.0 | Kr |
| Rb 0.8 | Sr 1.0 | Y 1.2 | Zr 1.3 | Nb 1.6 | Mo 2.2 | Tc 1.9 | Ru 2.2 | Rh 2.3 | Pd 2.2 | Ag 1.9 | Cd 1.7 | In 1.8 | Sn 1.8 | Sb 2.1 | Te 2.1 | I 2.7 | Xe |
| Cs 0.8 | Ba 0.9 | La 1.1 | Hf 1.3 | Ta 1.5 | W 2.4 | Re 1.9 | Os 2.2 | Ir 2.2 | Pt 2.3 | Au 2.5 | Hg 2.0 | Tl 2.0 | Pb 1.9 | Bi 2.0 | Po 2.0 | At 2.2 | Rn |

$\chi$

**គ_ប៉ូលកម្មនៃសម្ព័ន្ធនិងអេឡិចត្រូអវិជ្ជមាន**

តាងអាតូម A និង B ដែលមានអេឡិចត្រូអវិជ្ជមាន $\chi_A$ និង $\chi_B$ ចងសម្ព័ន្ធនិងគ្នាដូចរូបខាងក្រោម :

| | | |
|---|---|---|
| បើ $\chi_A = \chi_B$ គេបាន A —— B<br>$\chi_A = \chi_B$ | ប៉ុន្តែ | បើ $\chi_A > \chi_B$ គេបាន $A^{\delta-}$ ←—— $B^{\delta+}$<br>$\chi_A > \chi_B$ |

គេបានលក្ខខណ្ឌ : បើ $|\chi_A - \chi_B| \leq 0.5$ សម្ព័ន្ធនោះជា *សម្ព័ន្ធកូវ៉ាឡង់មិនប៉ូលែ* ។

បើ $|\chi_A - \chi_B| > 1.8$ សម្ព័ន្ធនោះជា *សម្ព័ន្ធអ៊ីយ៉ុនិច* ។

បើ $0.5 < |\chi_A - \chi_B| \leq 1.8$ សម្ព័ន្ធនោះជា *សម្ព័ន្ធកូវ៉ាឡង់ប៉ូលែ* ។

ឧទាហរណ៍ : ចូរប្រាប់ប្រភេទសម្ព័ន្ធដែលមាននៅក្នុងសមាសធាតុខាងក្រោម :

NaCl.................................................................................................................................

HCl..................................................................................................................................

$CH_4$……………………………………………………………………………………………………………………

## ២-ចំនួនអុកស៊ីតកម្មនៃធាតុ

ចំនួនអុកស៊ីតកម្មនៃធាតុនៅក្នុងប្រភេទគីមីគឺជាចំនួនគត់ពិជគណិតដែលសម្គាល់ដោយលេខរ៉ូម៉ាំង។ ចំនួនអុកស៊ីតកម្មតាងដោយ n.o ។

### ក-អ៊ីយ៉ុងម៉ូណូអាតូម

ចំនួនអុកស៊ីតកម្មនៃធាតុក្នុងអ៊ីយ៉ុងម៉ូណូអាតូមស្មើនឹងបន្ទុកអគ្គិសនីនៃអ៊ីយ៉ុងនោះ (រង្វាស់បន្ទុកដំបូង)។

ឧទាហរណ៍ : $Na^+$: n.o (Na) = +I , $Cu^{2+}$ : n.o (Cu) =…………

$Cl^-$ : n.o (Cl) = -I, $O^{2-}$ : n.o (O) =…………..

### ខ-បណ្ដុំម៉ូលីអាតូម

-ចំនួនអុកស៊ីតកម្មអង្គធាតុទោលស្មើនឹងសូន្យជានិច្ច។

ឧទាហរណ៍ : Na : n.o (Na) = 0 , Cu : n.o (Cu) =……………

$Cl_2$ : n.o (Cl) = 0 , $O_2$ : n.o (O) = …………...

-ផលបូកចំនួនអុកស៊ីតកម្ម ($\Sigma$ n.o) ក្នុងម៉ូលេគុលស្មើនឹងសូន្យ។

ឧទាហរណ៍ : HCl : n.o (H) + n.o (Cl) = 0 ⇔ (+I) + (-I) = 0

$H_2O$ : ……………………………………………………………………………………………………

-ផលបូកចំនួនអុកស៊ីតកម្ម ($\Sigma$ n.o) នៃគ្រប់ធាតុដែលបង្កអ៊ីយ៉ុងប៉ូលីអាតូមស្មើនឹងចំនួនបន្ទុករបស់អ៊ីយ៉ុងនោះ។

ឧទាហរណ៍ : $SO_4^{2-}$ : n.o (S) + n.o (O) x 4 = -2 ⇔ (+VI) + (-II) × 4 = -2

**<u>ចំណាំ</u>** :

-ចំនួនអុកស៊ីតកម្មរបស់អ៊ីដ្រូសែនក្នុងសមាសធាតុវាស្មើនឹង +I ជានិច្ច លើកលែងតែក្នុងសមាសធាតុអ៊ីដ្រូដែលចំនួនអុកស៊ីតកម្មរបស់អ៊ីដ្រូសែនស្មើនឹង –I ។ ឧទាហរណ៍ : NaH , LiH , KH,……… ។

-ចំនួនអុកស៊ីតកម្មរបស់អុកស៊ីសែនក្នុងសមាសធាតុវាស្មើនឹង –II ជានិច្ច លើកលែងតែក្នុងសមាសធាតុពែរអុកស៊ីតដែលចំនួនអុកស៊ីតកម្មរបស់អុកស៊ីសែនស្មើនឹង –I ។ ឧទាហរណ៍ : $Na_2O_2$, $H_2O_2$ ,…………… ។

## II- បម្រើបម្រាស់ចំនួនអុកស៊ីតកម្ម

-ធាតុគីមីមួយរងអុកស៊ីតកម្មកាលណា n.o នៃធាតុនោះកើនឡើង។

-ធាតុគីមីមួយរងរេដុកម្មកាលណា n.o នៃធាតុនោះថយចុះ។

-អុកស៊ីតករជាប្រភេទគីមីដែលក្នុងនោះមានធាតុណាមួយថយចំនួនអុកស៊ីកម្ម។

-រេដុករជាប្រភេទគីមីដែលក្នុងនោះមានធាតុណាមួយកើនចំនួនអុកស៊ីតកម្ម។

-នៅក្នុងប្រតិកម្មអុកស៊ីដូរេដុកម្មផលបូកបម្រែបម្រួល n.o របស់អុកស៊ីករនិងរេដុករស្មើសូន្យ។

### ១-ថ្លឹងប្រតិកម្មអុកស៊ីដូរេដុកម្មតាមផ្លូវស្វ័ត

- ដាក់ n.o នៅលើធាតុណាដែលមាន n.o ប្រែប្រួល
- សរសេរពាក់កណ្ដាលសមីការអេឡិចត្រុង
- អនុវត្តតាមគោលការណ៍ ចំនួន $e^-$ បោះបង់ = ចំនួន $e^-$ ទទួលយក
- ថ្លឹងសម្រេច។

ដើម្បីថ្លឹងសមីការតុល្យការប្រតិកម្មរេដុក គេត្រូវរកមេគុណ a និង b ក្នុងទំនាក់ទំនងខាងក្រោម

$$a \times \Delta n.o\ (\text{រេដុករ}) + b \times \Delta n.o\ (\text{អុកស៊ីតករ}) = 0$$

## ២-ថ្លឹងប្រតិកម្មអុកស៊ីដូរេដុកម្មក្នុងសូលុយស្យុងទឹក

### * របៀបថ្លឹងកន្លះសមីការអេឡិចត្រុងនៃគូរេដុក

### -ថ្លឹងចំនួនអាតូមនាំងឡាយនៅអង្គសងខាងឱ្យស្មើគ្នា

#### ក-ក្នុងមជ្ឈដ្ឋានអាស៊ីត

-អង្គដែលមានអុកស៊ីសែនតិច ត្រូវថែម $H_2O$

-អង្គដែលមានអុកស៊ីសែនច្រើន ត្រូវថែម $H^+$

- $e^-$ ត្រូវថែមខាងអង្គដែលមានបន្ទុកសរុបខ្ពស់ជាង ឬ ខាងអង្គសណ្ឋានជាអុកស៊ីករ ។

#### ខ-ក្នុងមជ្ឈដ្ឋានបាស

-អង្គដែលមានអុកស៊ីសែនតិច ត្រូវថែម $H_2O$

-អង្គដែលមានអុកស៊ីសែនច្រើន ត្រូវថែម $H^+$

-បំប្លែង $H^+$ ឱ្យទៅជា $H_2O$ ដោយថែម $OH^-$ ទៅឱ្យអង្គទាំងសងខាង ។

- $e^-$ ត្រូវថែមខាងអង្គដែលមានបន្ទុកសរុបខ្ពស់ជាង ឬ ខាងអង្គសណ្ឋានជាអុកស៊ីករ ។

### -ថ្លឹងសមីការតុល្យការ

ដើម្បីបានសមីការតុល្យការនៃប្រតិកម្មរេដុក គេត្រូវបូកកន្លះសមីការអេឡិចត្រុងនៃគូរេដុកទាំងពីរដែលធ្វើប្រតិកម្មនឹងគ្នា ដោយលៃយ៉ាងណាឱ្យចំនួន $e^-$ បោះបង់ = ចំនួន $e^-$ ទទួលយក ។

## មេរៀនទី៤ : ថ្មពិលអេឡិចត្រូគីមី

ថ្មពិលជាជនិតាចរន្តជាប់ដែលវាបំលែងថាមពលគីមីទៅជាថាមពលអគ្គិសនី ។

### I-ថ្មពិលអំបិល ឬថ្មពិលឡឺក្លង់សេ




#### ក-ពណ៌នាអំពីថ្មពិល

- គូអុកស៊ីតករ-រេដុករដែលចូលរួមប្រតិកម្មក្នុងថ្មពិលអំបិលគឺ : $Zn^{2+}/Zn$ និង $MnO_2/MnO(OH)$ ។
- ប៉ូលអវិជ្ជមានឬអាណូត ធ្វើពី Zn ដែលមាននាទីជាប្រអប់ថ្មពិល អង្គធាតុប្រតិករនិងជាអង្គធាតុចម្លងអគ្គិសនី ។
- ប៉ូលវិជ្ជមានឬកាតូតធ្វើពី ក្រាភីតដែលត្រាំក្នុងល្បាយ $MnO_2$ ម្សៅកាបូន ។ ល្បាយនេះភ្ជាប់ដោយសូលុយស្យុងកកនៃ $NH_4Cl$ ។
- អេឡិចត្រូលីតជាសូ. $NH_4Cl$ ហេតុនេះហើយបានជាគេឱ្យឈ្មោះថាថ្មពិលអំបិល ឬ ថ្មពិលស្ងួត ។ សូលុយស្យុង $NH_4Cl$ មានលក្ខណៈជាអាស៊ីត ។




#### ខ-គូអុកស៊ីតករ-រេដុករ

គូរេដុកដែលចូលរួមមានពីរគឺ $MnO_2/MnO(OH)$ មាន $E° = 1.01V$ និង $Zn^{2+}/Zn$ មាន ។

កម្លាំងអគ្គិសនីចលករស្តង់ដា (25 °C , 1atm )របស់ថ្មពិលគឺ $E = (+1.01V) – (-0.76V) = 1.77V$ ។ ប៉ុន្តែក្នុងការអនុវត្តគេមិនអាចធ្វើថ្មពិលឡឺក្លង់សេនៅក្នុងលក្ខខណ្ឌស្តង់ដាបានទេ ។ ដូចនេះកម្លាំងអគ្គិសនីចលកររបស់វាមានត្រឹមតែ $E = 1.5V$ទេ ។

តំនួសតាង ឬសញ្ញាណសន្ទត : **(-) Zn | $Zn^{2+}$ | $NH_4Cl$ , $Mn_2O_3$ , $H_2O$ | $MnO_2$ , C (+)**

#### គ-សមីការតុល្យការ

- ប៉ូល (+) ឬកាតូត ជាកន្លែងរេដុកម្ម ។

$MnO_2 + H^+ + e^- \longrightarrow MnO(OH)$ ឬ $Mn_2O_3 , H_2O$

- ប៉ូល (-) ឬ អាណូត ជាកន្លែងអុកស៊ីតកម្ម ។

$Zn \longrightarrow Zn^{2+} + 2e^-$

សមីការតុល្យការប្រតិកម្មនៅពេលថ្មពិលដំណើរការគឺ

$Zn + 2MnO_2 + 2H^+ \longrightarrow Zn^{2+} + 2MnO(OH)$

*ថ្មពិលអេឡិចត្រូគីមីប្លែងថាមពលគីមីទៅជាថាមពលអគ្គិសនី ។*




សំគាល់: Zn អាចមានអំពើជាមួយ $H^+$ នៃអេឡិចត្រូលីតតាមសមីការតុល្យការ $Zn + 2H^+ \longrightarrow Zn^{2+} + H_2$ ។

ប្រតិកម្មនេះមានផលប៉ះពាល់ដល់ថ្មពិលពីរយ៉ាងគឺ :

- អង្គធាតុប្រតិករឆាប់អស់ និងថយបរិមាណអគ្គិសនីថ្មពិល ។
- ប្រអប់ថ្មពិលធ្លុះធ្លាយដោយសារសម្ពាធ ឧស្ម័ន $H_2$ កើនឡើង ។

គេអាចបន្ថយល្បឿនប្រតិកម្មនេះឱ្យយឺតបំផុត ដោយប្រើសង្កសីអាម៉ាល់កាម ( សំលោហៈសង្កសីបារត) ប៉ុន្តែបារត (Hg) ជាលោហៈដែលពុលវិធីនេះត្រូវគេបោះបង់ចោល ហើយជំនួសដោយសមាសធាតុសរីរាង្គវិញ ។

ម្យ៉ាងទៀតក្នុងការអនុវត្តគេប្រើ $MnO_2$ ឱ្យខ្លះដើម្បីជៀសវាងការធ្លុះធ្លាយប្រអប់ថ្មពិលដែលធ្វើពី Zn ក្នុងពេលវាដំណើរការ ។

## II-ថ្មពិលអាល់កាឡាំង

### ក-ថ្មពិលម៉ាឡូរី

គូរេដុកដែលប្រើក្នុងថ្មពិលម៉ាឡូរី $Zn(OH)_4^{2+}$ / Zn មាន E° = -1.20V និង $MnO_2$ / MnO(OH) មាន E° = 1.01V ។ អេឡិចត្រូលីតជាសូ.បាស KOH ដែលមាន កំហាប់ 40% និងជាសូលុយស្យុងកក ។ កម្លាំងអគ្គិសនីចលករនៃថ្មពិលគឺ E = 1.5V ។

គំនូសតាង ឬសញ្ញាណសន្មត : **(-) Zn | $Zn(OH)_4^{2-}$ || KOH || MnO(OH) | $MnO_2$ (+)**

ប្រតិកម្មនៅលើអេឡិចត្រូតពេលថ្មពិលដំណើរការ

ប៉ូល (+) : $MnO_2 + H_2O + e^- \longrightarrow MnO(OH) + OH^-$ (×2)

ប៉ូល (-) : $Zn + 4OH^- \longrightarrow Zn(OH)_4^{2-} + 2e^-$

តុល្យការ : $Zn + 2MnO_2 + 2OH^- + 2H_2O \longrightarrow Zn(OH)_4^{2-} + 2MnO(OH)$

### ខ-ថ្មពិលប្រាក់អុកស៊ីត

គូរេដុកដែលប្រើក្នុងថ្មពិលប្រាក់អុកស៊ីត $Ag_2O$ / Ag មាន E° = 0.34V និង $Zn(OH)_4^{2-}$ / Zn មាន E° = -1.20V ។ ថ្មពិលនេះប្រើជាថ្មពិលឡេវអាវ ។ កម្លាំងអគ្គិសនីចលករស្តង់ដារបស់វាគឺ E = 1.54V ហើយថេរនៅពេលវាដំណើរការ ។

គំនូសតាង ឬសញ្ញាណសន្មត : **(-) Zn | $Zn(OH)_4^{2-}$ || KOH || Ag | $Ag_2O$ (+)**




ប្រតិកម្មនៅលើអេឡិចត្រូតពេលថ្មពិលដំណើរការ

ប៉ូល (+) : $Ag_2O + H_2O + 2e^- \longrightarrow 2Ag + 2OH^-$

ប៉ូល (-) : $Zn + 4OH^- \longrightarrow Zn(OH)_4^{2-} + 2e^-$

តុល្យការ : $Zn + Ag_2O + 2OH^- + H_2O \longrightarrow Zn(OH)_4^{2-} + 2Ag$

## III-អាគុយ

អាគុយជាជនិតាអេឡិចត្រូគីមី វាមានដំណើរការដូចថ្មពិលនៅពេលវាផ្ទេរ និងមានដំណើរការជាគ្រឿងទទួលអគ្គិសនីនៅពេលវាផ្ទុក ។



### ១-អាគុយសំណ

#### ក-ពណ៌នាអាគុយ

-អេឡិចត្រូលីតក្នុងអាគុយសំណជាសូ. $H_2SO_4$ ដែលមានកំហាប់ $6mol.L^{-1}$ ។ អេឡិចត្រូត ឬ ផ្ទាំកជាសំណាញ់ធ្វើពី Pb ដែលមានចន្លោះប្រហោងសម្រាប់បំពេញអង្គធាតុរឹងទម្រង់ជាម្សៅប្រាយ ។ $PbO_2$ សម្រាប់ផ្ទាំកវិជ្ជមាន និង Pb ស្ពោត សម្រាប់ផ្ទាំក អវិជ្ជមាន ។ ផ្ទាំកទាំងពីរប្រភេទនេះតម្រៀបឆ្លាស់គ្នា និងខណ្ឌដោយភ្នាស ។ ផ្ទាំកដែលមានធម្មជាតិដូចគ្នាគេភ្ជាប់គ្នាបង្កើតជា ប៉ូលបូក និង ប៉ូលដក នៃអាគុយ ។

-គូរេដុកដែលប្រើក្នុងអាគុយមាន $PbO_2$ / Pb មាន E° = 1.69V និង $Pb^{2+}$ / Pb មាន E° = -0.36V ។

-អាគុយសំណមានកម្លាំងអគ្គិសនីចលករ E = 2.05V ។

គំនូសតាង ឬសញ្ញាណសន្មត : **(-) Pb | $PbSO_4$ || $H_2SO_4$ || $PbSO_4$ | $PbO_2$ (+)**

**១-ដំណើរការរបស់អាគុយ**

**-ដំណើរការជាជនិតា ឬបន្ទេរអាគុយ**

នៅពេលអាគុយផ្ទេរ កំហាប់អាស៊ីត $H_2SO_4$ ថយចុះ និងផ្លាកអាគុយរុំពទ័ដោយ $PbSO_4$ នាំឱ្យអានុភាពអាគុយថយចុះ។ គេត្រូវផ្ទុកវាឡើងវិញមុនពេលវាផ្ទេរអស់ទាំងស្រុង។ ពេលអាគុយផ្ទេរថាមពលគីមីប្លែងជាថាមពលអគ្គិសនី។

ផ្លាកវិជ្ជមាន (+) : $PbO_2 + 4H^+ + 2e^- \longrightarrow Pb^{2+} + 2H_2O$

ផ្លាកអវិជ្ជមាន (-) : $Pb \longrightarrow Pb^{2+} + 2e^-$

---

សមីការតុល្យការ : $Pb + PbO_2 + 4H^+ \longrightarrow 2Pb^{2+} + 2H_2O$

**-ដំណើរការជាគ្រឿងទទួល ឬបន្ទុកអាគុយ**

ប្រតិកម្មនៅពេលផ្ទុកនេះជាប្រតិកម្មច្រាស់ពីប្រតិកម្មដែលកើតឡើងនៅពេលអាគុយផ្ទេរ។ ដូចនេះពេលបន្ទុកអាគុយថាមពលអគ្គិសនីបានប្លែងជាថាមពលគីមី។

ប៉ូល (+) : $Pb^{2+} + 2H_2O \longrightarrow PbO_2 + 4H^+ + 2e^-$

ប៉ូល (-) : $Pb^{2+} + 2e^- \longrightarrow Pb$

---

$2Pb^{2+} + 2H_2O \longrightarrow Pb + PbO_2 + 4H^+$

**គ-សន្និដ្ឋាន**

អាគុយបំប្លែងថាមពលគីមីជាថាមពលអគ្គិសនីពេលផ្ទេរ និងបំប្លែងថាមពលអគ្គិសនីជាថាមពលគីមីពេលផ្ទុក។

$$Pb + PbO_2 + 4H^+ \underset{\text{ផ្ទុក}}{\overset{\text{ផ្ទេរ}}{\rightleftharpoons}} 2Pb^{2+} + 2H_2O$$

**២-អាគុយកាត់ម្ញូម-នីកែល**

គូរេដុកដែលប្រើក្នុងអាគុយកាត់ម្ញូម-នីកែល $NiO(OH) / Ni(OH)_2$ មាន $E° = 0.49V$ និង $Cd(OH)_2 / Cd$ $E° = -0.81V$។ អេឡិចត្រូលីតជាសូ. KOH កំហាប់ 40%។ កម្លាំងអគ្គិសនីចលករស្តង់ដារតាមទ្រឹស្តី $E = 1.30V$ ប៉ុន្តែពេលវា ដំណើរការជាជនិតាវាមានកម្លាំងអគ្គិសនីចលករប្រហែល $E = 1.20V$ ប៉ុណ្ណោះ។

គំនូសតាង ឬសញ្ញាណសន្មត : **(-) Cd | $Cd(OH)_2$ || KOH || $Ni(OH)_2$| NiO(OH) (+)**

ផ្លាក (+) : $NiO(OH) + H_2O + e^- \longrightarrow Ni(OH)_2 + OH^-$

ផ្លាក (-) : $Cd + 2OH^- \longrightarrow Cd(OH)_2 + 2e^-$

នៅពេលវាផ្ទុក ទិសដៅប្រតិកម្មច្រាស់ នឹងប្រតិកម្មនៅពេលវាផ្ទេរ។

$$Cd + 2NiO(OH) + 2H_2O \underset{\text{ផ្ទុក}}{\overset{\text{ផ្ទេរ}}{\rightleftharpoons}} Cd(OH)_2 + 2Ni(OH)_2$$

សព្វថ្ងៃនេះអាគុយបែបនេះត្រូវបានគេប្រើក្នុងរថយន្តដើរដោយថាមពលអគ្គិសនី កុំព្យូទ័រយួរដៃ វិទ្យុ ទូរស័ព្ទ........។

# មេរៀនទី៤ : អគ្គិសនីវិភាគ ( Electrolysis )

អគ្គិសនីវិភាគជាភាសាក្រិច ( អេឡិចត្រូ + លុយស៊ីស ) មានន័យថាបំបែកសមាសធាតុដោយសារចរន្តអគ្គិសនី ។

## I .អគ្គិសនីវិភាគសមាសធាតុអ៊ីយ៉ុងរលាយដោយកម្ដៅ

ក្រោមសូដ្យូមក្លរួ **NaCl** មិនចម្លងចរន្តអគ្គិសនីទេ ។ វារលាយនៅសីតុណ្ហភាព 801 ℃ ។ ពេលរលាយវាបំបែកជាអ៊ីយ៉ុង $Na^+$ និង $Cl^-$ ដែលអាចធ្វើចលនាដោយសេរី ។

**នៅកាតូត** $Na^+$ ទទួលយកអេឡិចត្រុងពីអេឡិចត្រូត ហើយក្លាយជាអាតូមសូដ្យូម ដោយវារងរេដុកម្ម ។

$$2\,Na^+ + 2e^- \longrightarrow 2Na$$

**នៅអាណូត** $Cl^-$ បោះបង់អេឡិចត្រុងឱ្យទៅអេឡិចត្រូត ហើយក្លាយជាម៉ូលេគុលក្លរ ដោយវារងអុកស៊ីតកម្ម ។

$$2\,Cl^- \longrightarrow Cl_2 + 2e^-$$

**សមីការតុល្យការប្រតិកម្មពេលអគ្គិសនីវិភាគ**

$$2NaCl \longrightarrow 2Na + Cl_2$$

ក្នុងពេលធ្វើអគ្គិសនីវិភាគបរិមាណអេឡិចត្រុងដែលផ្ទេរនៅអាណូត និងនៅកាតូតមានបរិមាណស្មើគ្នា ។

*តារាងអគ្គិសនីវិភាគសមាសធាតុអ៊ីយ៉ុងរលាយដោយកម្ដៅមួយចំនួន គេទទួលបានលោហៈនៅខាងកាតូត និងអលោហៈខាងអាណូត ។*

| អេឡិចត្រូលីតរលាយ | ផលិតផលនៅកាតូត | ផលិតផលនៅអាណូត |
|---|---|---|
| កាល់ស្យូមក្លរួ ($CaCl_2$) | កាល់ស្យូម (**Ca**) | ក្លរ ($Cl_2$) |
| សូដ្យូមអ៊ីយ៉ូឌួ (**NaI**) | សូដ្យូម (**Na**) | អ៊ីយ៉ូត ($I_2$) |
| សំណអុកស៊ីត (**PbO**) | សំណ (**Pb**) | អុកស៊ីសែន ($O_2$) |

## II. អគ្គិសនីវិភាគសូលុយស្យុងទង់ដែងប្រូមួ ($CuBr_2$)




ប្រតិកម្មដែលកើតឡើងនៅអេឡិចត្រូតតាងដោយសមីការតុល្យការ :

នៅអាណូតអ៊ីយ៉ុងប្រូមួ $Br^-$ រងអុកស៊ីតកម្ម : $2Br^- \longrightarrow Br_2 + 2e^-$

នៅកាតូតអ៊ីយ៉ុងទង់ដែង (**II**) $Cu^{2+}$ រងរេដុកម្ម : $Cu^{2+} + 2e^- \longrightarrow Cu$

សមីការតុល្យការប្រតិកម្ម : $Cu^{2+} + 2Br^- \longrightarrow Br_2 + Cu$ (1)

ប្រតិកម្ម (1) ដែលកើតឡើងក្នុងពេលធ្វើអគ្គិសនីវិភាគនេះច្រាសនឹងប្រតិកម្មអុកស៊ីដូរេដុកម្មកើតឯង : $Br_2 + Cu \longrightarrow Cu^{2+} + 2Br^-$

***សង្កេត*** ក្នុងសូលុយស្យុងទង់ដែងប្រូមួមានប្រភេទគីមី $Cu^{2+}$, $Br^-$ និង $H_2O$ ។តាមចំណែកថ្នាក់ប៉ូតង់ស្យែលស្តង់ដានៃគូរេដុក :

- អ៊ីយ៉ុង $Br^-$ ជារេដុករខ្លាំងជាង $H_2O$ ដូចនេះអ៊ីយ៉ុង $Br^-$ រងអុកស៊ីតកម្មនៅអាណូតមុន $H_2O$ ។
- អ៊ីយ៉ុង $Cu^{2+}$ ជាអុកស៊ីតករខ្លាំងជាង $H_2O$ ដូចនេះអ៊ីយ៉ុង $Cu^{2+}$ រងរេដុកម្មនៅកាតូតមុន $H_2O$ ។

ផលសងប៉ូតង់ស្យែលស្តង់ដា $\Delta E^\circ$ នៃគូរេដុកដែលចូលរួមប្រតិកម្ម :

$$\Delta E^\circ = E^\circ(Br_2 / Br^-) - E^\circ(Cu^{2+} / Cu) = 1.08V - 0.34V = 0.74V$$

**សំគាល់ : អេឡិចត្រូតធ្វើពីក្រាភីត ឬ ប្លាទីន ជាអេឡិចត្រូតមិនរងកំណត់តែវាចម្លងចរន្តអគ្គិសនីបានល្អ ។**

## III. អគ្គិសនីវិភាគទឹក ($H_2O$)

### ១.ពិសោធន៍

ទឹកសុទ្ធចម្លងអគ្គិសនីអន់បំផុត ដើម្បីធ្វើអគ្គិសនីវិភាគទឹក គេបន្ថែមអេឡិចត្រូលីតដែលមានអ៊ីយ៉ុងមិនរំខានដល់ប្រតិកម្មនៅអេឡិចត្រូតជើងវិភាគ ។ ពេលនេះគេប្រើសូលុយស្យុងអាស៊ីតស៊ុលផួរិចដែលមានកំហាប់ $1\ mol.L^{-1}$ ។

គេប្រែប្រួលតង់ស្យុងដែលភ្ជាប់នឹងអេឡិចត្រូតទាំងពីរ :

-បើតង់ស្យុង $U < 2V$ គេពុំឃើញមានឧស្ម័នភាយនៅអេឡិចត្រូតទេ ។

-បើតង់ស្យុង $U \geq 2V$ គេឃើញមានឧស្ម័នភាយនៅអេឡិចត្រូត ។ តាមអត្តសញ្ញាណបង្ហាញថាឧស្ម័នភាយខាងកាតូតជា $H_2$ និង ខាងអាណូតជា $O_2$ ។ **មាឌ $H_2$ មានពីរដង នៃមាឌឧស្ម័ន $O_2$** ។

### ២.បំណកស្រាយ

នៅខាងអាណូតទឹករងអុកស៊ីតកម្ម ប្រែងជា $O_2$តាមកន្លះសមីការអេឡិចត្រុង : $2H_2O \longrightarrow O_2 + 4H^+ + 4e^-$

នៅខាងកាតូត $H^+$ រងរេដុកម្ម ប្រែងជា $H_2$ តាមកន្លះសមីការអេឡិចត្រុង : $4H^+ + 4e^- \longrightarrow 2H_2$

សមីការតុល្យការប្រតិកម្មនៃអគ្គិសនីវិភាគទឹក : $2H_2O \longrightarrow 2H_2 + O_2$

ប្រតិកម្មគីមីនេះច្រាស់នឹងប្រតិកម្មសំយោគទឹកដែលជាប្រតិកម្មអុកស៊ីដូរេដុកម្មកើតឯង $2H_2 + O_2 \longrightarrow 2H_2O$ *ប្រតិកម្មក្នុងអគ្គិសនីវិភាគជាប្រតិកម្មបង្ខំ*។

### ៣.បាតុភូតតង់ស្យុងលើស




គេបានគិតថាអគ្គិសនីវិភាគសូ.$H_2SO_4$ នឹងចាប់ផ្ដើមនៅពេលតង់ស្យុង :

$$U = \Delta E^\circ = E^\circ(O_2/H_2O) - E^\circ(H^+/H_2) = 1.23V - 0.00V = 1.23V$$

តែតាមពិសោធន៍គេពុំបានឃើញមានបាតុភូតអគ្គិសនីវិភាគកើតឡើងទេ។ បើគេឱ្យ $U > 1.23V$បន្តិចបន្តួចប្រតិកម្មប្រព្រឹត្តទៅយឺតណាស់ដែលគេមិនអាចមើលឃើញ ។ គេអាចសង្កេតឃើញបាតុភូតអគ្គិសនីវិភាគនៅពេល $U \geq 2V$ ។

**ផលសងរវាងតម្លៃតាមការពិសោធន៍ និងទ្រឹស្តីគេហៅថាតង់ស្យុងលើស u ដែល :**

$$u = U - \Delta E^\circ = 2V - 1.23V \approx 0.8V$$

***សំគាល់*** : -អ៊ីយ៉ុង $SO_4^{2-}$ នៃគូ $S_2O_8^{2-}/SO_4^{2-}$ ជារេដុករខ្សោយជាង $H_2O$ នៃគូ $O_2/H_2O$ ដូច្នេះ $H_2O$ ត្រូវរងអុកស៊ីតកម្មមុន ។

-អ៊ីយ៉ុង $SO_4^{2-}$ នៃគូ $SO_4^{2-}/SO_2$ ជាអុកស៊ីតករខ្លាំងជាងអ៊ីយ៉ុង $H^+$ នៃគូ $H^+/H_2$ ។ តែអ៊ីយ៉ុង $H^+$ រងរេដុកម្មនៅខាងកាតូតមុនដោយសារតែអ៊ីយ៉ុង $SO_4^{2-}$ មានបន្ទុកអវិជ្ជមានវាផ្លាស់ទីទៅខាងកាតូតដោយពិបាក ។

-ការមិនចូលរួមប្រតិកម្មនៃអ៊ីយ៉ុង $SO_4^{2-}$ ក្នុងអគ្គិសនីវិភាគនេះក៏បណ្ដាលមកពីមានបាតុភូតតង់ស្យុងលើសផងដែរ ។

## IV. អគ្គិសនីវិភាគសូលុយស្យុងសំណប៉ាហាំងក្លរួ ($SnCl_2$)

កាលណាតង់ស្យុងនៅអេឡិចត្រូតតូចជាង **1.4V** គេពុំឃើញមានចរន្តឆ្លងកាត់ជើងវិភាគ ប៉ុន្តែចាប់ពីតង់ស្យុង **1.7V** ទៅ គេសង្កេតឃើញមានកំណកលោហៈសំណប៉ាហាំងនៅខាងកាតូត និងឧស្ម័នក្លរនៅខាងអាណូត ។

*ម្យ៉ាងទៀតបើតង់ស្យុងធំជាង **2V** គេ សង្កេតឃើញនៅកាតូតមានភាយឧស្ម័ន $H_2$ និងនៅអាណូតមានភាយឧស្ម័ន $O_2$ ថែមទៀត ។*

**បំណកស្រាយ :**




កាតូត : $Sn^{2+} + 2e^- \longrightarrow Sn$ អាណូត : $2Cl^- \longrightarrow Cl_2 + 2e^-$

សមីការតុល្យការប្រតិកម្មពេលធ្វើអគ្គិសនីវិភាគ : $Sn^{2+} + 2Cl^- \longrightarrow Sn + Cl_2$

តាមចំណែកថ្នាក់នៃគូរេដុក $H_2O$ ត្រូវរងអុកស៊ីតកម្ម និង $H_2O$ រងរេដុកម្មមុន។ តាមពិសោធន៍បង្ហាញថាការបំភាយឧស្ម័នក្លរ និង កំណសំណប៉ាហាំងត្រូវការតង់ស្យុងលើស :

$$u = U - (E^\circ Cl_2/Cl^- - E^\circ Sn^{2+}/Sn)$$
$$= 1.7V - (1.36V + 0.14V)$$
$$= 0.2V$$

ចំណែកការបំភាយ $H_2$ និង $O_2$ ត្រូវការតង់ស្យុងលើសរហូតដល់ 0.8V ។ ប៉ុន្តែតង់ស្យុងស្តង់ដានៃគូរេដុកនៅតែមានសារសំខាន់ ក៏ប៉ុន្តែវាមិនគ្រប់គ្រាន់សម្រាប់ព្យាករណ៍ថាមាន ឬគ្មានប្រតិកម្មនៅអេឡិចត្រូតទេ។

## V. អគ្គិសនីវិភាគសូលុយស្យុងទង់ដែងស៊ុលផាត ($CuSO_4$)

ក្នុងអគ្គិសនីវិភាគនេះគេដាក់សូ. $Cu^{2+} + SO_4^{2-}$ ដែលមានកំហាប់ $0.1 mol.L^{-1}$ ក្នុងកែវបែស៊ែ ហើយគេដាក់**ត្រាំអេឡិចត្រូតទាំងពីរធ្វើពី លោហៈទង់ដែង** Cu ។ ក្រោយពីគេផ្តល់ចរន្តអគ្គិសនីដែលមានតង់ស្យុងពី 0.1V ទៅ 0.5V គេសង្កេតឃើញ :

-កាតូតត្រូវបានរុំព័ទ្ធដោយពំនូកលោហៈទង់ដែង

-អាណូតសឹកបន្តិចម្តងៗ និងសូលុយស្យុងមិនប្រែប្រួលពណ៌ទេ។

**បំណកស្រាយ :**

នៅកាតូត : អ៊ីយ៉ុង $Cu^{2+}$ រងរេដុកម្ម

$Cu^{2+} + 2e^- \longrightarrow Cu$

នៅអាណូត : លោហៈទង់ដែងរងអុកស៊ីតកម្ម

$Cu \longrightarrow Cu^{2+} + 2e^-$

សមីការតុល្យការ

$Cu^{2+} + Cu \longrightarrow Cu + Cu^{2+}$




តាមសមីការតុល្យការបង្ហាញថាអ៊ីយ៉ុង $Cu^{2+}$ ដែលបានបាត់នៅកាតូតត្រូវបានកកើតឡើងវិញនៅអាណូត ដែលធ្វើឱ្យកំហាប់អ៊ីយ៉ុង $Cu^{2+}$ មិនប្រែប្រួល អគ្គិសនីវិភាគបែបនេះហៅថា ***អគ្គិសនីវិភាគអាណូតរលាយ***។

## VI. អនុវត្តន៍អគ្គិសនីវិភាគ

អគ្គិសនីវិភាគមានសារប្រយោជន៍សំខាន់ដូចជា :

**១.ផលិតអង្គធាតុគោល**

-លោហៈមួយចំនួនថ្មីបើវាជារេដុករខ្លាំងជាងអ៊ីដ្រូសែន ក៏គេអាចធ្វើវាពីអគ្គិសនីវិភាគសូ.ទឹកដែលមានកាចុងលោហៈនោះ ។

ឧ. **Zn** បានមកពីអគ្គិសនីវិភាគសូ. **$ZnSO_4$** លាយ **$H_2SO_4$** ។ ចំពោះលោហៈដែលជារេដុករខ្លាំងដូចជា **Na, K, Al**… គេអាចធ្វើវាពី អគ្គិសនីវិភាគសមាសធាតុអ៊ីយ៉ុងរលាយដោយកម្តៅ ។




ឧ. **$H_2$** និង **$O_2$** គេអាចធ្វើវាពីអគ្គិសនីវិភាគសូ. **KOH.**

ឧ. **$Cl_2$** និង **NaOH** អាចបានពីអគ្គិសនីវិភាគសូ. **NaCl** ។ល ។

**២.ចម្រាញ់លោហៈ**

ដើម្បីបាន **Au, Ag, Cu, Pb, Ni** …សុទ្ធគេត្រូវធ្វើអគ្គិសនីវិភាគអាណូតរលាយ ។ ពេលធ្វើអគ្គិសនីវិភាគគេយកលោហៈដែលមានភាពមិនសុទ្ធធ្វើជាអាណូត និង លោហៈសុទ្ធកកើតនៅកាតូត ។

**៣.ការឆ្លងពីន្ទុកលោហៈ**

កាល់វ៉ាណូជាបច្ចេកទេសស្រោបវត្ថុប្រើប្រាស់ដោយស្រទាប់លោហៈស្តើងមួយ ។ វិធីកាល់វ៉ាណូមានពីរប្រភេទគឺ

-កាល់វ៉ាណូស្តេស៊ីជាវិធីស្រោបស្រទាប់លោហៈស្តើងទៅលើវត្ថុផ្សេងទៀត ដើម្បីការពារកំណូត ឬដើម្បីធ្វើឱ្យវត្ថុទាំងនោះមានសោភណ្ឌភាពល្អ ។

ឧ. ការស្រោបក្រូម ឬ នីកែល ស្រោបប្រាក់ ឬមាស……. ។

-កាល់វ៉ាណូផ្លាស្ទីជាវិធីប្រើសម្រាប់ធ្វើពុម្ពឱ្យដូចជារាងវត្ថុដែលគេចង់បាននិងលើផ្ទៃពុម្ពអាចចម្លងអគ្គិសនីបាន ។

ឧ. ការផលិតរូបចម្លាក់បូរាណ មេដាយកិត្តិយស….. ។

ជំពូកទី៤ : ប្រតិកម្មគីមី និង ថាមពល

មេរៀនទី១ : ថាមពលគីមី

## I.បំលែងថាមពលគីមីទៅជាថាមពលកម្ដៅ

ជាទូទៅប្រតិកម្មគីមីទាក់ទងនឹងបណ្ដូរកម្ដៅ ដែលអាចឱ្យដឹងបានតាមរយៈការឡើងសីតុណ្ហភាព ឬការចុះសីតុណ្ហភាព។ ប្រតិកម្មគីមីមានពីរយ៉ាងគឺ ប្រតិកម្មបញ្ចេញកម្ដៅ និង ប្រតិកម្មស្រូបកម្ដៅ។

-ប្រតិកម្មបញ្ចេញកម្ដៅជាប្រតិកម្មមួយដែលថាមពលកម្ដៅត្រូវបានបញ្ចេញទៅឱ្យមជ្ឈដ្ឋានជុំវិញ។

-ប្រតិកម្មស្រូបកម្ដៅជាប្រតិកម្មមួយដែលថាមពលកម្ដៅត្រូវបានស្រូបពីមជ្ឈដ្ឋានជុំវិញ។

## II.ការបង្កសម្ព័ន្ធនិងការផ្ដាច់សម្ព័ន្ធ

- បណ្ដាច់សម្ព័ន្ធជាលំនាំស្រូបកម្ដៅ ចំណែកការបង្កសម្ព័ន្ធជាលំនាំបញ្ចេញកម្ដៅ។

ឧទាហរណ៍ : ចំហេះឧស្ម័ន $H_2$ ជាមួយឧស្ម័ន $O_2$ ឱ្យផលជាចំហាយទឹក $H_2O$ ។

$2H_2(g) + O_2(g) \longrightarrow 2H_2O(g)$ + កម្ដៅ

$2H-H + O=O \longrightarrow 2H-O-H$ + កម្ដៅ

**បណ្ដូរថាមពលសរុប = ថាមពលបញ្ចេញ - ថាមពលស្រូបចូល**

**(ពេលបង្កសម្ព័ន្ធ) (ពេលផ្ដាច់សម្ព័ន្ធ)**

កម្ដៅ $= 4\times(O-H) - [2\times(H-H) + (O=O)]$

$= 4\times(463) - [2\times436 + (496)]$

$= 1852 - 1368$

$= 484$ kJ/mol

| សម្ព័ន្ធ | ថាមពលសម្ព័ន្ធមធ្យម (kJ/mol) |
|---|---|
| H – H | 436 |
| C – C | 348 |
| C – H | 413 |
| C = O | 743 |
| O = O | 496 |
| O – H | 463 |
| C = C | 612 |
| N – H | 388 |

## III.ប្រតិកម្មបញ្ចេញកម្ដៅ

ប្រតិកម្មបញ្ចេញកម្ដៅគឺ

-បញ្ចេញកម្ដៅ

-សីតុណ្ហភាពកើនដល់មជ្ឈដ្ឋានជុំវិញ

-ផលិតផលដែលទទួលបានមានថាមពលទាបជាងថាមពលអង្គធាតុប្រតិករ ($\Delta H < 0$)

-ថាមពលដែលបញ្ចេញក្នុងការបង្កើតសម្ព័ន្ធច្រើនជាងថាមពលស្រូបចូលសម្រាប់បណ្ដាច់សម្ព័ន្ធ។

ប្រតិកម្មចំហេះ (ប្រតិកម្មគីមីជាមួយអុកស៊ីសែន ) និងប្រតិកម្មបន្សាប ជាប្រតិកម្មបញ្ចេញកម្ដៅ ។

ឧ. ចំហេះធ្យូងថ្ម ឧស្ម័នធម្មជាតិ អ៊ីដ្រូសែន.... និងប្រតិកម្មបន្សាបអាស៊ីត-បាស។

$2C(s) + O_2(g) \longrightarrow 2CO(g)$ + កម្ដៅ

$C(s) + O_2(g) \longrightarrow CO_2(g)$ + កម្ដៅ

$2H_2(g) + O_2(g) \longrightarrow 2H_2O(g)$ + កម្ដៅ

$CH_4(g) + O_2(g) \longrightarrow CO_2(g) + 2H_2O(g)$ + កម្ដៅ

$C_6H_{12}O_6(s) + 6O_2(g) \longrightarrow 6CO_2(g) + 6H_2O(g)$ + កម្ដៅ

## IV. ប្រតិកម្មស្រូបកម្ដៅ

ប្រតិកម្មស្រូបកម្ដៅគឺ

-ស្រូបកម្ដៅ

-សីតុណ្ហភាពទាបជាងមជ្ឈដ្ឋានជុំវិញ

-ផលិតផលដែលទទួលបានមានថាមពលខ្ពស់ជាងថាមពលអង្គធាតុប្រតិករ ($\Delta H > 0$)

-ថាមពលដែលបញ្ចេញក្នុងការបង្កើតសម្ព័ន្ធតិចជាងថាមពលស្រូបចូលសម្រាប់បណ្ដាច់សម្ព័ន្ធ។

ឧ. ប្រតិកម្មបំបែកដោយកម្ដៅនៃសមាសធាតុមួយចំនួន

$$CaCO_3(s) \xrightarrow{\text{កម្ដៅ}} CaO(s) + CO_2(g)$$

$$2Pb(NO_3)_2(s) \xrightarrow{\text{កម្ដៅ}} 2PbO(s) + 2NO_2(g) + O_2(s)$$

$$Cu(OH)_2(s) \xrightarrow{\text{កម្ដៅ}} CuO(s) + H_2O(g)$$

ការរំលាយក្រាមសមាសធាតុអ៊ីយ៉ុនិច សុទ្ធសឹងជាប្រតិកម្មស្រូបកម្ដៅ។ ឯកម្ដៅដែលត្រូវស្រូបចូលត្រូវប្រើសម្រាប់បណ្ដាច់សម្ព័ន្ធក្នុងបណ្ដាញក្រាម។

ឧ. $NaNO_3(s) + H_2O(l) \xrightarrow{\text{កម្ដៅ}} NaNO_3(aq)$

$$NH_4NO_3(s) + H_2O(l) \xrightarrow{\text{កម្ដៅ}} NH_4NO_3(aq)$$

$$NaCl(s) + H_2O(l) \xrightarrow{\text{កម្ដៅ}} NaCl(aq)$$

* បណ្ដូរអង់តាល់ពី (ថាមពល)

| | |
|---|---|
| $\Delta$ | : ដែលតា មានន័យថាភាពខុសគ្នា |
| H | : អង់តាល់ពីប្រតិកម្ម |
| E | : ថាមពល |
| $\Delta H$ | : E (ផលិតផល) − E (ប្រតិករ) |
| គិតជាស៊ូល | |
| $\Delta H$ | : វិជ្ជមាន (ស្រូបកម្ដៅ) |

## V. កម្ដៅប្រតិកម្ម

បរិមាណកម្ដៅដែលបញ្ចេញ ឬស្រូបក្នុងអំឡុងពេលប្រតិកម្មគីមីនៅសម្ពាធថេរ ហៅថា **បម្រែបម្រួលអង់តាល់ពី ឬ កម្ដៅប្រតិកម្ម** តាងដោយនិមិត្តសញ្ញា $\Delta H$ មានខ្នាតគិតជាគីឡូស៊ូល (kJ) ។

ឧ. $Fe_2O_3(s) + 3CO(g) \longrightarrow 2Fe(s) + 3CO_2(g) \qquad \Delta H = -27kJ$

$$CaCO_3(s) \longrightarrow CaO(s) + CO_2(g) \qquad \Delta H = +222kJ$$

## VI. ថាមពលសកម្ម

ថាមពលចាំបាច់សម្រាប់ឱ្យប្រតិកម្មគីមីចាប់ផ្ដើមដំណើរការហៅថា **ថាមពលសកម្មកម្ម** ។

ឧ. ដើម្បីដាំបាយដោយប្រើចង្ក្រានហ្គាស ឧស្ម័នមេតាន $CH_4$ មិនអាចឆេះដោយខ្លួនវាទេ ដូច្នេះយើងត្រូវធ្វើឱ្យវាឆេះ ដោយផ្ដល់ផ្កាភ្លើង ឬអណ្ដាតភ្លើងទៅលើវា។ ថាមពលដែលយើងផ្ដល់ដើម្បីឱ្យមេតានឆេះនេះជា*ថាមពលសកម្មកម្ម*។

**ដ្យាក្រាមកម្រិតថាមពលនៃប្រតិកម្ម**




ថាមពលសកម្មកម្ម ត្រូវការដើម្បីបណ្ដាច់សម្ព័ន្ធក្នុងអង្គធាតុប្រតិករមុនការកកើតឡើងនៃសម្ព័ន្ធថ្មី ។

## VII. ការសន្សំសំចៃថាមពល

ក្នុងឧស្សាហកម្ម ការសន្សំសំចៃថាមពលគឺជាការសំខាន់ ។ ប្រសិទ្ធភាពដ៏ធំធេងក្នុងការប្លែងថាមពលពីទម្រង់មួយទៅមួយលើឧបករណ៍សម្រាប់ដុតនិងឥន្ធនៈ ។ ដូចជាឧស្ម័នធម្មជាតិដែលសម្បូរទៅដោយឧស្ម័នមេតាន គឺជាឥន្ធនៈប្រសើរជាងឧស្ម័នធ្យូងថ្ម ពីព្រោះវាបញ្ចេញកម្ដៅច្រើននៅពេលគេដុតវា ។ 1 ម៉ូលឧស្ម័នមេតានត្រូវនឹងមាឌ 24L នៅសីតុណ្ហភាពបន្ទប់និងសម្ពាធ 1atm ផ្ដល់ថាមពលកម្ដៅបាន 890kJ ។

$$CH_4(g) + 2O_2(g) \longrightarrow CO_2(g) + 2H_2O(g) + 890kJ/mol$$

កាលពីដើមក្នុងការរុករកប្រេង និងឧស្ម័នធម្មជាតិដែលប្រមូលបានត្រូវបានដុតចោលទាំងស្រុង ។ ប៉ុន្តែបច្ចុប្បន្ននេះគេប្រមូលវាជាឧស្ម័នផ្សេងៗទៀតរួចធ្វើវាឱ្យទៅជាអង្គធាតុរាវដោយការបញ្ចុះសីតុណ្ហភាពដើម្បីងាយស្រួលក្នុងការរក្សាទុកជា **L.P.G** (Liquid Petroleum Gas) ហៅថាឧស្ម័នប្រេងកាតរាវ ។

## មេរៀនទី២ : ទែម៉ូគីមីប្រតិកម្ម

### I. កម្តៅនិងសីតុណ្ហភាព

**កម្តៅ** គឺជាការផ្លាស់ប្តូរថាមពលកម្តៅរវាងសារធាតុពីរនៅសីតុណ្ហភាពផ្សេងគ្នា ។

**សីតុណ្ហភាព** គឺជារង្វាស់ថាមពលស៊ីនេទិចមធ្យមរបស់ភាគល្អិតនៃរូបធាតុ ។ បើថាមពលស៊ីនេទិចរបស់ភាគល្អិតក្នុងភាគសំណាកកាន់តែធំ នោះសីតុណ្ហភាពកាន់តែខ្ពស់មានន័យថាកាន់តែក្តៅ ។

ក្នុងការគណនាគេប្រើមាត្រដ្ឋានសីតុណ្ហភាពជាអង្សាសេ ( °C ) និងអង្សាកែលវិន ( K ) ។

ទំនាក់ទំនង : $K = 273.15 + °C$ ប៉ុន្តែក្នុងការគណនាគេយកតម្លៃ : $K = 273 + °C$

### II. កម្តៅយថាប្រភេទ ( កម្តៅម៉ាស )

**និយមន័យ** : កម្តៅម៉ាសជាបរិមាណថាមពលដែលត្រូវការដើម្បីឱ្យ 1g នៃសារធាតុនោះកើនសីតុណ្ហភាពបាន 1°C ។

ក្នុងការគណនា $C_p$ តាងកម្តៅម៉ាសនៅសម្ពាធ P ។ កម្តៅម៉ាស $C_p$ គិតជាស៊ូលក្នុងមួយក្រាមក្នុងមួយអង្សាសេ ( J/g.°C ) ឬគិតជា កាឡូរីក្នុងមួយក្រាមក្នុងមួយអង្សាសេ ( Cal/g.°C ) ។

រូបមន្តគណនា កម្តៅម៉ាស

$$C_p = \frac{q}{m \times \Delta T}$$ ឬ $$q = C_p \times m \times \Delta T$$

- $C_p$ តាងកម្តៅម៉ាស
- q ថាមពលបាត់បង់ ឬថាមពលចំណេញ
- m ជាម៉ាសនៃភាគសំណាក
- $\Delta T = T_{\text{ស្រេច}} - T_{\text{ដើម}}$ ឬ $\Delta T = T_f - T_i$

**តារាងកម្តៅម៉ាសរបស់សារធាតុមួយចំនួននៅ 25°C ឬ 298K**

| សារធាតុ | កម្តៅម៉ាស (J/g.K) | សារធាតុ | កម្តៅម៉ាស (J/g.K) |
|---|---|---|---|
| ទឹក (រាវ) | 4.18 | កាល់ស្យូម (រឹង) | 0.647 |
| ទឹក (រឹង) | 2.06 | កាបូនក្រាហ្វីត (រឹង) | 0.709 |
| ទឹក (ឧស្ម័ន) | 1.87 | ទង់ដែង (រឹង) | 0.385 |
| អាម៉ូញ៉ាក់ (ឧស្ម័ន) | 2.09 | មាស (រឹង) | 0.129 |
| បង់សែន (រាវ) | 1.74 | ដែក (រឹង) | 0.449 |
| អេតាណុល (រាវ) | 2.44 | បារត (រាវ) | 0.140 |
| អេតាណុល (ឧស្ម័ន) | 1.42 | សំណ (រឹង) | 0.129 |
| អាលុយមីញ៉ូម (រឹង) | 0.897 | សំណ (រឹង) | 0.129 |

### III. អង់តាល់ពីប្រតិកម្ម ( $\Delta H_{rxn}$ )

**H** ជាអង់តាល់ពី អក្សរក្រិច **Δ** ( ដែលតា ) មានន័យថាបម្រែបម្រួល ។ **ΔH** ជាបម្រែបម្រួលអង់តាល់ពីដែលជាបរិមាណថាមពលស្រូប ឬ បញ្ចេញដោយប្រព័ន្ធក្នុងអំឡុងពេលដំណើរការប្រតិកម្មនៅសម្ពាធថេរ ។ **ΔH** គឺជាភាពខុសគ្នារបស់អង់តាល់ពីផលិតផល និងអង់តាល់ពីរបស់អង្គធាតុប្រតិករ ។

សមីការបម្រែបម្រួលអង់តាល់ពីគឺ $\Delta H = H_{\text{ផលិតផល}} - H_{\text{អង្គធាតុប្រតិករ}}$

អង់តាល់ពីប្រតិកម្ម ឬកម្តៅប្រតិកម្មគឺជាបរិមាណបន្ទេរថាមពលជាកម្តៅក្នុងអំឡុងពេលប្រតិកម្មគីមី ។

អង់តាល់ពីប្រតិកម្មគឺជាភាពខុសគ្នារវាងថាមពលស្តុកទុករបស់អង្គធាតុប្រតិករ និងផលិតផល ។

- បើ **$\Delta H < 0$** ប្រតិកម្មបញ្ចេញកម្តៅ ដោយប្រពន្ធ័បាត់បង់ថាមពល ។

ឧទាហរណ៍ $2H_2(g) + O_2(g) \longrightarrow 2H_2O(g) \quad \Delta H = -483kJ$

- បើ **$\Delta H > 0$** ប្រតិកម្មស្រូបកម្តៅ ដោយប្រពន្ធ័ចំណេញថាមពល ។

ឧទាហរណ៍ $2H_2O(g) \longrightarrow 2H_2(g) + O_2(g) \quad \Delta H = +483kJ$

***វិធាន :***

-មេគុណលំនឹងក្នុងសមីការទែម៉ូគីមីប្រាប់ពីចំនួនម៉ូលរបស់អង្គធាតុប្រតិករនិងផលិតផលប៉ុន្តែមិនមែនជាចំនួនម៉ូលេគុលទេ ។

-ភាពរូបរបស់អង្គធាតុប្រតិករ ឬផលិតផលដែលទាក់ទងមានសារសំខាន់ ។

-បណ្តូរថាមពលបង្ហាញដោយសមីការទែម៉ូគីមី គឺជាសមាមាត្រដោយផ្ទាល់ទៅនឹង ចំនួនម៉ូលេគុលរបស់សារធាតុដែលរងបម្រែបម្រួល ។

-តម្លៃបម្រែបម្រួលថាមពល **ΔH** មិនជះឥទ្ធិពលជាសំគាល់ដល់ការប្រែប្រួលសីតុណ្ហភាពទេ ។

## IV.អង់តាល់ពីកំណត ( $\Delta H_f$ )

**និយមន័យ** : អង់តាល់ពីកំណជាបណ្តូរអង់តាល់ពីនៅពេលដែល**មួយម៉ូល** (1mol) របស់សមាសធាតុផលិតផលកើតឡើងពីអង្គធាតុប្រតិកររបស់វាក្នុងភាពរូបស្តង់ដានៅសីតុណ្ហភាព 25 °C និងសម្ពាធ 1atm ។

អង់តាល់ពីកំណស្តង់ដាតាងដោយ **$\Delta H^o_f$** និងគិតជាស៊ូលក្នុងមួយម៉ូល ឬគីឡូស៊ូលក្នុងមួយម៉ូល **k(J/mol)** ។




ឧទាហរណ៍ : $H_2(g) + \frac{1}{2}O_2(g) \longrightarrow H_2O(l) \quad \Delta H^o_f = -285.8kJ/mol$

$\frac{1}{2}N_2(g) + O_2(g) \longrightarrow NO_2(g) \quad \Delta H^o_f = +33.2kJ/mol$

**តារាងអង់តាល់ពីកំណស្តង់ដានៃសមាសធាតុពីមួយចំនួន 25°C ឬ 298K និង 1atm**

| សារធាតុ $\Delta H^o_f$ kJ/mol | | | |
|---|---|---|---|
| Ag(s)……0 | CaO(s)……-635.6 | $H_2O(l)$……-285.8 | $NO_2(g)$……33.2 |
| AgCl(s)……-127.04 | $CaCO_3(s)$……-1206.9 | $H_2O_2(l)$……-187.6 | $N_2O_4(g)$……9.66 |
| Al(s)……0 | $Cl_2(g)$……0 | Hg(l)……0 | $N_2O(g)$……81.56 |
| $Al_2O_3(s)$……-1669.8 | HCl(g)……-92.3 | $I_2(g)$……0 | $O_2(g)$……0 |
| $Br_2(l)$……0 | Cu(s)……0 | HI(g)……25.94 | O(g)……249.4 |
| HBr(g)……-36.2 | CuO(s)……-155.2 | Mg(s)……0 | $O_3(g)$……142.2 |
| C(ក្រាភីត)……0 | $F_2(g)$……0 | MgO(s)……-601.8 | S(ប្រលេពីប៉ែត)……0 |
| C(ពេជ្រ)……1.90 | HF(g)……-268.61 | $MgCO_3(s)$……-1112.9 | $SO_2(g)$……-296.1 |
| CO(g)……-110.5 | H(g)……218.2 | $N_2(g)$……0 | $SO_3(g)$……-395.2 |
| $CO_2(g)$……-393.5 | $H_2(g)$……0 | $NH_3(g)$……-46.3 | $H_2S(g)$……-20.15 |
| Ca(s)……0 | $H_2O(g)$……-241.8 | NO(g)……90.29 | ZnO(s)……-347.98 |

## V.អង់តាល់ពីចំហេះ ( $\Delta H_C$ )

**និយមន័យ** : អង់តាល់ពីចំហេះជាបម្រែបម្រួលអង់តាល់ពីដែលកើតឡើងក្នុងកំឡុងពេលចំហេះសព្វ **មួយម៉ូល** ( 1mol ) របស់សមាសធាតុ ។ **$\Delta H_C$** អាចគិតជា **kJ/g** ឬ គិតជា **kJ/mol** ។

ដើម្បីវាស់បរិមាណកម្តៅដែលបញ្ចេញពីចំហេះនៃសារធាតុណាមួយគេប្រើឧបករណ៍ **កាឡូរីម៉ែត** ( Calorimeter ) ។

**ចំណាំ :** ប្រតិកម្មចំហេះបង្កើតបរិមាណថាមពលជាសណ្ឋានពន្លឺ និងកម្តៅកាលណាសារធាតុនោះចូលផ្សំជាមួយអុកស៊ីសែន ($O_2$) ។

**តម្លៃអង់តាល់ពីចំហេះរបស់អាហារនិងឥន្ធនៈមួយចំនួន**

| សារធាតុ | $\Delta H_c$ (kJ/g) | សារធាតុ | $\Delta H_c$ (kJ/g) |
|---|---|---|---|
| ផ្លែប៉ោម | -2 | ដំឡូងបារាំង | -3 |
| សាច់គោ | -8 | ធ្យូងថ្ម | -35 |
| ស្រាបៀរ | -1.5 | ធ្យូង | -30 |
| នំប៉័ង | -11 | ប្រេងសាំង | -34 |
| ប៊ឺរ | -34 | កេរ៉ូសែន | -37 |
| ស៊ុត | -6 | ឧស្ម័នធម្មជាតិ | -50 |
| ទឹកដោះគោ | -3 | ឧស | -30 |

**អង់តាល់ពីចំហេះរបស់ធាតុមួយចំនួន**

| សារធាតុ | រូបមន្ត | ភាពរូប | $\Delta H_c$ (kJ/mol) |
|---|---|---|---|
| អ៊ីដ្រូសែន | $H_2$ | g | -285.8 |
| ក្រាភីត | C | s | -393.5 |
| កាបូនម៉ូណូអុកស៊ីត | CO | g | -283.0 |
| មេតាន | $CH_4$ | g | -890.8 |
| អុកតាន | $C_8H_{18}$ | *l* | -5470.5 |
| អាសេទីឡែន | $C_2H_2$ | g | -1301.1 |
| អេតាណុល | $C_2H_5OH$ | *l* | -1366.8 |
| គ្លុយកូស | $C_6H_{12}O_6$ | s | -2803.0 |

## VI. ការគណនាអង់តាល់ពីប្រតិកម្ម

ដើម្បីធ្វើការគណនាអង់តាល់ពីប្រតិកម្មដែលទាក់ទងនឹងសមីការទែម៉ូគីមីគេប្រើ **ច្បាប់ហេស្ស** ( **Hess's law** ) ដែលមានដំណាក់កាលដូចតទៅ :

- បើប្រតិកម្មច្រាសនោះសញ្ញា **ΔH** ត្រូវប្តូរ
- គុណសមីការនឹងតម្លៃ **ΔH** ដោយចំនួនគត់មិនសូន្យក្នុងករណីចាំបាច់
- បូកសមីការនីមួយៗបញ្ចូលគ្នាដើម្បីបានសមីការទែម៉ូគីមីមួយត្រឹមត្រូវតាមដែលគេចង់បាន ។

ម្យ៉ាងទៀតគេក៏អាចគណនាអង់តាល់ពីប្រតិកម្ម បានដោយប្រើអង់តាល់ពីកំណើររបស់សារធាតុទាំងឡាយក្នុងប្រតិកម្មដោយមិនចាំបាច់ស្គាល់អ្វីៗដែលប្រតិកម្មនឹងកើតមានឡើយ ។ ការគណនាអាចប្រើសមីការទូទៅក្នុងរូបមន្តខាងក្រោម :

រូបមន្ត : $\Delta H^o = \Sigma\left[(\Delta H^o_f(P)) \times n_p\right] - \Sigma\left[(\Delta H^o_f(R)) \times n_R\right]$

ដែល $\Sigma$ : ផលបូក

$P$ : ផលិតផល

$R$ : អង្គធាតុប្រតិករ

$n_p$ : ចំនួនម៉ូលផលិតផល

$n_R$ : ចំនួនម៉ូលអង្គធាតុប្រតិករ ។

## ជំពូកទី៤ : សមាសធាតុអសរីរាង្គ

## មេរៀនទី១ : អាម៉ូញ៉ាក់

### I. លក្ខណៈរបស់អាម៉ូញ៉ាក់

#### ១.លក្ខណៈរូប

អាម៉ូញ៉ាក់ជាសមាសធាតុមួយនៃអាសូត (ក្នុងខ្យល់មានអាសូតប្រមាណ 78%ជាមាឌ)។ វាជាឧស្ម័នគ្មានពណ៌ មានក្លិនឈ្ងុល ឆេះ មានម៉ាសម៉ូល $17g.mol^{-1}$ និងមានចំណុចរំពុះ -33.35°C ។

អាម៉ូញ៉ាក់មានលក្ខណៈជាបាសដោយបម្រែពណ៌ក្រដាសទូណឺសុលក្រហមទៅជាខៀវ ។

#### ២.លក្ខណៈគីមី

ឧស្ម័នអាម៉ូញ៉ាក់ប្រតិកម្មជាមួយអ៊ីដ្រូសែនក្លរួឱ្យផលជាអាម៉ូញ៉ូមក្លរួ :

$$NH_3(g) + HCl(g) \longrightarrow NH_4Cl(s)$$

### II.ផលិតអាម៉ូញ៉ាក់

#### ១.ក្នុងទីពិសោធន៍ : គេអាចធ្វើអាម៉ូញ៉ាក់តាមសមីការ :

$$NH_4Cl(aq) + NaOH(aq) \longrightarrow NaCl(aq) + H_2O(l) + NH_3(g)$$

$$N_2(g) + 3H_2(g) \rightleftharpoons 2\,NH_3(g)$$

#### ២.ក្នុងឧស្សាហកម្ម

អាម៉ូញ៉ាក់ត្រូវបានផលិតក្នុងទ្រង់ទ្រាយធំតាមរយៈលំនាំ **ហាប៊ើ** ដែលរកឃើញដោយលោក **Fritz Haber** ក្នុងឆ្នាំ1908 ។

ក្នុងលំនាំ **ហាប៊ើ** អាសូត និងអ៊ីដ្រូសែនត្រូវបានលាយបញ្ចូលគ្នាតាមសមាមាត្រ 1:3 ។ អាសូតបានមកពីខ្យល់ និង អ៊ីដ្រូសែនបានមកពីក្រាគីង (**Cracking**) ប្រេងកាត ដោយប្រើកាតាលីករ ដែក នៅសីតុណ្ហភាព 450°C និងសម្ពាធ 200atm ។

សមីការប្រតិកម្មផលិតអាម៉ូញ៉ាក់ : $N_2(g) + 3H_2(g) \rightleftharpoons 2NH_3(g) \quad \Delta H = -184kJ$

បកស្រាយតាមក្រាហ្វ




-បើសម្ពាធកាន់តែខ្ពស់ នោះភាគរយអាម៉ូញ៉ាក់នៅភាពលំនឹងកាន់តែ ច្រើន ។

-បើសីតុណ្ហភាពកាន់ខ្ពស់ នោះភាគរយអាម៉ូញ៉ាក់នៅភាពលំនឹងកាន់តែ តិច ។

-ដើម្បីបង្កើនបរិមាណអតិបរមានៃអាម៉ូញ៉ាក់នៅភាពលំនឹងគេត្រូវតែបង្កើនសម្ពាធឱ្យខ្ពស់និងបន្ថយសីតុណ្ហភាពឱ្យទាប ។

### III.ជីអាសូត

រុក្ខជាតិត្រូវការអាសូតដើម្បីបង្កើតប្រូតេអ៊ីន ដែលជាតម្រូវការចាំបាច់សម្រាប់ការលូតលាស់ ។ ដូច្នេះជីអាសូតជួយបង្កើនប្រូតេអ៊ីនរុក្ខជាតិដែលធ្វើឱ្យគ្រាប់ធញ្ញជាតិមានគុណភាពល្អ ។

ធញ្ញជាតិជាអាហារដូចជា ស្រូវ ពោត.... លូតលាស់បានល្អដោយសារវាស្រូបយកសារធាតុចិញ្ចឹមក្នុងដី។ បើគ្មានសារធាតុចិញ្ចឹមទាំងនេះបន្ថែមទេដីនឹងខ្សោះជីជាតិ ដែលជាហេតុធ្វើឱ្យទិន្នផលដំណាំថយចុះ ។ បច្ចុប្បន្នដោយសារកំណើនប្រជាជនយ៉ាងលឿន

ក្នុងកំឡុងពីរសតវត្សកន្លងមកនេះ ដែលធ្វើឱ្យមានតម្រូវការអាហារច្រើន ចំណែកឯធនធានអាសូតក្នុងធម្មជាតិកាន់តែអស់ទៅ ។

**ជីអាសូត** : អាសូតបានស្រូបដោយរុក្ខជាតិជាសណ្ឋានអ៊ីយ៉ុងនីត្រាតរលាយ ។ អ៊ីយ៉ុងអាម៉ូញ៉ូមរងអុកស៊ីកម្មយ៉ាងរហ័សទៅជាអ៊ីយ៉ុងនីត្រាតក្នុងដី ។ ដូចនេះជីអាសូតជាសមាសធាតុដែលមានផ្ទុកអ៊ីយ៉ុងនីត្រាត ឬអ៊ីយ៉ុងអាម៉ូញ៉ូម ។

**តារាងសមាសធាតុអាសូតសំខាន់ៗ**

| សមាសធាតុ | រូបមន្ត | សំគាល់ |
|---|---|---|
| អាម៉ូញ៉ាក់ | $NH_3$ | ជាឧស្ម័នមានភាគរយអាសូតច្រើនអាចចាក់ដោយផ្ទាល់ទៅក្នុងដី |
| អាម៉ូញ៉ូមនីត្រាត | $NH_4NO_3$ | ផ្តល់អ៊ីយ៉ុងអាម៉ូញ៉ូម និងអ៊ីយ៉ុងនីត្រាត |
| អាម៉ូញ៉ូមស៊ុលផាត | $(NH_4)_2SO_4$ | ផ្តល់អ៊ីយ៉ុងអាម៉ូញ៉ូម និងអ៊ីយ៉ុងស៊ុលផាត |
| អ៊ុយរ៉េ | $CO(NH_2)_2$ | ប្រតិកម្មជាមួយទឹកឱ្យជាអ៊ីយ៉ុងអាម៉ូញ៉ូម |

☛ **ការជ្រើសរើសជីអាសូត**

-តើវាបញ្ចេញអាសូតទៅឱ្យរុក្ខជាតិលឿនបែបណា?

-តើវាមានកម្រិតរលាយដូចម្តេច?

-ភាគរយអាសូតដែលមាន

-តម្លៃក្នុងមួយគីឡូក្រាម ។

## IV.បញ្ហាបំពុលដែលបណ្តាលមកពីជីគីមី

ជីអាសូតដែលបានហូរចេញពីដីចូលក្នុងទន្លេ បឹងបួរដែលនៅក្បែរនោះ ដែលជាប្រភពបំពុលទឹក :

-អាសូតអាចបង្កឱ្យមានជីជាតិក្នុងទឹក

-អាសូតអាចបន្ថែមអ៊ីយ៉ុងនីត្រាតក្នុងទឹក (អ៊ីយ៉ុងនីត្រាតជាសារធាតុពុល) ។ ពេលដែលយើងផឹកទឹកដែលមានផ្ទុកអ៊ីយ៉ុងនីត្រាតអាចបណ្តាលឱ្យមានជម្ងឺមហារីក ។ អំបិលអាម៉ូញ៉ូមក៏មានគ្រោះថ្នាក់ដែរដោយសារអ៊ីយ៉ុងអាម៉ូញ៉ូមរងអុកស៊ីតកម្មជាអ៊ីយ៉ុងនីត្រាតតាមរយៈបាក់តេរីក្នុងទឹក ។ ដូច្នេះគេមានការលំបាកដើម្បីយកអ៊ីយ៉ុងនីត្រាតទាំងស្រុងចេញពីទឹកម៉ាស៊ីនក្នុងអាងប្រព្រឹត្តិកម្ម ។

ការបំពុលទឹកបណ្តាលមកពីកសិករប្រើប្រាស់ជីលើសបរិមាណដីកំណត់លើដីណាំរបស់គាត់ ។




**ផលិតកម្មជីអាសូត**

## មេរៀនទី២ : អាស៊ីតស៊ុលផួរិច

### I. អុកស៊ីតរបស់ស្ពាន់ធ័រ

អុកស៊ីតរបស់ស្ពាន់ធ័រមានពីរយ៉ាងគឺ ស្ពាន់ធ័រឌីអុកស៊ីត និងស្ពាន់ធ័រទ្រីអុកស៊ីត ។

#### ១.ស្ពាន់ធ័រឌីអុកស៊ីត

គេទទួលស្ពាន់ធ័រឌីអុកស៊ីតតាមរយៈចំហេះស្ពាន់ធ័រក្នុងខ្យល់ ។ តាមសមីការខាងក្រោម :

$S(s) + O_2(g) \longrightarrow SO_2(g)$

ស្ពាន់ធ័រឌីអុកស៊ីតត្រូវបានគេយកទៅប្រើក្នុងអាហារបម្រុង (តាមរយៈការសម្លាប់បាក់តេរី) ក្នុងដំណាប់ផ្លែឈើក្ងួរ ផ្លែឈើកំប៉ុង និងទឹកផ្លែឈើ ការសម្លាប់មេរោគដបដាក់ទឹកដោះគោសម្រាប់ទារក ។ $SO_2$ អាចរលាយក្នុងទឹកនៅកំហាប់ប្រមាណ **50p.p.m** ឬ **50mg/L** ដែលមានសក្ដានុពលគ្រប់គ្រាន់សម្រាប់សម្លាប់បាក់តេរីដែលអាចបណ្ដាល់ឱ្យមានគ្រោះថ្នាក់ ។

#### ២.ស្ពាន់ធ័រទ្រីអុកស៊ីត

ស្ពាន់ធ័រទ្រីអុកស៊ីតជាអុកស៊ីតខ្ពស់បំផុតនៃស្ពាន់ធ័រ ។ គេអាចធ្វើស្ពាន់ធ័រទ្រីអុកស៊ីតបានដោយយក ឧស្ម័នអុកស៊ីសែន និង $SO_2$ ទៅសម្ងួតដោយការឱ្យពពុះឆ្លងកាត់ $H_2SO_{4ត្រូវ}$ តាមសមាមាត្រ 2:1 និងប្រើកាតាលីករ ក្រោមសីតុណ្ហភាពប្រមាណ 500°C ។

$2SO_2(g) + O_2(g) \rightleftarrows 2SO_3(g)$

### II.លក្ខណៈរបស់ស្ពាន់ធ័រអុកស៊ីត

#### ១.ស្ពាន់ធ័រឌីអុកស៊ីត

ស្ពាន់ធ័រឌីអុកស៊ីតជាឧស្ម័នគ្មានពណ៌មានក្លិនឈ្ងុល ក្លិនឈើគូសឆេះ ធ្ងន់ជាងខ្យល់ និងងាយរលាយក្នុងទឹកទៅជាអាស៊ីតស៊ុលផួរ៉ូ តាមសមីការ : $SO_2(g) + H_2O(l) \rightleftarrows H_2SO_3(aq)$

ការរលាយនៃស្ពាន់ធ័រឌីអុកស៊ីតក្នុងទឹកមានលក្ខណៈគួរឱ្យកត់សំគាល់ដែលជាប្រភពចម្បងនៃការបំពុលបរិយាកាស ។ ស្ពាន់ធ័រឌីអុកស៊ីតកើតឡើងច្រើនកាលណាគេប្រើប្រាស់ផូស៊ីលឥន្ធនៈដូចជា ធ្យូងថ្ម និងប្រេង...។ វារលាយក្នុងទឹកភ្លៀងក្លាយជាភ្លៀងអាស៊ីតដែលបំផ្លាញសំណង់អាគារ បន្លែបង្កា និងរុក្ខជាតិបៃតង... ។

#### ២.ស្ពាន់ធ័រទ្រីអុកស៊ីត

ស្ពាន់ធ័រទ្រីអុកស៊ីតជាអានីឌ្រីតនៃអាស៊ីតស៊ុលផួរិច ។ កាលណាស្ពាន់ធ័រទ្រីអុកស៊ីតប្រតិកម្មជាមួយទឹកឱ្យជាអាស៊ីតស៊ុលផួរិច

$SO_3(g) + H_2O(l) \longrightarrow H_2SO_4(aq)$

**តារាងបង្ហាញពីម៉ាសស្ពាន់ធ័រទ្រីអុកស៊ីតទទួលបាននៅសីតុណ្ហភាពខុសៗគ្នា**

| សីតុណ្ហភាព°C | 100 | 200 | 300 | 400 | 500 | 600 |
|---|---|---|---|---|---|---|
| ម៉ាសស្ពាន់ធ័រទ្រីអុកស៊ីត (Kg) | 200 | 300 | 70 | 12 | 28 | 16 |
| រយៈពេលផលិតកម្ម | 3ម៉ោង | 4ម៉ោង | 45នាទី | 6នាទី | 15នាទី | 10នាទី |

### III.ឧស្សាហកម្មផលិតអាស៊ីតស៊ុលផួរិច (លំនាំដោយផ្ទាល់)

អាស៊ីតស៊ុលផួរិចត្រូវបានផលិតយ៉ាងច្រើនរហូតដល់ 1000 លានតោនម៉ែត្រគូបជារៀងរាល់ឆ្នាំតាមលំនាំដោយផ្ទាល់ ។ ការផលិតអាស៊ីតស៊ុលផួរិចមាន 5 ដំណាក់ការ :

**ដំណាក់ការទី១ :** វត្ថុធាតុដើមមានស្ពាន់ធ័រនិងខ្យល់ ។ ស្ពាន់ធ័រកើតឡើងពីចំហេះរវាងធាតុទាំងពីរ ។

$$S(s) + O_2(g) \longrightarrow SO_2(g)$$

**ដំណាក់ការទី២ :** $SO_2$ បានបន្សុទ្ធដោយការយកភាពមិនសុទ្ធចេញដូចជាសមាសធាតុអាសេនិច ។

**ដំណាក់ការទី៣ :** $SO_2$ និងខ្យល់ដែលបានបន្សុទ្ធរួចសំងួត និងឱ្យឆ្លងកាត់កាតាលីករវ៉ាណាដ្យូមអុកស៊ីត ($V_2O_5$) នៅសីតុណ្ហភាព 450°C និងសម្ពាធ 2-3atm ។ ប្រតិកម្មអាចត្រឡប់ប៉ុន្តែនៅសីតុណ្ហភាព និងសម្ពាធខាងលើ98% បំលែងទៅជា $SO_3$ ។

$$2SO_2(g) + O_2(g) \rightleftharpoons 2SO_3(g)$$

**ដំណាក់ការទី៤ :** ជំហានបន្ទាប់គឺការរំលាយស្ពាន់ធ័រទ្រីអុកស៊ីតក្នុង $H_2SO_4$ ខាប់ ទៅជាអូលេអូម (Oleum) ឬចំហាយ $H_2SO_4$ ។

$$SO_3(g) + H_2SO_4(l) \longrightarrow H_2S_2O_7(l)$$

**ដំណាក់ការទី៥ :** រំលាយអូលេអូមក្នុងទឹកទៅជាអាស៊ីតខ្លាំង ។

$$H_2S_2O_7(l) + H_2O(l) \longrightarrow 2H_2SO_4(l)$$

## III. បម្រើបម្រាស់អាស៊ីតស៊ុលផួរិច




**ការប្រើប្រាស់អាស៊ីតស៊ុលផួរិច**

ក្នុងវិស័យសេដ្ឋកិច្ច អាស៊ីតស៊ុលផួរិចប្រើសម្រាប់ផលិតជី អាស៊ីតអាគុយ សារធាតុជម្រះ ថ្នាំលាប ឧសថជាដើម ។

## មេរៀនទី៣ : សមាសធាតុកាល់ស្យូម

### I.លក្ខណៈទូទៅរបស់កាល់ស្យូម

កាល់ស្យូមជាលោហៈមានពណ៌ប្រផេះ ស្ថិតនៅក្រុមទី 2 ខួបទី 4នៃតារាងខួប ។ មានលេខអាតូម 20 ដែលត្រូវនឹងរបាយអេឡិចត្រុង $K^2.L^8.M^8.N^2$ ។

### II.កាល់ស្យូមអុកស៊ីត

កាល់ស្យូមអុកស៊ីតទទួលបានដោយការដុតកម្ដៅកាល់ស្យូមកាបូណាត ។ កាល់ស្យូមអុកស៊ីតដែលទទួលបានជាម្សៅពណ៌សងាយរលាយក្នុងទឹក ទៅជាកាល់ស្យូមអ៊ីដ្រុកស៊ីត ។

$$CaCO_3(s) \longrightarrow CaO(s) + CO_2(g)$$

$$CaO(s) + H_2O(l) \rightleftharpoons Ca(OH)_2(aq)$$

កាល់ស្យូមអុកស៊ីតជាអុកស៊ីតបាស វាមានប្រតិកម្មជាមួយអាស៊ីត

$$CaO(s) + 2HCl(aq) \longrightarrow CaCl_2(aq) + H_2O(l)$$

$$CaO(s) + H_2SO_4(aq) \longrightarrow CaSO_4(aq) + H_2O(l)$$

### III.កាល់ស្យូមអ៊ីដ្រុកស៊ីត

កាល់ស្យូមអ៊ីដ្រុកស៊ីត (កំបោរងាប់) មានរូបមន្ត $Ca(OH)_2$ ។ កាល់ស្យូមអ៊ីដ្រុកស៊ីតជាម្សៅពណ៌ស គ្មានក្លិន គេអាចទទួលវាបានតាមរយៈប្រតិកម្មកាល់ស្យូមអុកស៊ីតជាមួយទឹក ។

$$CaO(s) + H_2O(l) \longrightarrow Ca(OH)_2(aq)$$

ក្នុងវិស័យកសិកម្មដីស្រែ និងដីដំណាំមួយចំនួនបានបាត់បង់ជីជាតិ ក្លាយជាដីហ៊ីរ ដែលពុំអាចដាំដំណាំបាន ។ ដូចនេះគេត្រូវប្រើកំបោរងាប់ ឬ កំបោររស់ បាចលើដីទាំងនោះ ដើម្បីកែលម្អដីឡើងវិញ ។

### IV.អំបិលកាល់ស្យូមនានា

#### ១.កាល់ស្យូមកាបូណាត

ក្នុងធម្មជាតិកាល់ស្យូមកាបូណាតមានក្នុងសណ្ឋានជាច្រើន ដូចជាកាល់ស៊ីត (**Calcite**) ថ្មម៉ាប ដីស ថ្កាថ្ម ថ្មកំបោរ សំបកសិប្បីសត្វ (ងាវ ក្ដាម លៀស ធ្មេញ) និងឆ្អឹងសត្វជាដើម ។

#### ២.កាល់ស្យូមក្លរួ

កាល់ស្យូមក្លរួ ជាអង្គធាតុរឹងពណ៌សស្រូបសំណើម គេប្រើវាជាភ្នាក់ងារសម្ងួតក្នុងទីពិសោធន៍គីមី ។

ក្នុងទីពិសោធន៍គេទទួលបានកាល់ស្យូមក្លរួ ដោយប្រតិកម្មកាល់ស្យូមអុកស៊ីតជាមួយអាស៊ីតក្លរីឌ្រិចរាវ ។

$$CaO(s) + 2HCl(aq) \longrightarrow CaCl_2(aq) + H_2O(l)$$

$$CaCl_2(s) \longrightarrow Ca^{2+}(aq) + 2Cl^-(aq) \quad \Delta H = -82kJ.mol^{-1}$$

#### ៣.កាល់ស្យូមស៊ុលផាត

កាល់ស្យូមស៊ុលផាតរកឃើញក្នុងទម្រង់ជាអ៊ីដ្រាតេ $CaSO_4.2H_2O$ ឬហៅថា **ម្នាងសិលា** ។ កាលណាគេដុតកម្ដៅដល់ 100°C ម្នាងសិលាប្លែងជាម្សៅប្លាត តាមសមីការ :

$$CaSO_4.2H_2O \longrightarrow CaSO_4.½H_2O(s) + {}^{3}/_{2}H_2O(g)$$

ម្សៅប្លាតមានពណ៌សដែលកើតឡើង $CaSO_4.½H_2O$ មានប្រតិកម្មយឺតជាមួយទឹក រួចឡើងក្រាមជាថ្មី ក្រោមសណ្ឋាន ជា

ម្នាងសិលារឹងវិញ។ ម្នាងសិលាប្រើយ៉ាងទូលំទូលាយដូចជា ថ្នាំលាបជញ្ជាំងផ្ទះ ការិយាល័យ ឬមន្ទីរពេទ្យ។ ម្នាងសិលាជាសារធាតុមានតម្លៃថោកត្រូវបានគេជ្រើសរើសវាជាវត្ថុធាតុយ៉ាងសំខាន់សម្រាប់ការពារអគ្គិភ័យដោយសារតែវាមិនឆេះនិងចម្លងកម្តៅតិច ។

## V.ទឹករឹង

ទឹកក្នុងធម្មជាតិមិនមែនជាទឹកសុទ្ធទេ វាមានផ្ទុកនូវអ៊ីយ៉ុង **$Ca^{2+}$ , $Mg^{2+}$, $SO_4^{2-}$, $HCO_3^-$** និង **$Cl^-$** ។

**និយមន័យ :** ទឹករឹងជាទឹកដែលមានបរិមាណអ៊ីយ៉ុងកាល់ស្យូម **$Ca^{2+}$** និងអ៊ីយ៉ុងម៉ាញេស្យូម **$Mg^{2+}$** *ច្រើន*។

### ១. ប្រភពទឹករឹង




ក្នុងបរិយាកាសកាលណាកាបូនឌីអុកស៊ីតនិងចំហាយទឹកមានប្រតិកម្មជាមួយគ្នាបង្កទៅជាភ្លៀងអាស៊ីត។ កាល់ស្យូមកាបូណាតអាស៊ីត **$[Ca(HCO_3)_2]$** ជាធាតុបង្កសំខាន់របស់ទឹករឹង។ ពេលដែលទឹកភ្លៀងហូរកាត់ផ្ទាំងថ្មដែលផ្ទុកនូវជាតិថ្មកំបោរវាបង្កើតជាកាល់ស្យូមកាបូណាតអាស៊ីត **$[Ca(HCO_3)_2]$** រលាយក្នុងទឹក។

$$CO_2(g) + H_2O(l) \rightleftharpoons H_2CO_3(aq)$$

$$H_2CO_3(aq) + CaCO_3(s) \rightleftharpoons Ca(HCO_3)_2(aq)$$

ទឹកភ្លៀងមានប្រតិកម្មជាមួយដូឡូមីត **($CaCO_3 . MgCO_3$)** និងម្នាងសិលា **($CaSO_4 . 2H_2O$)** បង្កទៅជាទឹករឹង។

### ២. ប្រភេទទឹករឹង

ទឹករឹងចែកជាបីប្រភេទគឺ ***ទឹករឹងអចិន្ត្រៃយ៍ ទឹករឹងអនាចិន្ត្រៃយ៍ និងទឹករឹងសរុប***។

#### ក. ទឹករឹងអចិន្ត្រៃយ៍

ទឹករឹងអចិន្ត្រៃយ៍គឺអាស្រ័យលើបរិមាណអ៊ីយ៉ុង ***$SO_4^{2-}$*** និង ***$Cl^-$*** របស់អំបិលកាល់ស្យូម និងម៉ាញេស្យូម។ បើគេដាំរហូតដល់ពុះវានៅតែរឹងដដែល ពីព្រោះ $SO_4^{2-}$ និង $Cl^-$ ក្នុងទឹកមិនបង្កជាកករទេ។ Ca និង Mg ក្នុងទឹកជា **ធាតុខនិជ** ដែលធ្វើឱ្យទឹករឹង។ ភាពរឹងនៃទឹកអាស្រ័យនឹងបរិមាណកាល់ស្យូមកាបូណាត ឬម៉ាញេស្យូមកាបូណាតដែលមាននៅក្នុងទឹក គិតជាមីលីក្រាមក្នុងមួយលីត្រ។

#### ខ. ទឹករឹងអនាចិន្ត្រៃយ៍

ទឹករឹងអនាចិន្ត្រៃយ៍គឺអាស្រ័យនឹងបរិមាណ ***$HCO_3^-$*** របស់អំបិលកាល់ស្យូមកាបូណាតអាស៊ីត **$[Ca(HCO_3)_2]$** និងម៉ាញេស្យូមកាបូណាតអាស៊ីត **$[Mg(HCO_3)_2]$** ។ អំបិលទាំងពីរនេះអាចបំបែកជាកាបូណាតមិនរលាយ និងឧស្ម័នកាបូនិច តាមសមីការ

$$Ca^{2+}(aq) + 2HCO_3^-(aq) \longrightarrow CaCO_3(s) + H_2O(l) + CO_2(g)$$

$$Mg^{2+}(aq) + 2HCO_3^-(aq) \longrightarrow MgCO_3(s) + H_2O(l) + CO_2(g)$$

#### គ. ទឹករឹងសរុប

គឺជាប្រភេទទឹកដែលបានមកដោយការបូកនៃភាពរឹងអចិន្ត្រៃយ៍ និងភាពរឹងអនាចិន្ត្រៃយ៍ ។

## VI. ទឹកទន់

ទឹកទន់ជាប្រភេទទឹកដែលគ្មាន ឬ មានបរិមាណអ៊ីយ៉ុងកាល់ស្យូម **$Ca^{2+}$** និងអ៊ីយ៉ុងម៉ាញេស្យូម **$Mg^{2+}$** *តិច*។

- ទឹកទន់មានបរិមាណ $CaCO_3$ ពី 0-75 mg/L
- ទឹករឹងមធ្យមមានបរិមាណ $CaCO_3$ ពី 75-150 mg/L
- ទឹករឹងខ្លាំងមានបរិមាណ $CaCO_3$ លើសពី 150 mg/L ឡើងទៅ។

**គុណសម្បត្តិនិងគុណវិបត្តិទឹករឹងនិងទឹកទន់**

| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| **ទឹករឹង** | |
| -ល្អសម្រាប់ការលូតលាស់ឆ្អឹង ឬ ធ្មេញ<br>-បង្កើតជាស្នឹមដែលស្រោបលើបំពង់បង្ហូរទឹក ជួយការពារកុំឱ្យ ជ្រាប ឬ ធ្លាយ ។ | -ប្រើសាប៊ូច្រើនសម្រាប់ការបោកគក់<br>-បន្សល់ទុកពពុះកករដីជាប់ប្រឡាក់ខោអាវ<br>-អាចនាំឱ្យស្ទះបំពង់បង្ហូរទឹក ។ |
| **ទឹកទន់** | |
| -សាប៊ូមានពពុះច្រើនងាយស្រួលក្នុងការបោកគក់<br>-កាត់បន្ថយការឡើងស្នឹមក្នុងបំពង់បង្ហូរទឹក<br>-ប្រើសាប៊ូអស់តិចនិងនៅសីតុណ្ហភាពទាបសម្រាប់ការបោកគក់ដោយម៉ាស៊ីន ។ | -មានអ៊ីយ៉ុងសូដ្យូមច្រើនជាងទឹករឹងដែលអាចបង្កឱ្យមានជម្ងឺបេះដូង<br>-ទឹកទន់អាចរំលាយលោហៈដែលប្រើក្នុងបំពង់បង្ហូរទឹក ដូចជា សំណ និងកាត់ម្ញូម ។ |

**VII.វិធីធ្វើឱ្យទឹករឹងទៅជាទឹកទន់**

គេមិនអាចយកទឹករឹងទៅប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ ឬ ក្នុងឧស្សាហកម្មបានទេ ។ គេចាំបាច់ត្រូវជម្រុះភាពរឹងនេះជាមុនសិន មុននិងយកវាទៅប្រើ ។ ដើម្បីបំបាត់ភាពរឹងរបស់ទឹកគេប្រើវិធីដូចខាងក្រោម :

**ក.វិធីបំបាត់ភាពរឹង :** គេត្រូវដាំរហូតដល់ពុះ ឬបន្ថែម $Na_2CO_3$ ឬ$Ca(OH)_2$

$$Ca^{2+}(aq) + SO_4^{2-}(aq) + 2Na^{+}(aq) + CO_3^{2-}(aq) \longrightarrow CaCO_3(s) + 2Na^{+}(aq) + SO_4^{2-}(aq)$$

$$Ca^{2+}(aq) + 2HCO_3^{-}(aq) + Ca^{2+}(aq) + 2OH^{-}(aq) \longrightarrow CaCO_3(s) + 2H_2O(l)$$

**ខ.វិធីបំណាយ :** គេយកទឹកទៅដាំឱ្យពុះ ទឹកនឹងក្លាយទៅជាចំហាយ ។រួចគេបញ្ចុះសីតុណ្ហភាពចំហាយទឹក១នឹងក្លាយជាទឹក ។ ទឹកដែលគេទទួលបាននេះគឺជាទឹកសុទ្ធ ។

**VIII.បម្រើបម្រាស់សមាសធាតុកាល់ស្យូម**

**១.កាល់ស្យូមកាបូណាត :** កាល់ស្យូមកាបូណាតជាថ្មកំបោរអាចធន់នឹងអាកាសធាតុព្រោះសមាសធាតុនេះរឹងមិនរលាយក្នុងទឹកប្រើជាវត្ថុធាតុដើមសម្រាប់ផលិតស៊ីម៉ង់ត៍ ។ ថ្មកំបោរប្រើដើម្បីទាញយកភាពមិនសុទ្ធពីការរំលាយលោហៈក្នុងឧស្សាហកម្មសំណប៉ាហាំងនិងរ៉ែដែក ។ ថ្មកំបោរអាចប្រើប្រាស់សម្រាប់ផលិតកំបោររស់ ថ្មម៉ាបដែលរឹងមានពណ៌ស្អាតប្រើសម្រាប់ធ្វើការ៉ូ ។

**២.កាល់ស្យូមអុកស៊ីត**

-កាល់ស្យូមអុកស៊ីត ឬកំបោររស់ រលាយក្នុងទឹកឱ្យជាបាសប្រើសម្រាប់បន្សាបអាស៊ីតក្នុងដី ។

-កាល់ស្យូមអុកស៊ីតប្រើជាភ្នាក់ងារស្រូបទឹកក្នុងការរៀបចំអាម៉ូញ៉ាក់និងប្រើដើម្បីផលិតកាល់ស្យូមអ៊ីដ្រុកស៊ីត និងកាល់ស្យូមកាប ។ កាល់ស្យូមកាបប្រើសម្រាប់ផលិតឧស្ម័នអាសេទីឡែន ។

**៣.កាល់ស្យូមអ៊ីដ្រុកស៊ីត**

កាល់ស្យូមអ៊ីដ្រុកស៊ីតរលាយក្នុងទឹកមានលក្ខណៈជាបាស ។ គេប្រើសម្រាប់បន្សាបអាស៊ីតក្នុងដី ។ កាល់ស្យូមអ៊ីដ្រុកស៊ីតប្រើសម្រាប់ផលិតសម្ភារៈសំណង់ ថ្នាំលាបជញ្ជាំង និងក្នុងទីពិសោធន៍ ។

## ជំពូកទី៦ : ស្តេរ៉េអូគីមី

## មេរៀនទី១ : ធរណីមាត្រនៃម៉ូលេគុល

### I.តំនួសតាងឡឺវីស

#### ១.តម្រង់ឡឺវីសនៃអាតូម

គំនួសតាងឡឺវីសលើកឡើងតែពីអេឡិចត្រុងស្រទាប់ក្រៅ (អេឡិចត្រុងស្រទាប់វ៉ាឡង់) នៃអាតូមប៉ុណ្ណោះ ។

ឧទាហរណ៍ : $H^\bullet$  $\cdot\dot{C}\cdot$  $|\underline{O}\cdot$  $|\dot{N}\cdot$  $|\underline{Cl}\cdot$  $|\underline{S}\cdot$  $|\dot{P}\cdot$

#### ២.សម្ព័ន្ធកូវ៉ាឡង់

សម្ពន្ធ័កូវ៉ាឡង់បានកើតឡើងកាលណាអាតូមពីរដាក់អេឡិចត្រុងទោលរួមគ្នា ។ ទ្វេតាអេឡិចត្រុងដាក់រួមនេះ ហៅថា **ទ្វេតាសម្ព័ន្ធ ឬទ្វេតាអេឡិចត្រុងសម្ព័ន្ធ ឬគូអេឡិចត្រុងសម្ព័ន្ធ**ដែលតាងដោយរង្វាស់សញ្ញានៅចន្លោះនិមិត្តសញ្ញាអាតូមទាំងពីរ ។

$H\cdot + \cdot H \rightarrow H{:}H$ ឬ $H-H$ | $|\overline{O}\cdot + \cdot\overline{O}| \rightarrow \overline{O}{::}\overline{O}$ ឬ $\overline{O}=\overline{O}$

$|\overline{Cl}\cdot + \cdot\overline{Cl}| \rightarrow |\overline{Cl}{:}\overline{Cl}|$ ឬ $|\overline{Cl}-\overline{Cl}|$ | $|\dot{N}\cdot + \cdot\dot{N}| \rightarrow |N{:::}N|$ ឬ $|N\equiv N|$

#### ៣.វិធានអដ្ឋតា

*អាតូមនីមួយៗមាននិន្នាការទទួលយកទម្រង់អេឡិចត្រុងដែលមានស្ថេរភាពដូចឧស្ម័នកម្រ ដែលនៅជិតវាក្នុងចំណែកថ្នាក់តាមខួបនៃធាតុ គឺមាន 8 អេឡិចត្រុងនៅស្រទាប់ក្រៅ (វិធានអដ្ឋតា) ។ លើកលែងអាតូម H និង Li ដែលមានតែ 2 អេឡិចត្រុងនៅស្រទាប់ក្រៅ (វិធានទ្វេតា) ។*

*ឧទាហរណ៍ :* $H^\bullet + \cdot\overline{Cl}| \rightarrow H-\overline{Cl}|$

**សំគាល់ :** មានករណីលើកលែងខ្លះនៃវិធានអដ្ឋតា ។ ឧទាហរណ៍ $AlCl_3$ និង $PCl_5$ ។

#### ៤.ការសរសេរទម្រង់ឡឺវីស

**ក.និយមន័យ :** ទម្រង់ឡឺវីសគឺជាការតាងម៉ូលេគុល ឬ អ៊ីយ៉ុងប៉ូលីអាតូមដើម្បីបង្ហាញពីការបន្តអាតូមទាំងឡាយក្នុងម៉ូលេគុល ឬ អ៊ីយ៉ុង និងបង្ហាញពីអេឡិចត្រុងនៅស្រទាប់ក្រៅវ៉ាឡង់ ដោយបែងចែកគូអេឡិចត្រុងសេរីនិងគូអេឡិចត្រុងសម្ព័ន្ធ ។

ឧទាហរណ៍:




**ខ.សំណេរទម្រង់ឡឺវីស :** ការសរសេរទម្រង់ឡឺវីសត្រូវពិតតាមដំណាក់ការ 4 យ៉ាង :

-***របៀបបន្តអាតូម*** : អាតូមម៉ូណូវ៉ាឡង់ទាំងអស់ត្រូវស្ថិតនៅខាងចុង ឯអាតូមដែលមានវ៉ាឡង់ច្រើនជាងគេជាទូទៅនៅកណ្តាល ។

-***របាយទ្វេតាអេឡិចត្រុង*** : គេបូកសរុបចំនួនអេឡិចត្រុងវ៉ាឡង់ V នៃគ្រប់ធាតុនៅក្នុងម៉ូលេគុលបើជាអ៊ីយ៉ុងគេត្រូវគិតបន្ទុកសន្ទតផង ។ គេទាញរកចំនួនទ្វេតាអេឡិចត្រុង V/2 ។ ការសរសេររបាយទ្វេតាសម្ពន្ធ័និងទ្វេតាសេរីត្រូវគោរពតាមវិធានទ្វេតាសម្រាប់អ៊ីដ្រូសែន និងវិធានអដ្ឋតាសម្រាប់គ្រប់អាតូមផ្សេងទៀត ។

***-ការកំណត់បន្ទុកផាក់លាក់ :*** ក្នុងសំណេររូបមន្តឡឺវីសនៃអ៊ីយ៉ុង $CO_3^{2-}$ និង $NH_4^+$ មានដាក់បន្ទុកលើអាតូម ។ បន្ទុកនេះហៅថា ***បន្ទុកផាក់លាក់*** ។ ករណីខ្លះបន្ទុកជាក់លាក់ក៏មានក្នុងសំណេររូបមន្តឡឺវីសនៃម៉ូលេគុលណឺតមួយចំនួនដែរ ។
ដើម្បីកំណត់បន្ទុកនេះគេត្រូវរៀបចំទ្វេតាអេឡិចត្រុង បន្ទាប់មកបំបែកទ្វេតាសម្ព័ន្ធទាំងអស់ ។ បើអាតូមណាខ្លះអេឡិចត្រុង វាមានបន្ទុកវិជ្ជមានស្មើនឹងចំនួនអេឡិចត្រុងដែលខ្វះ ផ្ទុយទៅវិញបើវាចំណេញអេឡិចត្រុង វាមានបន្ទុកអវិជ្ជមាន ស្មើនឹងចំនួនអេឡិចត្រុងដែលលើស ។

***-លក្ខណៈវិនិច្ឆ័យនៃជម្រើសរវាងទម្រង់ឡឺវីសច្រើន :*** កាលណាមានរូបមន្តឡឺវីសច្រើនយ៉ាង គេជ្រើសរើសជាអាទិភាព ទម្រង់ដែលគោរពតាមវិធានអដ្ឋតាសម្រាប់គ្រប់អាតូម ។ បើមានរូបមន្តច្រើនគោរពតាមវិធានអដ្ឋតា គេត្រូវជ្រើសរើសទម្រង់ដែលមានបន្ទុកជាក់លាក់តិចជាងគេ ។

**សន្និដ្ឋាន :** ទម្រង់ឡឺវីសប្រាប់ឱ្យដឹងពីរបាយអេឡិចត្រុងក្នុងម៉ូលេគុលឬអ៊ីយ៉ុងដោយញែកសម្គាល់ទ្វេតាសម្ព័ន្ធនិងទ្វេតាសេរី ។ វាបានបញ្ជាក់ចំនួនសម្ព័ន្ធ( មួយ ពីរ ឬបីជាន់) ក្នុងម៉ូលេគុលតែមិនបានបញ្ជាក់ពីធរណីមាត្រនៃម៉ូលេគុលឬអ៊ីយ៉ុងទេ ។
ឧទាហរណ៍ : ចូរសរសេររូបមន្តឡឺវីសរបស់សមាសធាតុខាងក្រោម :

$H_2O_2$ , $CO_2$ , $HClO$ , $CH_4$ , $HCN$ , $CO_3^{2-}$ , $NH_4^+$ , $O_3$ , $CO$

## II. ធរណីមាត្រនៃម៉ូលេគុលនិងអ៊ីយ៉ុង

### ១. វិធីVSEPR

**VSEPR** សរសេរពេញ **" Valence Shell Electron Pair Repulsion"** មានន័យថា "ចម្រានគូអេឡិចត្រុងនៃស្រទាប់វ៉ាឡង់" ។ វិធីនេះប្រាប់ឱ្យយើងដឹងពីទីតាំងក្នុងលំហនៃគូអេឡិចត្រុងនៅជុំវិញអាតូមកណ្តាលរបស់ម៉ូលេគុលឬអ៊ីយ៉ុង ។

### ២. គោលការណ៍នៃវិធីVSEPR

-តាង A ជាអាតូមកណ្តាលដែលភ្ជាប់ដោយអាតូម X មានចំនួន m និង n ចំនួនគូអេឡិចត្រុងសេរី E នៅលើអាតូម A ។ គេតាងនិមិត្តសញ្ញានៃម៉ូលេគុល : $AX_mE_n$ ។

-គេចាត់ទុកអាតូម X ដែលចងសម្ព័ន្ធជាមួយ A ទោះជាប្រភេទដូចគ្នាឬខុសគ្នាវាសមមូលគ្នា ។ ម្យ៉ាងទៀតគេចាត់ទុកគូអេឡិចត្រុងសម្ព័ន្ធ និងគូអេឡិចត្រុងសេរីក៏សមមូលគ្នាដែរ ។

-កាលណាម៉ូលេគុលឬអ៊ីយ៉ុងមានសម្ព័ន្ធពីរ ឬបីជាន់គេចាត់ទុកសម្ព័ន្ធច្រើនជាន់នេះ ដូចសម្ព័ន្ធមួយជាន់ដែរ ។ ឧទាហរណ៍ :

| | | | | | |
|---|---|---|---|---|---|
| ទម្រង់ឡឺវីស : | H–C≡N | H–C=O (H) | H–C(H)(H)–H | H–N(H)–H | H–O–H |
| ប្រភេទ VSEPR : | $AX_2$ | $AX_3$ | $AX_4$ | $AX_3E$ | $AX_2E_2$ |

### ៣. ធរណីមាត្រនៃម៉ូលេគុលឬអ៊ីយ៉ុងតាមវិធីVSEPR

#### ក. ម៉ូលេគុលប្រភេទ $AX_2$






ជាម៉ូលេគុលលីនេអ៊ែ អាតូមទាំងបីរត់ត្រង់គ្នាហើយអាតូម A ហៅថា **ទ្វេកោណ** ។

-ករណីសម្ព័ន្ធមួយជាន់ ឬសម្ព័ន្ធច្រើនជាន់និងធរណីមាត្រនៃម៉ូលេគុលដូចគ្នា ។

#### ខ. ម៉ូលេគុលនិងអ៊ីយ៉ុងប្រភេទ $AX_3$




ជាម៉ូលេគុលទម្រង់ត្រីកោណអាតូម X ទាំងបីនៅទីតាំងកំពូលត្រីកោណសម័ង្សដែល

មានអាតូមកណ្ដាល A ជាផ្ចិត ។ អាតូម A ហៅថា **ត្រីកោណរាប** ។

-ករណីសម្ព័ន្ធមួយជាន់ ឬសម្ព័ន្ធច្រើនជាន់និងធរណីមាត្រនៃម៉ូលេគុលដូចគ្នា ។

### គ.ម៉ូលេគុលនិងអ៊ីយ៉ុងប្រភេទ $AX_4$

ជាម៉ូលេគុលទម្រង់ចតុមុខ ។ អាតូម **X** ទាំងបួននៅទីតាំងកំពូលចតុមុខ ដែលមានអាតូមកណ្ដាល **A** ជាផ្ចិត ។ អាតូម **A** ហៅថា **ចតុមុខ** ។




### ឃ.ម៉ូលេគុលប្រភេទ $AX_2E$

ធរណីមាត្រនៃម៉ូលេគុល **$AX_2E$** ទាញចេញពីម៉ូលេគុល **$AX_3$** ដែលអាតូម **X** មួយជំនួសដោយទ្វេតាសេរី ។ ម៉ូលេគុលប្រភេទ **$AX_2E$** មានទម្រង់ **បង្កោង** ឬ **V** ។




### ង.ម៉ូលេគុលអ៊ីយ៉ុងប្រភេទ $AX_3E$

ធរណីមាត្រនៃម៉ូលេគុល **$AX_3E$** ទាញចេញពីម៉ូលេគុល **$AX_4$** ។ម៉ូលេគុល **$AX_3E$** មានទម្រង់ជា **ពីរ៉ាមីត** ដែលមានបាតជា **ត្រីកោណសម័ង្ស** ។




### ច.ម៉ូលេគុលប្រភេទ $AX_2E_2$

ធរណីមាត្រនៃម៉ូលេគុល **$AX_2E_2$** បានមកពីម៉ូលេគុល **$AX_4$** ។ម៉ូលេគុល **$AX_2E_2$** មានទម្រង់ **បង្កោង** ឬ **V** ។



## មេរៀនទី២ : រូបសណ្ឋាននិងទ្រង់ទ្រាយនៃម៉ូលេគុល

### I.អ៊ីសូមែ

**និយមន័យ :** ***អ៊ីសូមែពីរ គឺជាសមាសធាតុពីរដែលមានរូបមន្តដុលដូចគ្នា ប៉ុន្តែមានម៉ូលេគុលខុសគ្នា***។ ម៉ូលេគុលពីរដែលខុសគ្នា មិនត្រួតស៊ីគ្នាទេ ហើយមានលក្ខណៈរូបនិងលក្ខណៈគីមីក៏ខុសគ្នាដែរ ។ អ៊ីសូមែរមានពីរប្រភេទធំៗគឺ **អ៊ីសូមែប្លង់** និង **អ៊ីសូមែលំហ** ។

### II. អ៊ីសូមែប្លង់

សមាសធាតុពីរជាអ៊ីសូមែប្លង់នឹងគ្នា កាលណាវាមានរូបមន្តដុលដូចគ្នា ប៉ុន្តែមានរូបមន្តស្ទើរលាត ឬរូបមន្តលាតខុសគ្នា។

រូបមន្តស្ទើរលាត ឬរូបមន្តលាតគេហៅថា ***រូបមន្តប្លង់*** ។ អ៊ីសូមែប្លង់ចែកជាបីប្រភេទគឺ ***អ៊ីសូមែខ្សែកាបូន អ៊ីសូមែទីតាំង និង អ៊ីសូមែនាទី*** ។

**១.អ៊ីសូមែខ្សែកាបូន :** ***អ៊ីសូមែខ្សែកាបូនជាប្រភេទម៉ូលេគុលដែលខុសគ្នាដោយរបៀបបន្តនៃអាតូមកាបូន***។

ឧ. ប៊ុយតាន $C_4H_{10}$ មានអ៊ីសូមែខ្សែកាបូន : $CH_3-CH_2-CH_2-CH_3$ n.ប៊ុយតាន និង $CH_3-CH(CH_3)-CH_3$ មេទីលប្រូប៉ាន ។

**២.អ៊ីសូមែទីតាំង :** ***ជាប្រភេទម៉ូលេគុលដែលមានខ្សែកាបូនដូចគ្នា តែមានសម្ព័ន្ធពីរជាន់ ឬបីជាន់ ឬបង្គុំនាទី (បណ្តុំអាតូមសំគាល់លក្ខណៈ) ស្ថិតនៅលើទីតាំងខុសគ្នា***។ ឧ. សង្កេតអ៊ីសូមែរបស់ ប៊ុយតាន ($C_4H_8$) និង ប្រូប៉ាណុល ($C_3H_7OH$)

| | | | | | |
|---|---|---|---|---|---|
| $C_4H_8$ : | $CH_3-CH_2-CH=CH_2$ | ប៊ុយ-1-អែន | $C_3H_7OH$ : | $CH_3-CH_2-CH_2OH$ | ប្រូប៉ាន-1-អុល |
| | $CH_3-CH=CH-CH_3$ | ប៊ុយ-2-អែន | | $CH_3-CHOH-CH_3$ | ប្រូប៉ាន-2-អុល |

**៣.អ៊ីសូមែនាទី :** ***អ៊ីសូមែនាទីជាប្រភេទម៉ូលេគុលដែលខុសគ្នាដោយបង្គុំនាទី***។

ឧ. អ៊ីសូមែនាទីនៃរូបមន្តដុល $C_3H_8O$ :

$CH_3-CH_2-CH_2OH$ ប្រូប៉ាន-1-អុល (នាទីអាល់កុល) និង $CH_3-O-CH_2-CH_3$ មេតុកស៊ីអេតាន (នាទីជាអេទែ) ។

### III.អ៊ីសូមែលំហ ឬ ស្តេរ៉េអូអ៊ីសូមែ

**និយមន័យ :** ***អ៊ីសូមែលំហជាសមាសធាតុទាំងឡាយដែលមានរូបមន្តប្លង់ដូចគ្នា ប៉ុន្តែមានរូបមន្តលំហខុសគ្នា***។ ម៉ូលេគុលទាំងនោះមិនត្រួតស៊ីគ្នាទេ ។ រូបមន្តដែលបង្ហាញពីទីតាំងអាតូមក្នុងលំហហៅថា **រូបមន្តលំហ** ។ ឧ. ម៉ូលេគុល មេតាន




អ៊ីសូមែលំហ ឬស្តេរ៉េអូអ៊ីសូមែចែកជាពីរប្រភេទគឺ :

**-អ៊ីសូមែទ្រង់ទ្រាយ ឬ អ៊ីសូមែកុងផរម៉ាស្យុង (Conformation Isomer)**

**-អ៊ីសូមែរូបសណ្ឋាន ឬ អ៊ីសូមែកុងភីគ្វ័រាស្យុង (Configuration Isomer)** ។

**១. អ៊ីសូមែទ្រង់ទ្រាយ ឬ អ៊ីសូមែកុងផរម៉ាស្យុង**

***អ៊ីសូមែទ្រង់ទ្រាយ ឬ អ៊ីសូមែកុងផរម៉ាស្យុង នៃម៉ូលេគុលកើតឡើងដោយសាររង្វិលជុំវិញសម្ព័ន្ធទោល C – C កាលណា***

***ម៉ូលេគុលនោះបានទទួលថាមពលបន្តិចបន្តួច ។***

គេអាចតាងទ្រង់ទ្រាយមួយនៃម៉ូលេគុលតាមចំណោលញ៉ូម៉ាន់ **ញ៉ូម៉ាន់** (**Newman**) ។ ក្នុងចំណោលញ៉ូម៉ាន់ភ្នែកអ្នកសង្កេតត្រូវមើលតាមបណ្តោយសម្ព័ន្ធ **C – C** ។ ឧ. ករណីសិក្សាលើម៉ូលេគុល **អេតាន** $CH_3 – CH_3$




-កាលណាមុំ α មានតម្លៃ 60° ឬ 180° ឬ 300° គេបាន **ទ្រង់ទ្រាយផ្កាយ** ។

-កាលណាមុំ α មានតម្លៃខុសពីទ្រង់ទ្រាយជាន់ និងទ្រង់ទ្រាយផ្កាយ គេហៅថា **ទ្រង់ទ្រាយបង្ខិត** ( ទ្រង់ទ្រាយផ្កាយក៏ជាទ្រង់ទ្រាយបង្ខិតតែឋិតក្នុងករណីពិសេស) ។

**២.អ៊ីសូមែររូបសណ្ឋាន ឬ អ៊ីសូមែរធរណីមាត្រ**

***អ៊ីសូមែររូបសណ្ឋាននៃម៉ូលេគុលដែលមានរូបមន្តប្លង់កំណត់មួយគឺជាភាពខុសគ្នានៃទីតាំងអាតូមក្នុងលំហ ( ដោយមិនគិតពីទីតាំងនៃអាតូមដែលខុសគ្នាដោយសាររង្វិលជុំវិញសម្ព័ន្ធទោល C – C មួយឬច្រើនឡើយ ) ។***

អ៊ីសូមែររូបសណ្ឋានចែកជាពីរប្រភេទគឺ **អ៊ីសូមែរធរណីមាត្រ** និង **អ៊ីសូមែរអុបទិច** ។

**ក.អ៊ីសូមែរធរណីមាត្រ (អ៊ីសូមែររូបសណ្ឋាន Z – E នៃសមាសធាតុអេទីឡេនិច ឬអាល់សែន)**

អ៊ីសូមែររូបសណ្ឋាន **Z – E** កើតមានចំពោះសមាសធាតុអេទីឡេនិចដែលមានទម្រង់ **R – CH = CH – R’** ( **R** និង **R’** អាចដូចគ្នា ) តាមរបៀបដែលអាតូម **H** នៅតែម្ខាង ឬនៅសងខាងសម្ព័ន្ធពីរជាន់ **C = C** ។




ឧ. ករណី ប៊ុយ - 2 - អែន ( $CH_3 – CH = CH – CH_3$ ) មានអ៊ីសូមែ Z - E




***ជាទូទៅ***

គូអ៊ីសូមែទាំងពីរមិនមែនជារូបឆ្លុះគ្នាទៅវិញទៅមកក្នុងកញ្ចក់ទេគេហៅថា ***ឌីអាស្តេរ៉េអូអ៊ីសូមែ***។

**ខ.អ៊ីសូមែរអុបទិច**

***អ៊ីសូមែអុបទិច ឬគូអេណង់ទ្យូមែ គឺជាអ៊ីសូមែររូបសណ្ឋានដែលមានរូបឆ្លុះទៅវិញទៅមកក្នុងកញ្ចក់ឆ្លុះ តែមិនត្រួតស៊ីគ្នាទេ ។*** ករណីនេះកើតមានបណ្តាលមកពីវត្តមាន **កាបូនអស៊ីមេទ្រី** ។

**-អាតូមកាបូនអស៊ីមេទ្រី**

អាតូមកាបូនអស៊ីមេទ្រី គឺជាកាបូនចតុមុខដែលភ្ជាប់ជាមួយអាតូម 4 ឬក្រុមអាតូម 4 ខុសៗគ្នា។ ជាទម្លាប់គេដៅអាតូមកាបូនអស៊ីមេទ្រីដោយសញ្ញាផ្កាយ ( * ) ។




ឧទាហរណ៍ : ចូរដាក់សញ្ញាផ្កាយឱ្យកាបូនអស៊ីមេទ្រីក្នុងម៉ូលេគុលខាងក្រោម :

អាស៊ីតឡាក់ទិច $CH_3 - CHOH - COOH$

អាស៊ីតតាកទ្រិច $HOOC - CHOH - CHOH - COOH$

គ្លុយកូស $CH_2OH - CHOH - CHOH - CHOH - CHOH - CHO$




***ជាទូទៅ :*** ម៉ូលេគុលទាំងឡាយណាដែលមានកាបូនអស៊ីមេទ្រីមួយ ដែលក្នុងនោះបណ្តុំអាតូមទាំង 4 តាងដោយ A, B, D, E បង្ហាញនូវរូបសណ្ឋាន 2 យ៉ាងដែលជា **គូអេណង់ទ្យូមែ**។ គូអេណង់ទ្យូមែជាម៉ូលេគុលដែលមានរូបឆ្លុះគ្នាទៅវិញទៅមកក្នុងកញ្ចក់ ប៉ុន្តែមិនត្រួតស៊ីគ្នាទេ។ ចំនួនអេណង់ទ្យូមែកើនជាមួយចំនួនកាបូនអស៊ីមេទ្រីក្នុងម៉ូលេគុល។ ម៉ូលេគុលដែលមានក្នុងធម្មជាតិអាចមានចំនួនកាបូនអស៊ីមេទ្រីមួយ ឬច្រើន។

**-ភាពគីរ៉ាល់** : ភាពគីរ៉ាល់ គឺជាលក្ខណៈរបស់វត្ថុមួយដែលមិនត្រួតស៊ីគ្នាទៅនឹងរូបភាពរបស់វាក្នុងកញ្ចក់ឆ្លុះ។

មានវត្ថុជាច្រើនដែលជាវត្ថុគីរ៉ាល់។ អេណង់ទ្យូមែជាម៉ូលេគុលគីរ៉ាល់។ ម៉ូលេគុលដែលមានកាបូនអស៊ីមេទ្រីមួយគឺជា ម៉ូលេគុលគីរ៉ាល់។ ផ្ទុយទៅវិញម៉ូលេគុល ឬ វត្ថុដែលត្រួតស៊ីគ្នាទៅនឹងរូបភាពរបស់វាក្នុងកញ្ចក់ឆ្លុះជាម៉ូលេគុល ឬវត្ថុ ***អាគីរ៉ាល់។***

ឧទាហរណ៍ : បាតដៃ កូនសោ ឆ្នាំងមានដៃ សំបកខ្យង... ជាវត្ថុគីរ៉ាល់។

ដបទឹកបរិសុទ្ធថាគ្មានផ្លាកយីហោក្រុមហ៊ុន ជាវត្ថុអាគីរ៉ាល់។

**ជំពូកទី៧ : គីមីសរីរាង្គ**

**មេរៀនទី១ : អាល់កុលនិងអេទែរ**

## I.អាល់កុល

1.**និយមន័យ** : អាល់កុលគឺជាសមាសធាតុសរីរាង្គដែលមានក្រុមអ៊ីដ្រុកស៊ីល (–OH) ភ្ជាប់ទៅនឹងអាតូមកាបូនចតុមុខ។ ក្រុម –OH មាន ឈ្មោះថាបង្គុំនាទីអាល់កុល ឯអាតូមកាបូនដែលភ្ជាប់ជាមួយបង្គុំនាទីមានឈ្មោះថា កាបូននាទី ។

កាលណាក្រុម –OH ភ្ជាប់ទៅនឹងអាតូម C ដែលមិនចតុមុខ សមាសធាតុនោះមិនមែនជាអាល់កុលទេ។

2.**អាល់កុលស្រឡាយអាល់កាន ឬម៉ូណូអាល់កុលឆ្អែត**

**ក.រូបមន្តទូទៅ** : អាល់កុលស្រឡាយអាល់កាន បានមកពីការជំនួសអាតូមអ៊ីដ្រូសែនមួយនៃអាល់កានដោយក្រុម –OH និង មានរូបមន្តទូទៅ $C_nH_{2n+1}$-OH ឬ $C_nH_{2n+2}O$ ។ ម៉ូលេគុលអាល់កុលប្រភេទនេះមានបង្គុំនាទីអាល់កុលតែមួយ និងមានសម្ព័ន្ធកូវ៉ាឡង់ទោលទាំងអស់ ដូច្នេះហើយបានជាគេហៅថា **ម៉ូណូអាល់កុលឆ្អែត** ។

**ខ.នាមវលីអន្តរជាតិ (IUPAC)**

ឈ្មោះរបស់អាល់កុលបានមកពីឈ្មោះអាល់កាន និងបន្ថែមបច្ច័មបទ **អុល** ។

***វិធាន*** : - ជ្រើសរើសខ្សែមេ គឺជាខ្សែដែលមានកាបូនច្រើនជាងគេ ហើយផ្ទុកក្រុម –OH

- ចុះលេខឱ្យអាតូមកាបូនខ្សែមេដោយចាប់ផ្ដើមពីអាតូមកាបូនចុងខ្សែដែលនៅជិតក្រុម –OH ជាងគេ

- ឈ្មោះអាល់កុល = ឈ្មោះអាល់កាន + វង្កុសញ្ញា + លេខកាបូននាទី + វង្កុសញ្ញា + អុល ។

ឧ.

**គ.ថ្នាក់នៃវិចមីនៃអាល់កុល**

គេចែកអាល់កុលជាបីថ្នាក់ដោយផ្អែកទៅតាមចំនួនអាតូមកាបូនដែលភ្ជាប់ជាមួយ C នាទី :

អាល់កុលថ្នាក់ I : មានអាតូមកាបូន 1 ភ្ជាប់នឹងអាតូមកាបូននាទី R–$CH_2$OH ( R ជាក្រុមអាល់គីល) ។

អាល់កុលថ្នាក់ II: មានអាតូមកាបូន 2 ភ្ជាប់នឹងអាតូមកាបូននាទី $R_1$–CHOH–$R_2$ ។

អាល់កុលថ្នាក់ III: មានអាតូមកាបូន 3 ភ្ជាប់នឹងអាតូមកាបូននាទី $R_1$–COH$R_3$–$R_2$ ។

ឧ.

3. **ប៉ូលីអាល់កុល**

ប៉ូលីអាល់កុល ឬប៉ូលីអុល ជាសមាសធាតុសរីរាង្គ ដែលម៉ូលេគុលវាមានក្រុមអ៊ីដ្រុកស៊ីល ពីរ ឬ ច្រើនហើយដែលក្រុមនីមួយៗភ្ជាប់ទៅនឹងកាបូនចតុមុខផ្សេងៗពីគ្នា ។ ប៉ូលីអាល់កុលមានលក្ខណៈគីមីស្រដៀងគ្នានឹងម៉ូណូអាល់កុលដែរ ។

ឧ. $CH_2$OH–$CH_2$OH ....................................................................................................

$CH_2$OH–CHOH–$CH_2$OH ....................................................................................................

## II.អេទែរ

1.**និយមន័យ** : អេទែរគឺជាសមាសធាតុសរីរាង្គដែលគេចាត់ទុកហាក់ដូចជាស្រលាយនៃអាល់កុល ដែលអ៊ីដ្រូសែននៃក្រុម –OH ត្រូវ បានជំនួសដោយរ៉ាឌីកាល់អ៊ីដ្រូកាបូ (–R) ។

2.**នាមវលី(IUPAC)** : គេអាចហៅឈ្មោះអេទែរតាមពីររបៀប :

*របៀបទី១ :* នាមវលីដែលបញ្ជាក់នាទីអេទែ គេហៅឈ្មោះរ៉ាឌីកាល់អ៊ីដ្រូកាបួនីមួយៗតាមលំដាប់អក្សរក្រមឡាតាំង រួចបន្ថែមពាក្យ *អេទែ*។

ឧ. $CH_3–O–CH_3$…………………………………………… ឧ.$CH_2=CH–O–CH=CH_2$……………………………

$C_2H_5–O–C_2H_5$…………………………………………… $CH_3–O–C_6H_5$……………………………………………

*របៀបទី២ :* យករ៉ាឌីកាល់អ៊ីដ្រូកាបួណាមួយដែលងាយ ភ្ជាប់ជាមួយអាតូមអុកស៊ីសែន ហើយហៅឈ្មោះថា ក្រុមអាល់កុកស៊ី ឬ ក្រុមអារ៉ុកស៊ី ដូចជា :

$CH_3–O^-$ មេតុកស៊ី

$CH_3–CH_2–O^-$ អេតុកស៊ី

$CH_3–CH_2–CH_2–O^-$ ប្រូប៉ុកស៊ី

$C_6H_5–O^-$ ឬ ផេណុកស៊ី

$C_6H_5–CH_2–O^-$ ឬ បង់ស៊ីឡុកស៊ី

ឧ.

## III. លក្ខណៈរូបអាល់កុល

អាល់កុលមានសីតុណ្ហភាពរំពុះខ្ពស់បើប្រៀបធៀបទៅនឹងសមាសធាតុសរីរាង្គផ្សេងៗទៀតដែលមានម៉ាសម៉ូលប្រហែលគ្នា នេះបណ្ដាលមកពីវត្តមានសម្ព័ន្ធអ៊ីដ្រូសែនរវាងម៉ូលេគុល អាល់កុល-អាល់កុល ។ អាល់កុលរលាយក្នុងទឹកយ៉ាងខ្លាំងគឺបណ្ដាលមកពីវត្តមានសម្ព័ន្ធអ៊ីដ្រូសែនរវាងម៉ូលេគុលអាល់កុល-ទឹក ។

## IV. លក្ខណៈគីមីរបស់អាល់កុល

អាល់កុលចូលរួមប្រតិកម្មគីមីជាច្រើនដែលកើតឡើងដោយការផ្ដាច់សម្ព័ន្ធ អុកស៊ីសែន-អ៊ីដ្រូសែន ($–O\downarrow H$) ឬការផ្ដាច់សម្ព័ន្ធ កាបូន-អុកស៊ីសែន ($–C\downarrow OH$) ។

### 1. រេដុកម្មអាល់កុលដោយសូដ្យូម

អាល់កុលគ្រប់ថ្នាក់មានប្រតិកម្មជាមួយសូដ្យូម ដោយអាល់កុលរងរេដុកម្មជាអ៊ីយ៉ុងអាល់កូឡាត និងបំភាយអ៊ីដ្រូសែន។

ឧ. $2CH_3–CH_2OH + Na \rightarrow 2CH_3–CH_2ONa + H_2$

### 2. ប្រតិកម្មដេស៊ីដ្រាតកម្មអេតាណុល

#### ក. ដកទឹក១ម៉ូលេគុលពី១ម៉ូលេគុលអាល់កុល

បើគេឱ្យចំហាយអេតាណុលឆ្លងកាត់អាលុយមីន ដុតកម្ដៅនៅ 400°C និងកាតាលីករ $H_2SO_4$ខាប់ នៅ 180°C គេទទួល បានអេទីឡែន និងទឹក តាមសមីការ :

$$CH_3–CH_2OH \xrightarrow[400°C]{Al_2O_3} CH_2=CH_2 + H_2O$$

$$CH_3–CH_2OH \xrightarrow[180°C]{H_2SO_4} CH_2=CH_2 + H_2O$$

#### ខ. ដកទឹក១ម៉ូលេគុលពី២ម៉ូលេគុលអាល់កុល

ក្នុងករណីខាងលើបើសិនជាសីតុណ្ហភាពមិនសូវខ្ពស់គេនឹងទទួលបានផលិតផលផ្សេងៗ តាមសមីការ

$$C_2H_5–OH + HO–C_2H_5 \xrightarrow[250°C]{Al_2O_3} C_2H_5–O–C_2H_5 + H_2O$$

$C_2H_5–OH + HO–C_2H_5 \xrightarrow[140°C]{H_2SO_4} C_2H_5–O–C_2H_5 + H_2O$

3. **ប្រតិកម្មជាមួយអ៊ីដ្រូសែនអាឡូសែនួ**

អាល់កុលធ្វើប្រតិកម្មជាមួយអ៊ីដ្រូសែនអាឡូសែនួ (HX) បង្កើតបានជាអាល់គីលអាឡូសែនួ។

$R–OH + HX \rightarrow R–X + H_2O$

ឱ. $CH_3–CH_2OH + HBr \rightarrow CH_3–CH_2Br + H_2O$

4. **ប្រតិកម្មអុកស៊ីតកម្មអាល់កុល**

**ក. ប្រតិកម្មចំហេះ :** ប្រតិកម្មចំហេះសព្វនៃអេតាណុលបង្កើតជាទឹកនិងកាបូនឌីអុកស៊ីត តាមសមីការ

$C_2H_5OH + 3O_2 \rightarrow 2CO_2 + 3H_2O$

**ខ. ប្រតិកម្មអុកស៊ីតកម្មតាមសម្រួលនៃអេតាណុល**

អុកស៊ីតកម្មតាមសម្រួលជាអុកស៊ីតកម្មដែលមិនធ្វើឱ្យមានកំណែប្រែដល់ខ្សែកាបូននៃម៉ូលេគុលទេ ឯចំហេះគឺជាអុកស៊ីតកម្មដែលបំផ្លាញខ្សែកាបូន។ អុកស៊ីតកម្មតាមសម្រួលអាចប្រព្រឹត្តទៅក្នុងផាសចំហាយ និងផាសរាវ។

នៅចំពោះមុខអុកស៊ីតករក្នុងមជ្ឈដ្ឋានអាស៊ីត អាចឱ្យយើងសំគាល់បាននូវលក្ខណៈខុសគ្នារវាងអាល់កុលទាំងបីថ្នាក់ :

*-អាល់កុលថ្នាក់ I :*

ករណីអុកស៊ីតករមិនគ្រប់គ្រាន់ : អាល់កុលថ្នាក់ I រងអុកស៊ីតកម្មជាអាល់ដេអ៊ីត និងមួយផ្នែកជាអា ស៊ីតកាបុកស៊ីលិច។

$R–CH_2OH \xrightarrow{[O]} R–CHO \xrightarrow{[O]} R–COOH$

ករណីអុកស៊ីតករលើស : អាល់កុលថ្នាក់ I រងអុកស៊ីកម្មជាអាស៊ីតកាបុកស៊ីលិច

$R–CH_2OH \xrightarrow{[O]} R–COOH$

*-អាល់កុលថ្នាក់ II :* រងអុកស៊ីតកម្មជាសេតូន

$R_1–CHOH–R_2 \xrightarrow{[O]} R_1–CO–R_2$

*-អាល់កុលថ្នាក់III:* មិនរងអុកស៊ីតកម្មទេ។

*សំគាល់* : ករណីដែលអុកស៊ីតករខាប់ខ្លាំងនិងប្រើក្នុងបរិមាណលើស ព្រមទាំងមានការដុតកម្តៅផង ប្រតិកម្មនឹងទៅហួសអុកស៊ីតកម្មតាមសម្រួលដោយច្រវាក់កាបូនត្រូវដាច់។ ពេលនោះអាល់កុលថ្នាក់ III រងអុកស៊ីតកម្មហើយបង្កើតទៅជាអាស៊ីតកាបុកស៊ីលិចច្រើនប្រភេទ។

5. **ប្រតិកម្មដេស៊ីដ្រូសែនកម្ម :** ដេស៊ីដ្រូសែនកម្មអាល់កុលថ្នាក់ I បង្កើតជាអាល់ដេអ៊ីត ហើយដេស៊ីដ្រូសែនកម្មអាល់កុលថ្នាក់ II បង្កើតជាសេតូន។

$R–CH_2OH \xrightarrow[300°C]{Cu} R–CHO + H_2$

$R_1–CHOH–R_2 \xrightarrow[300°C]{Cu} R_1–CO–R_2 + H_2$

V. **ផលិតអាល់កុលនិងប្រើប្រាស់**

**1. អ៊ីដ្រាតកម្មអាល់សែន :** វិធីធ្វើអាល់កុលគឺអ៊ីដ្រាតកម្មអាល់សែនដែលផ្តល់បរិមាណគ្រប់គ្រាន់សម្រាប់តម្រូវការក្នុង ឧស្សាហកម្ម។

ឧ. $CH_2=CH_2 + H_2O \rightarrow CH_3-CH_2OH$

$CH_3-CH=CH_2 + H_2O \rightarrow CH_3-CHOH-CH_3$

$CH_3-C(CH_3)=CH_2 + H_2O \rightarrow CH_3-COH(CH_3)-CH_3$

### ២.នាទីអាល់កុលតាមវិធីផ្សេងទៀត

#### ក.នាទីមេតាណុល :

$$CO + 2H_2 \xrightarrow[400°C\ និង\ 200\ atm]{កាតាលីករ} CH_3OH$$

**ខ.នាទីអេតាណុល :** គេអាចទធ្វើអេតាណុលដោយល្បើងអាល់កុលនៃគ្លុយកូស $C_6H_{12}O_6$ តាមសមីការ

$$C_6H_{12}O_6 \xrightarrow[30°C]{កាតាលីករ} 2C_2H_5OH + 2CO_2$$

កាតាលីករក្នុងករណីនេះគឺជាអង់ស៊ីមបញ្ចេញដោយមេដំបែដែលជាផ្សិតមីក្រូសារពាង្គកាយមានជីវិតរស់នៅលើសំបកផ្លែឈើ ។

## VI. លក្ខណៈរូបអេទែ

អេទែជាអង្គធាតុគ្មានពណ៌ មានក្លិនគួរជាទីគាប់ចិត្ត រលាយតិចក្នុងទឹក និងមានសីតុណ្ហភាពពុះទាបជាងអាល់កុលដែល មានចំនួនអាតូមកាបូនដូចគ្នា ។

**VII.លក្ខណៈគីមីអេទែ :** អេទែមានប្រតិកម្មជាមួយអ៊ីដ្រូសែនអាឡូសែនលើសក្រោមការដុតកម្តៅ :

$$R_1-O-R_2 + 2HX(លើស) \xrightarrow{t°} R_1X + R_2X + H_2O$$

ឧ. $CH_3-O-C_2H_5 + 2HBr \xrightarrow{t°} ?$

## VIII.នាទីនិងបម្រើបម្រាស់អេទែ

### 1.នាទី

ក.ចំពោះអេទែដែលមានរ៉ាឌីកាល់អ៊ីដ្រូកាបួដូចគ្នា(R-O-R)អាចទធ្វើឡើងតាមប្រតិកម្មដេស៊ីដ្រាកម្មរវាងពីរម៉ូលេគុលអាល់កុល

ឧ. $C_2H_5-OH + HO-C_2H_5 \xrightarrow[140°C]{H_2SO_4} C_2H_5-O-C_2H_5 + H_2O$

ខ.តាមវិធី Williamson គេអាចសំយោគបានចំពោះអេទែ (R–O–R) និង ($R_1$–O–$R_2$) ដោយឱ្យអំបិលសូដ្យូមរបស់អាល់កុលមានអំពើជាមួយស្រឡាយអាឡូសែន ។

$R_1-O-Na + R_2X \rightarrow R_1-O-R_2 + NaX$

ឧ. $CH_3-O-Na + C_2H_5Br \rightarrow ?$

### ២.បម្រើបម្រាស់

គេប្រើអេទែជាធាតុរំលាយ វាអាចរំលាយសារធាតុមិនប៉ូលែបាន ដូច្នេះហើយបានជាគេប្រើវាជាធាតុរំលាយក្នុងប្រតិកម្មអង្គធាតុសរីរាង្គ ។ ឌីអេទីលអេទែ ជាអង្គធាតុរាវឆាប់ហើរ គ្មានពណ៌ ងាយឆាបភ្លើង ។ វាជាធាតុរំលាយដ៏ល្អសម្រាប់សារធាតុសរីរាង្គ និងប្រើជាថ្នាំស្ពឹកតាមរយៈការស្រូបក្លិនរបស់វា ។

## មេរៀនទី២ : អាល់ដេអ៊ីត និង សេតូន

### I. អាល់ដេអ៊ីត

#### 1. រូបមន្តទូទៅ

កាលណាសម្ព័ន្ធមួយនៃកាបូននាទី ភ្ជាប់ជាមួយអាតូមអ៊ីដ្រូសែន សមាសធាតុនោះមានឈ្មោះថា អាល់ដេអ៊ីត ។

អាល់ដេអ៊ីតមានរូបមន្តទូទៅ : R-CHO ឬ

-CHO( បង្គុំកាបូនីល) ជាបង្គុំនាទីអាល់ដេអ៊ីត ដែល R អាចជាអាតូម H ឬជាអាតូមកាបូននៃរ៉ាឌីកាល់អ៊ីដ្រូកាបួណាមួយ ។

ឧ. $H-\underset{H}{\underset{|}{C}}=O$ អាល់ដេអ៊ីតផរមិច $C_nH_{2n+1}-\underset{H}{\underset{|}{C}}=O$ អាល់ដេអ៊ីតឆ្អែត  អាល់ដេអ៊ីតប្រហើរ

#### 2. នាមវលី

របៀបហៅឈ្មោះប្រហាក់ប្រហែលទៅនឹងករណីអាល់កុលដែរប៉ុន្តែមានបច្ច័មបទ អាល់ ។

វិធាន : -ជ្រើសរើសខ្សែកាបូនដែលវែងជាងគេ ហើយមានបង្គុំកាបូនីលជាខ្សែមេ ។

-ត្រូវបង់លេខ 1 ឱ្យកាបូននាទីជានិច្ច ។

-ហៅឈ្មោះខ្សែមេ ហើយបន្ថែមបច្ច័មបទ អាល់ ។

ឧ.

### II. សេតូន

#### 1. រូបមន្តទូទៅ

សេតូនគឺជាសមាសធាតុស្រឡាយកាបូនីលដែលក្នុងនោះសម្ព័ន្ធទាំងពីរនៃបង្គុំកាបូនីល ត្រូវភ្ជាប់ទៅនឹងអាតូមកាបូននៃ រ៉ាឌីកាល់អ៊ីដ្រូកាបួពីរទៀត ។

រូបមន្តទូទៅ : $R_1-\underset{R_2}{\underset{|}{C}}=O$ ឬ $R_1-\underset{O}{\underset{||}{C}}-R_2$

$R_1$ និង $R_2$ ជារ៉ាឌីកាល់អ៊ីដ្រូកាបួពីរ ដែលអាចដូចគ្នា ។

$R_1$ និង $R_2$ អាចជារ៉ាឌីកាល់អ៊ីដ្រូកាបួឆ្អែត មិនទាន់ឆ្អែត ស៊ិច ឬ ប្រហើរ ។

ឧ.

#### 2. នាមវលី

វិធាន : -ជ្រើសរើសខ្សែកាបូនដែលវែងជាងគេហើយមានបង្គុំកាបូនីលជាខ្សែមេ

-ចុះលេខឱ្យអាតូមកាបូនខ្សែមេលើយ៉ាងណាឱ្យអាតូមកាបូននាទីមានលេខតូច

-ហៅឈ្មោះខ្សែមេដោយបញ្ជាក់ទីតាំងកាបូននាទីហើយបន្ថែមបច្ច័មបទ អូន ។

ឧ.

ម្យ៉ាងទៀតមាននាមវលីមួយទៀតដែលគេនិយមប្រើដែរគឺហៅតាមនាទីសេតូន ដោយហៅឈ្មោះក្រុម $R_1$ និង $R_2$តាមលំដាប់អក្ខរក្រមឡាតាំង ហើយបន្ថែមពាក្យ សេតូន ។

ឧ.

## III.លក្ខណៈរូបនិងគីមីអាល់ដេអ៊ីត

### ១.លក្ខណៈរូប

ចំពោះអាល់ដេអ៊ីតផ្លែតតួទី១និងទី2គឺជាឧស្ម័ននៅសីតុណ្ហភាពប្រក្រតីឯតួបន្ទាប់ៗជាអង្គធាតុរាវ ឬ រឹងកាលណាម៉ាសម៉ូលេគុលវាកាន់តែច្រើន។ ចំនាញទាំងម៉ូលេគុលមិនសូវខ្លាំងដូចក្នុងករណីអាល់កុលទេ។ កម្រិតរលាយក្នុងទឹកថយចុះជាមួយកំណើនម៉ាសម៉ូលេគុល។ ចាប់ពីកាបូន 5 ទៅវាស្ទើរតែមិនរលាយក្នុងទឹក។ អាល់ដេអ៊ីតមានក្លិនឈ្ងុលខ្លាំង។

### ២.លក្ខណៈគីមី

#### ក.ប្រតិកម្មបូកជាមួយអ៊ីដ្រូសែន

អាល់ដេអ៊ីត + $H_2$ $\xrightarrow[t^\circ]{Ni}$ អាល់កុលថ្នាក់ I

ឧ.

#### ខ.ប្រតិកម្មបូកជាមួយទឹក

អាល់ដេអ៊ីត + H-OH $\leftrightarrows$ អាល់ដេអ៊ីតអ៊ីដ្រាត

ឧ.

#### គ.ប្រតិកម្មអុកស៊ីតកម្ម

អាល់ដេអ៊ីត $\xrightarrow{[O]}$ អាស៊ីតកាបុកស៊ីលិច

ឧ.

#### គ.១.អុកស៊ីតកម្មដោយរ៉េអាក់ទីបតូឡង់ (កុំផ្លិច$Ag^+$)

រ៉េអាក់ទីបតូឡង់គឺជាសូលុយស្យុងថ្លាគ្មានពណ៌បានមកដោយការបន្តក់សូ.អាម៉ូញ៉ាក់ទៅក្នុងសូ.ប្រាក់នីត្រាតដែលក្នុងនោះអ៊ីយ៉ុងប្រាក់ស្ថិតនៅជាកុំផ្លិចជាមួយអាម៉ូញ៉ាក់មានឈ្មោះថាអ៊ីយ៉ុងប្រាក់ឌីអាមីន គឺ $[Ag(NH_3)_2]^+$។

រ៉េអាក់ទីបតូឡង់ត្រូវបានប្រើដើម្បីរកអត្តសញ្ញាណអាល់ដេអ៊ីត តាមសមីការខាងក្រោម :

$$R\text{-}CHO + 2[Ag(NH_3)_2]^+ + 3OH^- \rightarrow R\text{-}COO^- + 2Ag + 4NH_3 + 2H_2O$$

#### គ.២.អុកស៊ីតកម្មដោយទឹកផេលិញ (កុំផ្លិច$Cu^{2+}$)

ទឹកផេលិញគឺជាសូ.បាសមានពណ៌ខៀវចាស់ដែលក្នុងនោះមានកុំផ្លិចដែលកើតឡើងដោយ $Cu^{2+}$ និងអាញ៉ុងនៃអាស៊ីតតាកទ្រិច។

អាល់ដេអ៊ីតរងអុកស៊ីតកម្មដោយទឹកផេលិញឱ្យផលជាអាញ៉ុងកាបុកស៊ីឡាតនិងកករ$Cu_2O$ពណ៌ក្រហមដូចឥដ្ឋ។ សមីការ

$$R\text{-}CHO + 2Cu^{2+}(\text{កុំផ្លិច}) + 5OH^- \rightarrow R\text{-}COO^- + Cu_2O + 3H_2O$$

IV.**ផលិតនិងបម្រើបម្រាស់អាល់ដេអ៊ីត**

**១.ផលិត**

**ក.អុកស៊ីតកម្មអ៊ីដ្រូកាបួ**

ក្នុងលក្ខខណ្ឌប្រកបអ៊ីដ្រូកាបួប្រភេទខ្លះរងអុកស៊ីតកម្មក្លាយជាអាល់ដេអ៊ីត។ តាមវិធីនេះហើយដែលគេអាចសំយោគអាល់ដេអ៊ីតបានក្នុងបរិមាណដ៏ច្រើន។

ឧ.ទង្វើមេតាណាល់ : គេកម្តៅល្បាយឧស្ម័នមេតាននិងខ្យល់នៅសី.តុ 600°C ទៅ 700°C ចំពោះមុខកាតាលីករអាស្មូតអុកស៊ីត គេទទួលបានមេតាណាល់ តាមសមីការ :

$$CH_4 + O_2 \rightarrow H-CHO + H_2O$$

**ខ.អ៊ីដ្រាតកម្មអាសេទីឡែន**

ក្នុងមជ្ឈដ្ឋានអាស៊ីតស៊ុលផួរិចរាវនិងមានវត្តមានអំបិលបារតII អាសេទីឡែនរងអ៊ីដ្រាតកម្មជាអេតាណាល់។ សមីការ

$$C_2H_2 + H_2O \rightarrow CH_3-CHO$$

**គ.ដេស៊ីដ្រូសែនកម្មអាល់កុលថ្នាក់** I

នេះជាវិធីមួយសំខាន់ក្នុងទង្វើអាល់ដេអ៊ីតដែលយើងធ្លាប់បានសិក្សាក្នុងមេរៀនអាល់កុល។ គេត្រូវជ្រើសរើសអុកស៊ីតករណាដែលមិនធ្វើឱ្យអាល់ដេអ៊ីតទើបកើតទទួលអុកស៊ីតកម្មបន្តជាអាស៊ីត។

$$R-CH_2OH \xrightarrow{[O]} R-CHO + H_2$$

ឧ.

**២.បម្រើបម្រាស់**

គេប្រើមេតាណាល់ក្រោមសណ្ឋានជាសូ.ទឹក40%ដែលមានឈ្មោះថា ផរម៉ុល ឬផរម៉ាលីន។ វាអាចសម្លាប់មីក្រុប និងអាចធ្វើឱ្យប្រូតេអ៊ីនកក។ គេប្រើវាសម្រាប់ថែរក្សាសាកសពឱ្យទុកបានយូរ។

IV.**លក្ខណៈរូបនិងគីមីសេតូន**

**១.លក្ខណៈរូប** : សេតូនដែលម៉ានម៉ាសម៉ូលេគុលតូចជាអង្គធាតុរាវគ្មានពណ៌ មានក្លិនជាទីគាប់ចិត្ត រលាយក្នុងទឹក។ ភាពរលាយក្នុងទឹកថយចុះកាលណាចំនួនអាតូមកាបូនកើន។

**២.លក្ខណៈគីមី**

**ក.ប្រតិកម្មបូក** $H_2$ : $R_1-CO-R_2 + H_2 \rightarrow R_1-CHOH-R_2$

**ខ.ប្រតិកម្មបូក** $H_2O$ : $R_1-CO-R_2 + H_2O \rightarrow R_1-C(OH)_2-R_2$

**គ.តេសជាមួយ** 2,4-D.N.P.H

ដូចអាល់ដេអ៊ីតដែរ សេតូនឱ្យកករពណ៌លឿងចាស់កាលណាវាប៉ះជាមួយ 2,4-D.N.P.H ដែលគេប្រើសម្រាប់រកវត្តមាន បង្គុំនាទី កាបូនីល។

ប៉ុន្តែសេតូនខុសពីអាល់ដេអ៊ីតត្រង់សេតូនមិនរងអុកស៊ីតកម្ម ហើយសេតូនមិនមានប្រតិកម្មជាមួយរ៉េអាក់ទីបតូឡង់ , រ៉េអាក់ទីបស៊ីប និងទឹកផេលិញទេ។

## VI.ផលិតកម្មនិងបម្រើបម្រាស់អាល់ដេអ៊ីត

### ១.ផលិត

**ក.អុកស៊ីតកម្ម ឬដេស៊ីដ្រូសែនកម្មអាល់កុលថ្នាក់** II

$R_1–CHOH–R_2 \xrightarrow{[O]} R_1–CO–R_2$

ឧ. $CH_3–CHOH–CH_3 + ½O_2 \rightarrow ?$ (ដេស៊ីដ្រាតកម្ម)

$CH_3–CHOH–CH_3 \rightarrow ?$ (ដេស៊ីដ្រូសែនកម្ម)

**ខ.អ៊ីដ្រាតកម្មអាល់ស៊ីន**

អាល់ស៊ីនរងអ៊ីដ្រាតកម្មជាសេតូនដោយវត្តមានអំបិលបារត II នៅចំពោះមុខអាស៊ីតស៊ុលផួរិចរាវ :

$R_1– C \equiv CH + H_2O \rightarrow R_1–CO–CH_3$

### ២.បម្រើបម្រាស់

អាសេតូនជាដែលងាយជាងគេ ត្រូវបានប្រើជាធាតុរំលាយ សមាសធាតុសែលុយឡូស វ៉ែនី ល័ខ និងរូបធាតុប្លាស្ទិច...។

មេរៀនទី៣ : **អាស៊ីតកាបុកស៊ីលិច**

## I.អាស៊ីតកាបុកស៊ីលិច

**១.និយមន័យ** : ជាសមាសធាតុសរីរាង្គដែលមានបង្គុំកាបុកស៊ីលក្នុងម៉ូលេគុលមានឈ្មោះថា អាស៊ីតកាបុកស៊ីលិច ។

រូបមន្តទូទៅ : R – COOH ឬ $R-\underset{\displaystyle \overset{\|}{O}}{C}-OH$

ដែល R អាចជាអាតូមអ៊ីដ្រូសែន រ៉ាឌីកាល់អ៊ីដ្រូកាបួឆ្អែត មិនទាន់ឆ្អែត ស៊ិច ឬ ប្រហើរ ។

ឧទាហរណ៍ :

**២.នាមវលី** : គេបានស្គាល់អាស៊ីតកាបុកស៊ីលិចជាយូរមកហើយ ។ អាស៊ីតមួយចំនួនត្រូវបានហៅតាមឈ្មោះដែលគេធ្លាប់ប្រើ ។ អាស៊ីតខ្សែបើកមួយចំនួនគេហៅថាអាស៊ីតខ្លាញ់ ព្រោះគេបានវាពីអង្គធាតុខ្លាញ់ ។

### ក.ម៉ូណូអាស៊ីតខ្សែបើកគ្មានខ្នែង

*ឈ្មោះតាម IUPAC = អាស៊ីត + ឈ្មោះខ្សែកាបូន + អូអ៊ិច*

តារាងនាមវលីម៉ូណូអាស៊ីតឆ្អែតពីអាតូម ១ ដល់ ១០

| រូបមន្ត | ប្រភព | នាមវលី IUPAC | នាមវលីធ្លាប់ប្រើ |
|---|---|---|---|
| H – COOH | ស្រមោចភ្លើង | | អាស៊ីតផរមិច |
| $CH_3 – COOH$ | ទឹកខ្មេះ | | អាស៊ីតអាសេទិច |
| $CH_3 – CH_2 – COOH$ | ទឹកដោះគោ | | អាស៊ីតប្រូប្យូនិច |
| $CH_3 – (CH_2)_2 – COOH$ | ប៊ឺរ | | អាស៊ីតប៊ុយទីរិច |
| $CH_3 – (CH_2)_3 – COOH$ | | | អាស៊ីតវ៉ាលេរិច |
| $CH_3 – (CH_2)_4 – COOH$ | ទឹកដោះពពែ | | អាស៊ីតកាប្រូអ៊ិច |
| $CH_3 – (CH_2)_5 – COOH$ | | | អាស៊ីតអេណង់ទិច |
| $CH_3 – (CH_2)_6 – COOH$ | ទឹកដោះពពែ | | អាស៊ីតកាព្រីលិច |
| $CH_3 – (CH_2)_7 – COOH$ | | | អាស៊ីតប៉េឡាកុនិច |
| $CH_3 – (CH_2)_8 – COOH$ | ទឹកដោះពពែ | | អាស៊ីតកាព្រិច |

### ខ.ម៉ូណូអាស៊ីតខ្សែបើកមានខ្នែង

-ជ្រើសរើសខ្សែកាបូនដែលវែងជាងគេហើយមានបង្គុំកាបុកស៊ីលជាខ្សែមេ

-កាបូននាទីជាកាបូនលេខ 1 ជានិច្ច

-ត្រូវហៅឈ្មោះខ្នែងតាមលំដាប់អក្ខរក្រមឡាតាំង ។

ប្រសិនបើគេប្រើនាមវលីដែលធ្លាប់ប្រើវិញ ទីតាំងនៃខ្សែខ្នែងឬបណ្តុំជំនួសត្រូវតាងតាមលំដាប់អក្សរក្រិច គឺ

$\alpha$( អាល់ផា) $\beta$( បែ៊តតា) $\gamma$( កាម៉ា) $\delta$( ដែលតា) ........ ។

ឧ.

### គ.ប៉ូលីអាស៊ីត

ចំពោះ ឌីអាស៊ីត ទ្រីអាស៊ីត.... អាចហៅតាម IUPAC ដោយបន្ថែមពាក្យ ឌីអូអ៊ិច ទ្រីអូអ៊ិច...។ ឧទាហរណ៍ :

| រូបមន្ត | នាមវលី IUPAC | នាមវលីធ្លាប់ប្រើ |
|---|---|---|
| $HOOC - COOH$ | | អាស៊ីតអុកសាលិច |
| $HOOC - CH_2 - COOH$ | | អាស៊ីតម៉ាឡូនិច |
| $HOOC - (CH_2)_2 - COOH$ | | អាស៊ីតស៊ុចស៊ីនិច |
| $HOOC - (CH_2)_3 - COOH$ | | អាស៊ីតគ្លុយតានិច |
| $HOOC - (CH_2)_4 - COOH$ | | អាស៊ីតអាឌីពិច |
|  –COOH –COOH | | អាស៊ីតផ្តាលិច |

## II.អាស៊ីតកាបុកស៊ីលិចសំខាន់ៗ

### ១.អាស៊ីតខ្លាញ់

ខ្លាញ់និងប្រេងគឺជាផ្នែកមួយនៃចំណីអាហាររបស់យើង។ ខ្លាញ់មានដើមកំណើតពីសត្វ ឯប្រេងមានដើមកំណើតពីរុក្ខជាតិ ដូចជា ពោត សណ្តែកសៀង អូលីវ ដូង....។ ខ្លាញ់ជាអង្គធាតុរឹង ឯប្រេងជាអង្គធាតុរាវ ប៉ុន្តែអង្គធាតុទាំងពីរមានទម្រង់គ្រឹះដូចគ្នា។ ខ្លាញ់ និងប្រេងគឺជាអេស្ទែ ដែលកើតមកពីអាស៊ីតខ្លាញ់ និងគ្លីសេរីន។ ជានិច្ចកាលអាស៊ីតខ្លាញ់ មានខ្សែកាបូនជាខ្សែត្រង់គ្មានខ្នែង អាចឆ្អែត ឬមិនឆ្អែត។

អាស៊ីតខ្លាញ់សំខាន់ៗមួយចំនួន

| អាស៊ីតឆ្អែត | ចំនួន C | រូបមន្ត |
|---|---|---|
| អាស៊ីតប៊ុយទីរិច | 4 | $CH_3 - (CH_2)_2 - COOH$ |
| អាស៊ីតកាប្រូអ៊ិច | 6 | $CH_3 - (CH_2)_4 - COOH$ |
| អាស៊ីតកាព្រីលិច | 8 | $CH_3 - (CH_2)_6 - COOH$ |
| អាស៊ីតកាព្រិច | 10 | $CH_3 - (CH_2)_8 - COOH$ |
| អាស៊ីតឡូរិច | 12 | $CH_3 - (CH_2)_{10} - COOH$ |
| អាស៊ីតមីរីស្ទិច | 14 | $CH_3 - (CH_2)_{12} - COOH$ |
| អាស៊ីតប៉ាល់មីទិច | 16 | $CH_3 - (CH_2)_{14} - COOH$ |
| អាស៊ីតស្តេអារិច | 18 | $CH_3 - (CH_2)_{16} - COOH$ |
| អាស៊ីតអារ៉ាស៊ីឌិច | 20 | $CH_3 - (CH_2)_{18} - COOH$ |
| **អាស៊ីតមិនឆ្អែត** | **ចំនួន C** | **រូបមន្ត** |
| អាស៊ីតអូលេអ៊ិច | 18 | $CH_3 - (CH_2)_7 - CH = CH - (CH_2)_7 - COOH$ |
| អាស៊ីតលីណូលេអ៊ិច | 18 | $CH_3 - (CH_2)_4 - CH = CH - CH_2 - CH = CH - (CH_2)_7 - COOH$ |
| អាស៊ីតលីណូលេនិច | 18 | $CH_3 - CH_2 - CH = CH - CH_2 - CH = CH - CH_2 - CH = CH - (CH_2)_7 - COOH$ |
| អាស៊ីតអារ៉ាស៊ីដូនិច | 20 | $CH_3 - (CH_2)_3 - CH = CH - CH_2 - CH = CH - CH_2 - CH = CH - CH_2 - CH = CH - (CH_2)_4 - COOH$ |

### ២.អ៊ីដ្រុកស៊ីអាស៊ីត

| រូបមន្ត | នាមវលី IUPAC | នាមវលីធ្លាប់ប្រើ |
|---|---|---|
| $OH–CH_2–COOH$ | | អាស៊ីតគ្លីកូលិច |
| $CH_3–CHOH–COOH$ | | អាស៊ីតឡាក់ទិច |
| $HOOC–CHOH–CH_2–COOH$ | | អាស៊ីតម៉ាលិច |
| $HOOC–CHOH–CHOH–COOH$ | | អាស៊ីតតាកទ្រិច |
| $HOOC–CH_2–C(OH)(COOH)–CH_2–COOH$ | | អាស៊ីតស៊ីទ្រិច |

## III. អេស្ទែ

**១.និយមន័យ** : អេស្ទែជាសមាសធាតុសរីរាង្គស្រឡាយកាបុកស៊ីល ដែលក្នុងនោះអាតូម H នៃបង្គុំកាបុកស៊ីលត្រូវបានជំនួសដោយរ៉ាឌីកាល់អ៊ីដ្រូកាបួ។

**២.រូបមន្តទូទៅ** : $R_1–COO–R_2$ ឬ $R_1–\underset{\displaystyle O}{\overset{}{C}}\!\!\!\!\!\overset{}{\phantom{C}}–O–R_2$ ($R_1–C(=O)–O–R_2$) ដែល $R_2 \neq H$

$R_1$ និង $R_2$ អាចជា រ៉ាឌីកាល់អ៊ីដ្រូកាបួឆ្អែត មិនទាន់ឆ្អែត ស៊ិច ឬ ប្រហើរ ។

**៣.នាមវលី** : អេស្ទែនីមួយៗមានបច្ច័យ *អូអាត* ។

វិធាន : ក្នុងការហៅឈ្មោះអេស្ទែគេត្រូវបែងចែកជាពីរផ្នែក គឺ ត្រូវហៅខាង $R_2$ មុន បន្ទាប់មកហៅខាងផ្នែក $R_1$ ដោយមានបច្ច័យបទ អូអាត ។

ឧ.

**តារាងសង្ខេប**

| បង្គុំនាទី | សមាសធាតុសរីរាង្គ | រូបមន្តទូទៅ | បច្ច័យបទ |
|---|---|---|---|
| អ៊ីដ្រុកស៊ីល | អាល់កុល | $R – OH$ | អុល |
| | អេទែ | $R_1 – O – R_2$ | អេទែ |
| កាបូនីល | អាល់ដេអ៊ីត | $R – CHO$ | អាល់ |
| | សេតូន | $R_1 – CO – R_2$ | អូន |
| កាបុកស៊ីល | អាស៊ីតកាបុកស៊ីលិច | $R – COOH$ | អូអ៊ិច |
| | អេស្ទែ | $R_1 – COO – R_2$ | អូអាត |